# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ចតុក្កនិបាត

## ភាគ ៤៣

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងចតុក្កនិបាត មាន ១ បណ្ណាសកៈ

មាន ៥ វគ្គ និងវគ្គមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ ៧ វគ្គ

ព្រះអដ្ឋកថាកែសេចក្តី ៥៤ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ចតុក្កនិបាត

## ភាគ ៤៣

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងចតុក្កនិបាត មាន ១ បណ្ណាសកៈ

មាន ៥ វគ្គ និងវគ្គមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ ៧ វគ្គ

ព្រះអដ្ឋកថាកែសេចក្តី ៨៤ សូត្រ

# អង្គុត្តរនិកាយ ចតុក្កនិបាត
# រួមមាន
## ១ បណ្ណាសកៈ និង ១២ វគ្គ
## ព្រះអដ្ឋកថាកែសេចក្តី ៨៤ សូត្រ

### ចតុត្ថបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ ឥន្ទ្រិយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ២ បដិបទាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៣ សញ្ចេតនាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៤ យោធាជីវវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៥ មហាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |

### វគ្គមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ សប្បុរិសវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៥ សូត្រ |
| ២ សោភនវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៥ សូត្រ |
| ៣ ទុច្ចរិតវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី | រួម |
| ៤ កម្មវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |
| ៥ អាបត្តិភយវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៧ សូត្រ |
| ៦ អភិញ្ញាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |
| ៧ កម្មបថវគ្គ | | អដ្ឋកថាកែសេចក្តី | រួម |
| រាគបេយ្យាល | | អដ្ឋកថាកែសេចក្តី | រួម |

# ស្រៈនិងសៀ់យ

## *Signes et accents:*



# ស្រៈពេញតួ

# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | . *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហល<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម<br>Romain | c | ch | j | jh | ñ |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទូវសេចក្ដី*

វែកញែក និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញុំាងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកបា្បដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់ វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរស របស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញុំាញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយ គ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែល ជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្ពាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហា សង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈ នោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យ ទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុថៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ិន

ឧបាសក កុំ ទួន

ឧបាសក ជីម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ុម វ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ដុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក ណាក់ម៉ៅ

ឧបាសក ហុកសីងហួត

ឧបាសក កើត ឌិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ិត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ុំថាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូវ | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មបញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ដុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡេះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ ទំព័រ

## ចតុក្កនិបាត ចតុត្ថបណ្ណាសកៈ

### ឥន្ទ្រិយវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា ឥន្ទ្រិយសូត្រ | ទី ១ | ១ |
| អដ្ឋកថា បឋមពលសូត្រ | ទី ២ | ២ |
| អដ្ឋកថា ទុតិយពលសូត្រ | ទី ៣ | ៣ |
| អដ្ឋកថា តតិយពលសូត្រ | ទី ៤ | ៤ |
| អដ្ឋកថា ចតុត្ថពលសូត្រ | ទី ៥ | ៥ |
| អដ្ឋកថា កប្បសូត្រ | ទី ៦ | ៦ |
| អដ្ឋកថា រោគសូត្រ | ទី ៧ | ៧ |
| អដ្ឋកថា បរិហានិសូត្រ | ទី ៨ | ៨ |
| អដ្ឋកថា ភិក្ខុនីសូត្រ | ទី ៩ | ៩ |
| អដ្ឋកថា សុគតសូត្រ | ទី ១០ | ១២ |


### បដិបទាវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា សង្ខិត្តសូត្រ | ទី ១ | ១៤ |
| អដ្ឋកថា វិត្ថារសូត្រ | ទី ២ | ១៥ |
| អដ្ឋកថា អសុភសូត្រ | ទី ៣ | ១៨ |
| អដ្ឋកថា បឋមខមសូត្រ | ទី ៤ | ២១ |
| អដ្ឋកថា ទុតិយខមសូត្រ | ទី ៥ | ២២ |
| អដ្ឋកថា ឧភយសូត្រ | ទី ៦ | ២៣ |
| អដ្ឋកថា មោគ្គល្លានសូត្រ | ទី ៧ | ២៤ |
| អដ្ឋកថា សារីបុត្តសូត្រ | ទី ៨ | ២៥ |
| អដ្ឋកថា សសង្ខារសូត្រ | ទី ៩ | ២៦ |
| អដ្ឋកថា យុគនទ្ធសូត្រ | ទី ១០ | ២៧ |

## សព្យោតនិយវគ្គ ទី ៣


| | | |
|---|---|---|
| អដ្ឋកថា ចេតនាសូត្រ | ទី ១ | ៣០ |
| អដ្ឋកថា វិភត្តិសូត្រ | ទី ២ | ៣៩ |
| អដ្ឋកថា កោដ្ឋិតសូត្រ | ទី ៣ | ៤១ |
| អដ្ឋកថា អានន្ទសូត្រ | ទី ៤ | ៤១ |
| អដ្ឋកថា ឧបវានសូត្រ | ទី ៥ | ៤៤ |
| អដ្ឋកថា អាយាចនសូត្រ | ទី ៦ | ៤៥ |
| អដ្ឋកថា រាហុលសូត្រ | ទី ៧ | ៤៦ |
| អដ្ឋកថា ជម្ពាលីសូត្រ | ទី ៨ | ៤៨ |
| អដ្ឋកថា និព្វានសូត្រ | ទី ៩ | ៥៥ |
| អដ្ឋកថា មហាបទេសសូត្រ | ទី ១០ | ៥៦ |


## យោធាជីវវគ្គ ទី ៤


| | | |
|---|---|---|
| អដ្ឋកថា យោធាសូត្រ | ទី ១ | ៦១ |
| អដ្ឋកថា ចាដិភោគសូត្រ | ទី ២ | ៦២ |
| អដ្ឋកថា សុតសូត្រ | ទី ៣ | ៦៣ |
| អដ្ឋកថា អភយសូត្រ | ទី ៤ | ៦៤ |
| អដ្ឋកថា ព្រាហ្មណ៍សច្ចសូត្រ | ទី ៥ | ៦៦ |
| អដ្ឋកថា ឧម្មគ្គសូត្រ | ទី ៦ | ៧០ |
| អដ្ឋកថា វស្សការសូត្រ | ទី ៧ | ៧២ |
| អដ្ឋកថា ឧបកសូត្រ | ទី ៨ | ៧៥ |
| អដ្ឋកថា សច្ឆិកិរិយសូត្រ | ទី ៩ | ៧៨ |
| អដ្ឋកថា ឧបោសថសូត្រ | ទី ១០ | ៧៩ |


## មហាវគ្គស្សវគ្គ ទី ៥


| | | |
|---|---|---|
| អដ្ឋកថា សោតានុគតសូត្រ | ទី ១ | ៨២ |
| អដ្ឋកថា ឋានសូត្រ | ទី ២ | ៨៦ |
| អដ្ឋកថា ភទ្ទិយសូត្រ | ទី ៣ | ៨៩ |
| អដ្ឋកថា សាបុគិយាសូត្រ | ទី ៣ | ៩១ |
| អដ្ឋកថា វប្បសូត្រ | ទី ៥ | ៩៤ |

| | | |
|---|---|---|
| អដ្ឋកថា សាឡ្ហសូត្រ | ទី ៦ | ១០៣ |
| អដ្ឋកថា មល្លិកាទេវីសូត្រ | ទី ៧ | ១០៧ |
| អដ្ឋកថា អត្តន្តបសូត្រ | ទី ៨ | ១១០ |
| អដ្ឋកថា តណ្ហាសូត្រ | ទី ៩ | ១៤៣ |
| អដ្ឋកថា បេមសូត្រ | ទី ១០ | ១៥០ |


## វគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ

### សប្បុរិសវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា សិក្ខាបទសូត្រ | ទី ១ | ១៥១ |
| អដ្ឋកថា អសទ្ធម្មសូត្រ | ទី ២ | ១៥២ |
| អដ្ឋកថា សត្តកម្មសូត្រ | ទី ៣ | ១៥៣ |
| អដ្ឋកថា ទសកម្មសូត្រ | ទី ៤ | ១៥៤ |
| អដ្ឋកថា អដ្ឋង្គិកសូត្រ | ទី ៥ | ១៥៥ |
| អដ្ឋកថា ទសមគ្គសូត្រ | ទី ៦ | ១៥៦ |
| អដ្ឋកថា បឋមបាបធម្មសូត្រ | ទី ៧ | ១៥៧ |
| អដ្ឋកថា ទុតិយបាបធម្មសូត្រ | ទី ៨ | ១៥៨ |
| អដ្ឋកថា តតិយបាបធម្មសូត្រ | ទី ៩ | ១៥៩ |
| អដ្ឋកថា ចតុត្ថបាបធម្មសូត្រ | ទី ១០ | ១៦០ |


### សោភនវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា បរិសាសូត្រ | ទី ១ | ១៦១ |
| អដ្ឋកថា ទិដ្ឋិសូត្រ | ទី ២ | ១៦២ |
| អដ្ឋកថា អកតញ្ញុតាសូត្រ | ទី ៣ | ១៦៣ |
| អដ្ឋកថា បាណាតិបាតសូត្រ | ទី ៤ | ១៦៤ |
| អដ្ឋកថា បឋមមគ្គសូត្រ | ទី ៥ | ១៦៥ |
| អដ្ឋកថា ទុតិយមគ្គសូត្រ | ទី ៦ | ១៦៦ |
| អដ្ឋកថា បឋមវោហារបថសូត្រ | ទី ៧ | ១៦៧ |
| អដ្ឋកថា សូត្រ | ទី ៨-៩-១០ | ១៦៨ |

**ទុច្ចរិតវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា ទុច្ចរិតវគ្គ | | ១៦៩ |

**កម្មវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សង្ខិត្តសូត្រ | ទី ១ | ១៧០ |
| អដ្ឋកថា វិត្ថារសូត្រ | ទី ២ | ១៧២ |
| អដ្ឋកថា សោណកាយនសូត្រ | ទី ៣ | ១៧៤ |
| អដ្ឋកថា សិក្ខាបទសូត្រ | ទី ៤ | ១៧៥ |
| អដ្ឋកថា សិក្ខាបទសូត្រ | ទី ៥ មិនមានអដ្ឋកថា | ១៧៦ |
| អដ្ឋកថា អរិយមគ្គសូត្រ | ទី ៦ មិនមានអដ្ឋកថា | ១៧៧ |
| អដ្ឋកថា ពោជ្ឈង្គសូត្រ | ទី ៧ មិនមានអដ្ឋកថា | ១៧៨ |
| អដ្ឋកថា សាវជ្ជសូត្រ | ទី ៨ មិនមានអដ្ឋកថា | ១៧៩ |
| អដ្ឋកថា អព្យាបជ្ឈសូត្រ | ទី ៩ មិនមានអដ្ឋកថា | ១៨០ |
| អដ្ឋកថា សមណសូត្រ | ទី ១០ | ១៨១ |
| អដ្ឋកថា សប្បុរិសានិសង្សសូត្រ | ទី ១១ មិនមានអដ្ឋកថា | ១៨៤ |

**អាបត្តិភយវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា សង្ឃភេទកសូត្រ | ទី ១ | ១៨៥ |
| អដ្ឋកថា អាបត្តិសូត្រ | ទី ២ | ១៨៧ |
| អដ្ឋកថា សិក្ខានិសង្សសូត្រ | ទី ៣ | ១៨៩ |
| អដ្ឋកថា សេយ្យសូត្រ | ទី ៤ | ១៩១ |
| អដ្ឋកថា ថូបារហសូត្រ | ទី ៥ | ១៩៣ |
| អដ្ឋកថា សូត្រ | ទី ៦-៧ មិនមានអដ្ឋកថា | ១៩៥ |
| អដ្ឋកថា បឋមវោហារសូត្រ | ទី ៨ | ១៩៦ |

**អភិញ្ញាវគ្គ ទី ៦**

| | | |
|---|---|---|
| អដ្ឋកថា អភិញ្ញាសូត្រ | ទី ១ | ២០០ |
| អដ្ឋកថា បរិយេសនាសូត្រ | ទី ២ | ២០១ |
| អដ្ឋកថា សង្គហសូត្រ | ទី ៣ មិនមានអដ្ឋកថា | ២០២ |
| អដ្ឋកថា មាលុង្ក្យបុត្តសូត្រ | ទី ៤ | ២០៣ |

| | | |
|---|---|---|
| អដ្ឋកថា កុលសូត្រ | ទី ៥ | ២០៥ |
| អដ្ឋកថា បឋមអាជានេយ្យសូត្រ | ទី ៧ | ២០៦ |

**កម្មបថវគ្គ ទី ៧**

| | | |
|---|---|---|
| អដ្ឋកថា កម្មបថវគ្គ | ទី ៧ | ២១១ |
| អដ្ឋកថា រាគបេយ្យាល | | ២១២ |

# អង្គុត្តរនិកាយ ចតុក្កនិបាត

## ចតុត្ថបណ្ណាសកៈ

## ឥន្ទ្រិយវគ្គវណ្ណនាទី ១

### អដ្ឋកថា ឥន្ទ្រិយសូត្រទី ១

*“ឥន្ទ្រិយ ៤ ប្រការ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥន្ទ្រិយសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា **សទ្ធិន្ទ្រិយំ** (សទ្ធិន្ទ្រិយ៍) ព្រោះធ្វើភាពជាធំក្នុងសទ្ធាធុរៈ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា ឥន្ទ្រិយសូត្រទី ១

# អដ្ឋកថា បឋមពលសូត្រទី ២

*"ពោលអំពីពលៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមពលសូត្រទី ១ ដូចតទៅនេះ ៖*

[២] *បទថា* ***សទ្ធាពលំ*** *(សទ្ធាពលំ) ព្រោះអត្ថថា មិនញាប់ញ័រក្នុងអស្សទ្ធិយៈ (ការមិនជឿ) ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។*

ចប់អដ្ឋកថា ពលសូត្រទី ២

# អដ្ឋកថា ទុតិយពលសូត្រទី ៣

## *“ពោលអំពីពលៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយពលសូត្រទី ៣ ដូចតទៅនេះ ៖*

[៣] *បទថា **អនវជ្ជពលំ** គឺ ពលៈ គឺ កម្មដែលមិនមានទោស ។ បទថា **សង្គាហកពលំ** បានដល់ ពលៈ គឺ ការសង្គ្រោះបុគ្គលដែលគួរសង្គ្រោះ ។*

ចប់អដ្ឋកថា ទុតិយពលសូត្រទី ៣

# អដ្ឋកថា តតិយពលសូត្រទី ៤

*“ពោលអំពីពលៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយពលសូត្រទី ៤ ដូចតទៅនេះ ៖*

[៤] *ក្នុងសូត្រនេះ មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា តតិយពលសូត្រទី ៤

# អដ្ឋកថា ចតុត្ថពលសូត្រទី ៥

*“ពោលអំពីពលៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចតុត្ថពលសូត្រទី ៥ ដូចតទៅនេះ ៖*

[៥] *ក្នុងសូត្រនេះ មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា តតិយពលសូត្រទី ៤

# អដ្ឋកថា កប្បសូត្រទី ៦

## *"ពោលដោយអសង្ខេយ្យនៃកប្ប"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កប្បសូត្រទី ៦ ដូចតទៅនេះ ៖*

*[៦] ក្នុងបទថា **សំវដ្ដា** (សំវដ្ដៈ) នេះ សេចក្ដីវិនាស ៣ គឺ សេចក្ដីវិនាសដោយទឹក ១ សេចក្ដីវិនាសដោយភ្លើង ១ សេចក្ដីវិនាសដោយខ្យល់ ១ ។ ខេត្តនៃសេចក្ដីវិនាស មាន ៣ គឺ អាភស្សរព្រហ្ម សុភកិណ្ហព្រហ្ម វេហប្ផលព្រហ្ម ។ ក្នុងគ្រាដែលកប្បវិនាសដោយភ្លើង ភ្លើងរមែងឆេះពីខាងក្រោមអាភស្សរាចុះមក ។ ក្នុងគ្រាដែលវិនាសដោយទឹក ទឹករមែងជន់លិចពីខាងក្រោមសុភកិណ្ហាចុះមក ។ ក្នុងគ្រាដែលវិនាសដោយខ្យល់ ខ្យល់រមែងទម្លាយពីខាងក្រោមវេហប្ផលាចុះមក ។ តែបើពោលដោយពិស្ដារ ពុទ្ធខេត្តមួយ រមែងវិនាសបានគ្រប់កាល ។ នេះជាសេចក្ដីសង្ខេបក្នុងទីនេះ ។ ចំណែកសេចក្ដីពិស្ដារ អ្នកសិក្សាគប្បីជ្រាបបានដោយន័យដែលពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គចុះ ។*

ចប់អដ្ឋកថា កប្បសូត្រទី ៦

# អដ្ឋកថា រោគសូត្រទី ៧

## *"រោគ ២ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រោគសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧] បទថា **វិឃាតវា** (មានសេចក្ដីចង្អៀតចង្អល់ចិត្ត) បានដល់ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ចិត្ត គឺ ទុក្ខ មានសេចក្ដីប្រាថ្នាច្រើនជាបច្ច័យ ។ បទថា **អសន្តុដ្ឋោ** (មិនសន្ដោស) បានដល់ ជាអ្នកមិនសន្ដោសដោយសន្ដោស ៣ យ៉ាង ក្នុងបច្ច័យ ៤ ។ បទថា **អនវញ្ញប្បដិលាភាយ** (ដើម្បីមិនឲ្យអ្នកដទៃមើលងាយ) បានដល់ ដើម្បីបាននូវការលើកតម្កើងពីអ្នកដទៃ ។ បទថា **លាភសក្ការសិលោកប្បដិលាភាយ** (ដើម្បីនឹងបានលាភសក្ការៈ និងសេចក្ដីសរសើរ) បានដល់ ដើម្បីបានលាភសក្ការៈ បានដល់ បច្ច័យ ៤ ដែលគេចាត់ចែងទុកជាយ៉ាងល្អ និងសេចក្ដីសរសើរ បានដល់ ការពោលលើកតម្កើង ។ បទថា **សង្ខាយ កុលានិ ឧបសង្កមតិ** (ចូលកាន់ត្រកូលដើម្បីឲ្យគេរាប់អាន) បានដល់ ចូលទៅកាន់ត្រកូលដើម្បីដឹងថា ជនទាំងនេះស្គាល់យើងទេ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។*

ចប់អដ្ឋកថា រោគសូត្រទី ៧

# អដ្ឋកថា បរិហានិសូត្រទី ៨

## *"ធម៌ជាហេតុនៃសេចក្ដីវិនាស"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិហានិសូត្រទី ៨ ដូចតទៅនេះ ៖*

[៨] *បទថា* ***គម្ភីរេសុ*** *(ជ្រាលជ្រៅ) បានដល់ ជ្រៅដោយអត្ថ ។ បទថា* ***ឋានាឋានេសុ*** *(ក្នុងឋានៈ និងអឋានៈ) បានដល់ ក្នុងហេតុ និងមិនមែនហេតុ ។ បទថា* ***ន គមតិ*** *(មិនឈានទៅ) បានដល់ មិននាំទៅ គឺមិនប្រព្រឹត្តទៅ ។ ក្នុងបទថា* ***បញ្ញាចក្ខុំ*** *(បញ្ញាចក្ខុ) នេះ សុម្បីបញ្ញាកើតពីការរៀន ការសាកសួរក៏គួរ សុម្បីបញ្ញាកើតពីការពិចារណា ការចាក់ធ្លុះក៏គួរ ។*

ចប់អដ្ឋកថា បរិហានិសូត្រទី ៨

# អដ្ឋកថា ភិក្ខុនីសូត្រទី ៩

## *"ភិក្ខុនីបញ្ជូនបុរសទៅរកព្រះអានន្ទ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុនីសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *បទថា* **ឯហិ ត្វំ** *(នែបុរសចូរមកអាយ) បានដល់ ភិក្ខុនីមានចិត្តប្រតិព័ទ្ធក្នុងព្រះថេរៈ ទើបពោលយ៉ាងនេះ ហើយបញ្ជូនបុរសនោះទៅ ។ បទថា* **សសីសំ បារុបិត្វា** *(ទទូរសីសៈ) បានដល់ ដណ្តប់កាយរហូតដល់ក្បាល ។ បទថា* **មញ្ចកេ និបជ្ជិ** *(ដេក... នៅលើគ្រែ) បានដល់ ភិក្ខុនីប្រញាប់ក្រាលកម្រាលហើយដេកលើគ្រែនោះ ។ បទថា* **ឯតទវោច** *សេចក្តីថា ព្រះអានន្ទសង្កេតអាការរបស់ភិក្ខុនីនោះ ទើបបានពោលនឹងភិក្ខុនីនោះ ដើម្បីសម្តែងអសុភកថា ឲ្យភិក្ខុនីលះសេចក្តីលោភ ។*

*បទថា* **អាហារសម្ភូតោ** *(កើតមកដោយអាហារ) បានដល់ រាងកាយនេះ កើតមកព្រោះអាហារ គឺ ចម្រើនឡើងព្រោះអាស្រ័យអាហារ ។ បទថា* **អាហារំ និស្សាយ អាហារំ បជហតិ** *(ក៏អាស្រ័យអាហារ លះអាហារចេញ) សេចក្តីថា បុគ្គលអាស្រ័យកវឡីការាហារដែលជាបច្ចុប្បន្ន សេពអាហារនោះដោយឧបាយយ៉ាងនេះ រមែងលះអាហារ ពោលគឺ កម្មចាស់ ។ គប្បីលះតណ្ហា ដែលជាសេចក្តីប្រាថ្នាក្នុងកវឡីការាហារសូម្បីដែល*

ជាបច្ចុប្បន្ន ។ បទថា **តណ្ហំ បជហតិ** (លះតណ្ហា) សេចក្តីថា បុគ្គល អាស្រ័យតណ្ហាដែលជាបច្ចុប្បន្ន ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ក្នុងឥឡូវ នេះ រមែងលះបុព្វតណ្ហាដែលមានវដ្តៈជាមូល ។ សួរថា ក៏តណ្ហាដែលជា បច្ចុប្បន្ននេះ ជាកុសល ឬអកុសល ។ ឆ្លើយថា ជាអកុសល ។ សួរថា គួរសេព ឬមិនគួរសេព ។ ឆ្លើយថា គួរសេព ។ សួរថា នឹងនាំបដិសន្ធិ មក ឬមិននាំមក ។ ឆ្លើយថា មិននាំមក ។ តែគួរលះសេចក្តីប្រាថ្នាក្នុង តណ្ហាដែលគួរសេព ដែលជាបច្ចុប្បន្ននេះចេញនោះឯង ។ បទថា **កិមង្គំ បន** (ក៏យើងជាអ្វីហ្ន៎) ក្នុងបទថា **សោ ហិ នាម អាយស្មា អាសវានំ ខយា ។បេ។ ឧបសម្បជ្ជ វិហរិស្សតិ កិមង្គំ បនាហំ** (ដែលបុគ្គលនោះ ធ្វើ ឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលរកអាសវៈមិនបាន ព្រោះ អស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯងសម្រេចហើយ ក្នុងបច្ចុប្បន្នបាន ក៏យើងជានរណាហ្ន៎) នេះ នោះជាបរិវិតក្កៈដល់ហេតុ ។ លោកអធិប្បាយប្រការនេះទុកថា ភិក្ខុនោះ នឹងធ្វើអរហត្តផលឲ្យជាក់ច្បាស់ ហើយ ព្រោះហេតុណា យើងនឹងមិនទាន់បានធ្វើឲ្យជាក់ច្បាស់ទេ សូម្បីភិក្ខុ នោះ ក៏ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ សូម្បីយើង ក៏ជាបុត្ររបស់ព្រះសម្មា-សម្ពុទ្ធដូចគ្នា អរហត្តផលនោះរមែងកើតដល់យើងខ្លះ ។

បទថា **មានំ និស្សាយ** (អាស្រ័យមានះ) បានដល់ អាស្រ័យមានះដែលគួរសេព ដែលកើតឡើងហើយយ៉ាងនេះ ។ បទថា **មានំ បជហតិ** (លះមានះចេញ) បានដល់ បុគ្គលលះបង់បុព្វមានះដែលមានវដ្ដៈជាមូល ។ អធិប្បាយថា ក៏បុគ្គលនោះអាស្រ័យមានះណា លះមានះនោះបាន សូម្បីមានះនោះក៏ជាអកុសល គួរសេព និងមិននាំបដិសន្ធិមក ដូចតណ្ហា តែគួរលះសេចក្តីប្រាថ្នាសូម្បីក្នុងមានះនោះចេញ ។ បទថា **សេតុឃាតោ វុត្តោ ភគវតា** (ព្រះមានព្រះភាគត្រាស់ទូន្មានឲ្យនាំស្ពានចេញ) សេចក្តីថា ព្រះមាន-ព្រះភាគទ្រង់ជាពុទ្ធៈ ត្រាស់ទូន្មានឲ្យទម្លាយផ្លូវ គឺ ទម្លាយបច្ច័យចេញ ។ កាលព្រះថេរៈប្រារព្ធទេសនាដោយអង្គ ៤ យ៉ាងនេះហើយ ឆន្ទរាគៈដែលប្រារព្ធព្រះថេរៈកើតឡើងដល់ភិក្ខុនីនោះ ក៏បានអស់ទៅ ។ សូម្បីភិក្ខុនីនោះក៏សូមទោសកំហុស ដើម្បីឲ្យព្រះថេរៈលើកទោសឲ្យ ។ ព្រះថេរៈក៏ទទួលអត់ទោសដល់ភិក្ខុនីនោះ ។ ដើម្បីសម្តែងដល់ប្រការនោះ លោកទើបពោលបទមានជាអាទិ៍ថា **អថខោ សា ភិក្ខុនី** (ពេលនោះ ភិក្ខុនីរូបនោះ) ដូច្នេះ ។

ចប់អដ្ឋកថា ភិក្ខុនីសូត្រទី ៩

# អដ្ឋកថា សុគតសូត្រទី ១០

## *“ព្រះសុគត និងវិន័យរបស់ព្រះសុគត”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុគតសូត្រទី ១០ ដូចតទៅនេះ ៖*

[១០] *បទថា* ***ទុគ្គហិតំ*** *(ដែលចាំមកមិនល្អ) បានដល់ ប្រកាន់ខុសតាមៗ គ្នាមក ។ បទថា* ***បរិយាបុណន្តិ*** *(រៀនសូត្រ) បានដល់ រៀនមកខុស ។ ក៏ក្នុងបទថា* ***បទព្យញ្ជនេហិ*** *(ដោយបទព្យញ្ជនៈ) នេះ លោកពោលថា បទនៃសេចក្តីទាំងឯង ជាព្យញ្ជនៈដោយព្យញ្ជនៈ ។ បទថា* ***ទុន្និក្ខិត្តស្ស*** *(ដែលរៀបរៀងខុសលំដាប់) បានដល់ ខុសលំដាប់ គឺ តាំងទុកក្រៅលំដាប់ ។ បទថា* ***អត្ថោបិ ទុន្នយោ ហោតិ*** *(សូម្បីអត្ថ... ក៏យកសេចក្តីមិនល្អ) បានដល់ មិនអាចនឹងនាំអដ្ឋកថាចេញមកពោលបាន ។ បទថា* ***ឆិន្នមូលកោ*** *(ក៏ដាច់មូល) ឈ្មោះថា* ***ដាច់មូល*** *ព្រោះដាច់កិច្ចដែលជាមូល (អាចារ្យ) ។ បទថា* ***អប្បដិសរណោ*** *(មិនមានទីអាស្រ័យបន្ត) គឺមិនមានទីពឹង ។ បទថា* ***ពាហុលិកា*** *(សន្សំបរិក្ខារ) បានដល់ បដិបត្តិដើម្បីសន្សំបច្ច័យ ។ បទថា* ***សាថលិកា*** *(បដិបត្តិបន្ធូរបន្ថយ) បានដល់ កាន់យកត្រៃសិក្ខាធូរថយ ។ បទថា* ***ឱក្កមនេ បុព្វង្គមា*** *(ជាអ្នកនាំទៅក្នុងឱក្កមនេ) នីវរណៈ ៥ លោកហៅថា* ***ឱក្កមនៈ*** *ព្រោះដើរចុះទៅកាន់ទីទាប*

*(វិនាស) អធិប្បាយថា ប្រាថ្នាទៅក្នុងឱក្កមនៈនោះ ។ បទថា* ***បវិវេក*** *បានដល់ វិវេក ៣ ។ បទថា* ***និក្ខិត្តធុរា*** *(ដាក់ធុរៈ) បានដល់ មិនមានសេចក្តីព្យាយាម ។ គប្បីជ្រាបសេចក្តីក្នុងទីទាំងពួងដោយន័យនេះ ។*

ចប់អដ្ឋកថា សុគតសូត្រទី ១០

## ចប់ឥន្ទ្រិយវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# បដិបទាវគ្គវណ្ណនាទី ២

## អដ្ឋកថា សង្ខិត្តសូត្រទី ១

*“បដិបទាដោយសង្ខេប”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខិត្តសូត្រទី ១ ដូចតទៅនេះ ៖*

[១១] *ឈ្មោះថា* ***ទុក្ខា*** *ព្រោះបដិសេធការបដិបត្តិស្រួល ។ ឈ្មោះថា* ***បដិបទា*** *ព្រោះគួរបដិបត្តិ ។ ឈ្មោះថា* ***ទន្ធាភិញ្ញា*** *ព្រោះមានការត្រាស់ដឹងយឺតយូរ ដោយភាពជារបស់ធ្ងន់ ព្រោះបដិបត្តិបានមិនរហ័ស ។ គប្បីជ្រាបសេចក្តីសូម្បីក្នុងបទទាំងពួង ដោយន័យនេះ ។*

ចប់អដ្ឋកថា សង្ខិត្តសូត្រទី ១

# អដ្ឋកថា វិត្ថារសូត្រទី ២

## *"បដិបទាដោយពិស្តារ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិត្ថារសូត្រទី ២ ដូចតទៅនេះ ៖*

*[១២] បទថា **អភិក្ខណំ** (រឿយៗ) បានដល់ ជានិច្ចកាល ។ បទថា **អនន្តរិយំ** (អនន្តរិយគុណ) បានដល់ មគ្គសមាធិដែលឲ្យផលជាលំដាប់តទៅ ។ បទថា **អាសវានំ ខយា** (ដើម្បីការអស់អាសវៈ) បានដល់ ដើម្បីអរហត្តផល ។ បទថា **បញ្ចិន្ទ្រិយានិ** (ឥន្ទ្រិយ ៥ ) បានដល់ ឥន្ទ្រិយ ៥ ប្រការ ដែលមានវិបស្សនាជាទី ៥ ។ ក៏ក្នុងបទថា **បញ្ញិន្ទ្រិយំ** (បញ្ញិន្ទ្រិយ) នេះ លោកបំណងយកវិបស្សនាបញ្ញាប៉ុណ្ណោះថា **បញ្ញិន្ទ្រិយ** ។ បទដ៏សេសក្នុងសូត្រនេះ ងាយនោះឯង ព្រោះត្រាស់ទុកក្នុងបាលីហើយ ។*

*ក៏កថាចែកបដិបទាទាំងនេះមានដូច្នេះ ។ ភិក្ខុក្នុងធម្មវិន័យនេះ មិនធ្លាប់បំពេញមកអំពីមុន រមែងលំបាកក្នុងឋានៈ ៣ ប្រការ គឺ ក្នុងខាងដើម រមែងលំបាកក្នុងការកំណត់រូប រមែងលំបាកក្នុងការកំណត់អរូប រមែងលំបាកក្នុងការកំណត់បច្ច័យ រមែងលំបាកក្នុងផ្លូវ និងមិនមែនផ្លូវ ភិក្ខុនោះលំបាកក្នុងឋានៈ ៥ យ៉ាងនេះ ទើបបានសម្រេចវិបស្សនា លុះសម្រេចវិបស្សនាហើយ ក៏លំបាកក្នុងវិបស្សនាញាណ ៩ ទាំងនេះ គឺ ក្នុងឧទយព្វយានុប-*

សន្នាញាណ (ប្រាជ្ញាឃើញទាំងការកើត និងការរលត់) ១ , ក្នុងភង្គានុបស្សនាញាណ (ប្រាជ្ញាឃើញការរលត់) ១ , ក្នុងភយតូបដ្ឋានញាណ (ប្រាជ្ញារំពឹងឃើញសង្ខារប្រាកដជារបស់គួរខ្លាច) ១ , ក្នុងអាទីនវានុបស្សនាញាណ (ប្រាជ្ញារំពឹងឃើញទោស) ១ , ក្នុងនិព្វិទានុបស្សនាញាណ (ប្រាជ្ញារំពឹងដល់សេចក្ដីនឿយណាយ) ១ , ក្នុងមុញ្ចិតុកម្យតាញាណ (ប្រាជ្ញារំពឹងដោយប្រាថ្នានឹងរួចផុត) ១ , ក្នុងសង្ខារុបេក្ខាញាណ (ប្រាជ្ញារំពឹងដោយសេចក្ដីព្រងើយក្នុងសង្ខារ) ១ , ក្នុងអនុលោមញាណ (ប្រាជ្ញារំពឹងដោយសមគួរដល់ការកំណត់ដឹងអរិយសច្ចៈ) ១ , ក្នុងគោត្រភូញាណ (ប្រាជ្ញាកំណត់ដឹងញាណដែលជាលំដាប់អរិយមគ្គ) ១ ហើយទើបសម្រេចលោកុត្តរមគ្គ លោកុត្តរមគ្គនោះរបស់ភិក្ខុនោះ ឈ្មោះថា បដិបត្តិលំបាក ទាំងត្រាស់ដឹងលំបាក ព្រោះធ្វើ ឲ្យជាក់ច្បាស់ដោយអាការធ្ងន់ ដោយទុក្ខយ៉ាងនេះ ។ ក៏ភិក្ខុណា ខាងដើមលំបាកក្នុងញាណ ៥ តែខាងចុងមិនលំបាកក្នុងវិបស្សនាញាណ ៩ រមែងធ្វើឲ្យច្បាស់នូវមគ្គ មគ្គនោះរបស់ភិក្ខុនោះឈ្មោះថា បដិបត្តិលំបាក តែត្រាស់ដឹងរហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់ដោយអាការមិនធ្ងន់ដោយទុក្ខយ៉ាងនេះ ។ ពីរបដិបទាទៀត ក៏គប្បីជ្រាបដោយឧបាយនេះ ។

ម្យ៉ាងទៀត បដិបទាទាំងនេះ នឹងគប្បីជាក់ច្បាស់ ដោយការឧបមា ប្រៀបធៀបដោយអ្នករកគោ ។ គោ ៤ ក្បាល របស់បុរសម្នាក់ដើរចូល ទៅក្នុងព្រៃ ។ គេរកគោទាំងនោះក្នុងព្រៃដែលមានបន្ទាក្រាស់ ផ្លូវដែល ទៅ ក៏ទៅដោយសេចក្តីលំបាក គោលាក់ខ្លួនទៅក្នុងព្រៃដែលក្រាស់ ដូច្នោះ ក៏ឃើញបានដោយលំបាក ។ បុរសម្នាក់ទៅដោយសេចក្តីលំបាក គោឈរ ក្នុងទីវាល ក៏ឃើញបានឆាប់រហ័ស ។ ម្នាក់ទៀត ទៅផ្លូវព្រៃដែលមិនស្តុក គោលាក់ខ្លួនទៅក្នុងព្រៃក្រាស់ ក៏ឃើញបានដោយលំបាក ។ ម្នាក់ទៀត ទៅដោយសប្បាយតាមផ្លូវវាលស្រឡះ គោក៏ឈរក្នុងទីវាលស្រឡះ និង ឃើញបានដោយឆាប់រហ័ស ។ ក្នុងការឧបមានោះ អរិយមគ្គ ៤ គប្បីឃើញ ដូចគោ ៤ ក្បាល , ព្រះយោគាវចរដូចជាបុរសស្វែងរកគោ , ការបដិបត្តិ លំបាកក្នុងខាងដើមរបស់ភិក្ខុដែលលំបាកក្នុងញាណ ៥ ដូចទៅផ្លូវព្រៃក្រាស់ ទៅបានដោយសេចក្តីលំបាក , ការឃើញអរិយមគ្គក្នុងខាងចុងរបស់បុគ្គល ដែលនឿយណាយក្នុងញាណ ៩ ដូចជាការឃើញគោដែលលាក់ខ្លួនទៅក្នុង ព្រៃក្រាស់បានដោយលំបាក ។ គប្បីប្រកបសូម្បីការឧបមាដ៏សេស ដោយ ឧបាយនេះ ។

ចប់អដ្ឋកថា វិត្ថារសូត្រទី ២

# អដ្ឋកថា អសុភសូត្រទី ៣

## *"ការពិចារណាឃើញថាមិនស្អាត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសុភសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣] *បទថា* ***អសុភានុបស្សី កាយេ វិហរតិ*** *(ពិចារណាឃើញសេចក្ដីមិនស្អាតក្នុងកាយ) សេចក្ដីថា ភិក្ខុពិចារណាឃើញសេចក្ដីមិនស្អាតក្នុងករជកាយរបស់ខ្លួន ដោយការចូលទៅប្រៀបធៀបជាមួយអសុភ ១០ ដែលខ្លួនឃើញហើយនៅខាងក្រៅ ដោយន័យនេះថា អសុភនោះយ៉ាងណា កាយនេះក៏ដូច្នោះ អធិប្បាយថា ឃើញកាយរបស់ខ្លួនដោយញាណ ថាជារបស់មិនស្អាត ជារបស់បដិកូល ។ បទថា* ***អាហារេ បដិកូលសញ្ញី*** *(មានការសម្គាល់ថាបដិកូលក្នុងអាហារ) សេចក្ដីថា មានសេចក្ដីសម្គាល់ថាជាបដិកូលក្នុងកវឡីការាហារ ដោយអំណាចបដិកូល ៩ យ៉ាង ។ បទថា* ***សព្វលោកេ អនភិរតសញ្ញី*** *(មានការសម្គាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង) សេចក្ដីថា ប្រកបដោយសេចក្ដីមិនគួរត្រេកអរ គឺ ដោយសញ្ញាថា គួរធុញទ្រាន់ ក្នុងលោកសន្និវាសដែលជាត្រៃធាតុសូម្បីទាំងអស់ ។ បទថា* ***សព្វសង្ខារេសុ អនិច្ចានុបស្សី*** *(ពិចារណាឃើញការមិនទៀងក្នុងសង្ខារទាំងពួង) សេចក្ដីថា ពិចារណាឃើញសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ*

៣ សូម្បីទាំងអស់ ថារបស់មិនទៀង ។ បទថា **មរណសញ្ញា** បានដល់សញ្ញាដែលកើតឡើងព្រោះប្រារព្ធសេចក្ដីស្លាប់ ។ បទថា **អជ្ឈត្តំ សុបដ្ឋិតា ហោតិ** (តាំង... ទុកយ៉ាងល្អនៅខាងក្នុង) បានដល់ ចូលទៅតាំងទុកដោយល្អខាងក្នុងកាយរបស់ខ្លួន ។ លោកពោលវិបស្សនាដែលមានកម្លាំង ដោយហេតុត្រឹមតែប៉ុណ្ណេះ ។ បទថា **សេក្ខពលានិ** (សេក្ខពលៈ) បានដល់កម្លាំងរបស់បុគ្គលដែលនៅសិក្សា ។ បទដ៏សេសក្នុងសូត្រនេះងាយហើយដោយអំណាចព្រះបាលី ។ ក៏បទថា **អសុភានុបស្សី** (ពិចារណាឃើញសេចក្ដីមិនស្អាត) ជាដើម លោកពោលដើម្បីសម្ដែងដល់បដិបទាលំបាកបឋមឈានជាដើម លោកពោលដើម្បីសម្ដែងបដិបទាងាយស្រួល ព្រោះថា អសុភជាដើម មានបដិកូលជាអារម្មណ៍ ។ ក៏តាមប្រក្រតី ចិត្តដែលស្រឡាញ់ រមែងជាប់នៅក្នុងអារម្មណ៍ទាំងនោះ ព្រោះដូច្នោះ កាលនឹងចម្រើនអសុភជាដើមទាំងនោះ ឈ្មោះថា បដិបត្តិបដិបទាលំបាក ។ បឋមឈានជាដើម ជាសុខប្រណីត ព្រោះដូច្នោះ អ្នកបដិបត្តិបឋមឈានជាដើមទាំងនោះ ឈ្មោះថា បដិបត្តិបដិបទាងាយស្រួល ។

ក្នុងប្រការនេះ មានឧបមាដែលជាសាធារណៈដូចតទៅនេះ ពិតហើយបុរសអ្នកចូលសង្គ្រាម ធ្វើស៊ីមក្ដារហើយទុកអាវុធ ៥ ប្រភេទ ទើបចូលកាន់

សង្គ្រាម គេបំណាំងនឹងសម្រាកក្នុងចន្លោះនោះ ទើបចូលទៅក្នុងស៊ុមក្លារ សម្រាក និងផឹកទឹក បរិភោគអាហារជាដើម បន្ទាប់ពីនោះ គេក៏ចូលកាន់សង្គ្រាម ធ្វើការច្បាំងតទៅ ។ ក្នុងការឧបមានោះ គប្បីឃើញថា ការធ្វើសង្គ្រាមជាមួយកិលេស ដូចចូលសង្គ្រាម កម្លាំងជាទីអាស្រ័យ ៥ ដូចស៊ុមក្លារ ព្រះយោគាវចរដូចបុរសចូលកាន់សង្គ្រាម ឥន្ទ្រិយ មានវិបស្សនាជាទី ៥ ដូចគ្រឿងអាវុធ ៥ ប្រភេទ វេលាចម្រើនវិបស្សនា ដូចវេលាចូលសង្គ្រាម វេលាដែលព្រះយោគាវចរចម្រើនវិបស្សនា ខណៈចិត្តុប្បាទមិនមាន សេចក្តីត្រេកអរ ព្រោះអាស្រ័យពលៈ ៥ លួងលោមចិត្តឲ្យរីករាយ ដូចវេលាដែលអ្នកច្បាំងប្រាថ្នានឹងសម្រាក ដោយចូលទៅក្នុងស៊ុមក្លារ វេលាដែលព្រះយោគាវចរញ៉ាំងចិត្តឲ្យរីករាយដោយពលៈ ៥ ហើយចម្រើនវិបស្សនាទៀត ក៏បែរត្រឡប់មកកាន់យកព្រះអរហត្តទុកបាន គប្បីជ្រាប ដូចវេលាដែលអ្នកច្បាំងសម្រាកស៊ីផឹកហើយ ត្រឡប់ចូលកាន់សង្គ្រាមតទៅ ។ ក៏ក្នុងសូត្រនេះទ្រង់ត្រាស់ពលៈ និងឥន្ទ្រិយលាយគ្នា ។

ចប់អដ្ឋកថា អសុភសូត្រទី ៣

# អដ្ឋកថា បឋមខមសូត្រទី ៤

## *"បដិបទានៃសេចក្តីអត់ធន់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមខមសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *បទថា* ***អក្ខមា*** *បានដល់ ការបដិបត្តិរបស់បុគ្គលមិនអត់ធន់ ។ បទថា* ***ខមា*** *បានដល់ ការបដិបត្តិរបស់បុគ្គលអត់ធន់ ។ បទថា* ***ទមា*** *បានដល់ ការបដិបត្តិរបស់បុគ្គលទូន្មានឥន្ទ្រិយ ។ បទថា* ***សមា*** *បានដល់ ការបដិបត្តិរបស់បុគ្គលស្ងប់អកុសលវិតក្កៈ ។ បទថា* ***រោសន្តំ បដិរោសតិ*** *(គេក្រោធក៏ក្រោធតប) បានដល់ គេខឹង រមែងខឹងតប ។ បទថា* ***ភណ្ឌន្តំ បដិភណ្ឌតិ*** *(គេវិវាទក៏វិវាទតប) បានដល់ គេប្រហារ រមែងប្រហារតប ។*

ចប់អដ្ឋកថា បឋមសូត្រទី ៤

# អដ្ឋកថា ទុតិយខមសូត្រទី ៥

*“បដិបទានៃសេចក្ដីអត់ធន់”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយខមសូត្រទី ៥ ដូចតទៅនេះ ៖*

[១៥] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ទុតិយខមសូត្រទី ៥

# អដ្ឋកថា ឧភយសូត្រទី ៦

*“បដិបទាដូចគ្នាទាំងពីរចំណែក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧភយសូត្រទី ៦ ដូចតទៅនេះ ៖*

[១៦] *ក្នុងសូត្រនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ឧភយសូត្រទី ៦

# អដ្ឋកថា មោគ្គល្លានសូត្រទី ៧

## *"បដិបទារបស់ព្រះមហាមោគ្គល្លាន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោគ្គល្លានសូត្រទី ៧ ដូចតទៅនេះ ៖*

[១៧] *មគ្គ ៣ ខាងក្រោម របស់ព្រះមហាមោគ្គល្លានត្ថេរ ជា* **សុខាបដិបទា ទន្ធាភិញ្ញា** *(បដិបត្តិស្រួលត្រាស់ដឹងយូរ) , អរហត្តមគ្គ ជា* **ទុក្ខាបដិបទា ខិប្បាភិញ្ញា** *(បដិបត្តិលំបាកត្រាស់ដឹងរហ័ស) ។ ព្រោះដូច្នោះ ព្រះមហាមោគ្គល្លាន ទើបពោលយ៉ាងនេះថា ចិត្តរបស់ខ្ញុំរួចផុតចាកអាសវៈទាំងឡាយហើយ មិនប្រកាន់មាំដោយឧបាទាន ព្រោះអាស្រ័យ* **ទុក្ខាបដិបទា ខិប្បាភិញ្ញា** *ដូច្នេះ ។*

ចប់អដ្ឋកថា មហាមោគ្គល្លានសូត្រទី ៧

# អដ្ឋកថា សារីបុត្តសូត្រទី ៨

## *"បដិបទារបស់ព្រះសារីបុត្ត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារីបុត្តសូត្រទី ៨ ដូចតទៅនេះ ៖*

[១៨] *មគ្គ ៣ ខាងក្រោម របស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរ ជា **សុខាបដិបទា ទន្ធាភិញ្ញា** (បដិបត្តិស្រួលត្រាស់ដឹងយូរ) , អរហត្តមគ្គ ជា **សុខាបដិបទា ខិប្បាភិញ្ញា** (បដិបត្តិស្រួលត្រាស់ដឹងរហ័ស) ។ ព្រោះដូច្នោះ ព្រះសារីបុត្ត ទើបពោលថា **យាយំ បដិបទា សុខា ខិប្បាភិញ្ញា** (សុខា-បដិបទា ខិប្បាភិញ្ញា) ដូច្នេះជាដើម ។ ក៏ក្នុងសូត្រនេះ គប្បីជ្រាបថា លោកបដិបទាលាយគ្នា ។*

ចប់អដ្ឋកថា សារីបុត្តសូត្រទី ៨

# អដ្ឋកថា សសង្ខារសូត្រទី ៩

## *“សសង្ខារបរិនិព្វាយីក្នុងបច្ចុប្បន្ន”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សសង្ខារសូត្រទី ៩ ដូចតទៅនេះ ៖*

[១៩] *បុគ្គលទី ១ ទី ២ ជាសុក្ខវិបស្សកៈ ញ៉ាំងសង្ខារនិមិត្តឲ្យប្រាកដដោយសេចក្ដីព្យាយាមជាកម្លាំង ។ ក្នុងបុគ្គលទាំងនោះ មួយរូបរមែងបរិនិព្វានដោយកិលេសបរិនិព្វានក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយ គឺវិបស្សនាមានកម្លាំង មួយរូបមិនបរិនិព្វានក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយមិនមានកម្លាំង បានចំពោះមូលកម្មដ្ឋាននោះប៉ុណ្ណោះ ក្នុងអត្តភាពលំដាប់ទៅ ធ្វើសង្ខារនិមិត្តឲ្យប្រាកដដោយសេចក្ដីព្យាយាមមានកម្លាំង ទើបបរិនិព្វានដោយកិលេសបរិនិព្វាន បុគ្គលទី ៣ ទី ៤ ជាសមថយានិក (សមថៈជាគ្រឿងនាំទៅ) ។ បណ្ដាបុគ្គលទាំងនោះ គប្បីជ្រាបថា បុគ្គលមួយរូប ធ្វើកិលេសឲ្យអស់ទៅក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយមានកម្លាំង ដោយមិនត្រូវប្រើសេចក្ដីព្យាយាមខ្លាំងក្លា មួយរូបមិនបានធ្វើកិលេសឲ្យអស់ទៅក្នុងអត្តភាពនេះ ព្រោះឥន្ទ្រិយមិនមានកម្លាំង បានតែមូលកម្មដ្ឋាននោះប៉ុណ្ណោះ ក្នុងអត្តភាពលំដាប់ទៅ ធ្វើកិលេសឲ្យអស់ទៅដោយមិនត្រូវប្រើសេចក្ដីព្យាយាមខ្លាំងក្លា ។*

ចប់អដ្ឋកថា សង្ខារសូត្រទី ៩

# អដ្ឋកថា យុគនទ្ធសូត្រទី ១០

## *"ការចម្រើនសមថៈ និងវិបស្សនាជាគូគ្នា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យុគនទ្ធសូត្រទី ១០ ដូចតទៅនេះ ៖*

[២០] *បទថា* ***សមថបុព្វង្គមំ*** *(មានសមថៈនាំមុខ) បានដល់ ធ្វើសមថៈទៅខាងមុខ គឺ ឲ្យជាបុរេចារិក ។ បទថា* ***មគ្គោ សញ្ជាយតិ*** *(មគ្គរមែងកើតឡើង) បានដល់ លោកុត្តរមគ្គទី ១ រមែងកើតឡើង ។ បទថា* ***សោ តំ មគ្គំ*** *(លោក... នូវមគ្គនោះ) សេចក្តីថា ឈ្មោះថា អាសេវនៈជាដើម មិនមានដល់មគ្គដែលប្រព្រឹត្តទៅក្នុងខណៈចិត្តតែមួយ ។ តែកាលញ៉ាំងមគ្គទី ២ ឲ្យកើតឡើង លោកពោលថា "លោកសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ" នោះឯង ។ បទថា* ***វិបស្សនា បុព្វង្គមំ*** *(មានវិបស្សនានាំមុខ) បានដល់ ធ្វើវិបស្សនាទៅខាងមុខ គឺ ឲ្យជាបុរេចារិក ។ បទថា* ***សមថំ ភាវេតិ*** *(បំពេញសមថៈ) សេចក្តីថា ដោយប្រក្រតីបុគ្គលបានវិបស្សនា តាំងនៅក្នុងវិបស្សនា រមែងញ៉ាំងសមាធិឲ្យកើតឡើង ។*

*បទថា* ***យុគនទ្ធំ ភាវេតិ*** *(បំពេញ... ជាគូគ្នាទៅ) បានដល់ ចម្រើនធ្វើឲ្យជាគូជាប់គ្នា ។ ក្នុងសេចក្តីនោះ ភិក្ខុមិនអាចនឹងប្រើចិត្តដួងនោះ ចូលសមាបត្តិ ហើយប្រើចិត្តដួងនោះឯងពិចារណាសង្ខារបានឡើយ ។ តែភិក្ខុ*

នេះចូលសមាបត្តិត្រឹមណា រមែងពិចារណាសង្ខារត្រឹមនោះ ពិចារណាសង្ខារត្រឹមណា រមែងចូលដល់សមាបត្តិត្រឹមនោះ ។ សួរថា ដូចម្តេច ។ ឆ្លើយថា ភិក្ខុចូលបឋមឈាន លុះចេញពីបឋមឈានហើយ ពិចារណាសង្ខារទាំងឡាយ លុះពិចារណាសង្ខារទាំងឡាយហើយ ចូលទុតិយឈាន ។ល។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ លុះចេញចាកនេវសញ្ញានាសញ្ញាយ-តនសមាបត្តិហើយ ពិចារណាសង្ខារទាំងឡាយ ដោយអាការយ៉ាងនេះ ភិក្ខុនេះ ឈ្មោះថា ចម្រើនបឋមវិបស្សនាជាគូជាប់គ្នា ។ បទថា **ធម្មុទ្ធច្ច-វិគ្គហិតំ** (មានឧទ្ធច្ចៈក្នុងធម៌ពាំង) សេចក្តីថា ឧទ្ធច្ចៈ បានដល់ វិបស្សនូ-បក្កិលេស ១០ ក្នុងធម៌ គឺ សមថៈ និងវិបស្សនាក្តួចកាន់ហើយ គឺ ក្តួចកាន់ល្អហើយ ។ ដោយបទថា **សោ អាវុសោ សមយោ** (ក្នុងសម័យ) នេះ លោកពោលដល់កាលដែលបានសប្បាយ ៧ ។ បទថា **យន្តំ ចិត្តំ** (ដែលចិត្ត) បានដល់ ចិត្តដែលឈានចុះកាន់វិថីនៃវិបស្សនា ក្នុងសម័យណាប្រព្រឹត្តទៅហើយ ។ បទថា **អជ្ឈត្តំយេវ សន្តិដ្ឋតិ** (តាំងមាំ... នៅខាងក្នុង) សេចក្តីថា ចិត្តឈានចុះកាន់វិថីនៃវិបស្សនាហើយ ឈប់ក្នុងអារម្មណ៍ បានដល់ អារម្មណ៍ខាងក្នុងនោះឯង ។ បទថា **សន្និសីទតិ** (ឈប់ស្ងៀម) បានដល់ ស្ងៀមដោយប្រពៃ ដោយអំណាចនៃអារម្មណ៍ ។ បទថា **ឯកោទិ ហោតិ**

*បានដល់ ចិត្តមានអារម្មណ៍តែមួយ ។ បទថា* ***សមាធិយតិ*** *(ជាសមាធិ) បានដល់ ចិត្តតាំងមាំដោយប្រពៃ គឺ តម្កល់ល្អហើយ ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា យុគនទ្ធសូត្រទី ១០

## ចប់បដិបទាវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# សញ្ចេតនិយវគ្គវណ្ណនាទី ៣

## អដ្ឋកថា ចេតនាសូត្រទី ១

*“ពោលដោយចេតនា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចេតនាសូត្រទី ១ ដូចតទៅនេះ ៖*

*[២១] បទថា **កាយេ** (កាលកាយ) បានដល់ កាលកាយទ្វារ អធិប្បាយថា កាលបើការកម្រើកផ្លូវកាយមាន ។ ក្នុងបទថា **កាយសញ្ចេតនាហេតុ** (ព្រោះកាយសញ្ចេតនាជាហេតុ) ជាដើម សេចក្តីសម្រេចនៃចេតនាក្នុងកាយទ្វារ ឈ្មោះថា **កាយសញ្ចេតនា** (ការតាំងចិត្តធ្វើផ្លូវកាយ) កាយសញ្ចេតនានោះ មាន ២០ យ៉ាង គឺ កាមាវចរកុសល ៨ យ៉ាង អកុសល ១២ យ៉ាង ។ **វចីសញ្ចេតនា** (ការតាំងចិត្តធ្វើផ្លូវវាចា) ក៏ដូចគ្នា ។ **មនោសញ្ចេតនា** (ការតាំងចិត្តធ្វើផ្លូវចិត្ត) ក៏ដូចគ្នា ។ ម្យ៉ាងទៀត សូម្បីមហគ្គតចេតនា ៩ ក៏បានក្នុងបទនេះ ។ បទថា **ព្រោះកាយសញ្ចេតនាហេតុ** បានដល់ ព្រោះកាយសញ្ចេតនាជាបច្ច័យ ។ បទថា **ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ** (សុខទុក្ខដែលជាខាងក្នុងរមែងកើតឡើង) បានដល់ សុខកើតឡើងខាងក្នុងខ្លួនព្រោះកុសលកម្ម ៨ ជាបច្ច័យ ទុក្ខកើតឡើងព្រោះអកុសលកម្ម ១២ ជាបច្ច័យ ។ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា*

**អវិជ្ជាបច្ចយា** (ព្រោះអវិជ្ជាជាបច្ច័យ) បានដល់ ព្រោះអវិជ្ជាជាហេតុ ។ ពិតណាស់ កាលអវិជ្ជាដែលបិទបាំងជាបច្ច័យហើយ ដូច្នោះ ចេតនាដែលជាបច្ច័យនៃសុខ និងទុក្ខក្នុងទ្វារ ៣ រមែងកើតឡើង ។ នេះទ្រង់ត្រាស់ដោយអំណាចអវិជ្ជាដែលជាមូល ដោយប្រការដូច្នេះ ។

ក្នុងបទថា **សាមំ វា** (ដោយខ្លួនឯងខ្លះ) ជាដើម បុគ្គលដទៃមិនបានប្រើ កាលតាក់តែងដោយខ្លួនឯង ឈ្មោះថា **តាក់តែងកាយសង្ខារឯង** ។ បបួលអ្នកដទៃឲ្យតាក់តែងកាយសង្ខារណា អ្នកដទៃ ឈ្មោះថា **តាក់តែងកាយសង្ខារនោះរបស់គេ** ។ ក៏បុគ្គលណាដឹងកុសលថា ជាកុសល ដឹងអកុសលថា ជាអកុសល ដឹងកុសលវិបាកថា ជាកុសលវិបាក ដឹងអកុសលវិបាកថា ជាអកុសលវិបាក រមែងតាក់តែងសង្ខារ ២០ យ៉ាង ក្នុងកាយទ្វារ បុគ្គលនេះឈ្មោះថា **ដឹងនូវការតាក់តែងសង្ខារ** បុគ្គលណាមិនដឹងយ៉ាងនេះ បុគ្គលនេះឈ្មោះថា **មិនដឹងនូវការតាក់តែងសង្ខារ** ។ សូម្បីក្នុងទ្វារដ៏សេស ក៏ន័យនេះដូចគ្នា ។

ក្នុងសេចក្តីនោះ គប្បីជ្រាបការធ្វើដោយមិនដឹងតួដូច្នេះ ។ ពួកកុមារតូចៗ គិតថា យើងនឹងធ្វើកិច្ចដែលមាតាបិតាធ្វើហើយ ទើបថ្វាយបង្គំចេតិយបូជាដោយផ្កា ថ្វាយបង្គំពួកភិក្ខុសង្ឃ សូម្បីទាំងគេមិនដឹងថាជាកុសល ការ

ធ្វើនោះក៏ជាកុសលនោះឯង ។ សត្វតិរច្ឆាន មានម្រឹគ និងបក្សីជាដើម ក៏ដូចគ្នា ស្តាប់ធម៌ ថ្វាយបង្គំព្រះសង្ឃ ថ្វាយបង្គំព្រះចេតិយ ទាំងដែលវាដឹងខ្លះ មិនដឹងខ្លះ ការធ្វើនោះក៏ជាកុសលដូចគ្នា ។ តែពួកកុមារតូចៗយកដៃ និងជើងទាត់វាយមាតាបិតា លើកដៃកំញើញ ចោលដុំដី ជេរមេគោដេញដល់ពួកភិក្ខុ ពួកសុនខដេញខាំ សីហៈ និងខ្លាដំបងជាដើម ដេញតាមសម្លាប់ ទាំងដែលវាដឹងខ្លះមិនដឹងខ្លះ គប្បីជ្រាបថា ជាអកុសលកម្ម ។

ឥឡូវនេះ គប្បីជ្រាបការរួមចេតនាដែលប្រមូលចុះក្នុងទ្វារទាំង ៣ ។ សួរថា ដូចម្តេច ។ ឆ្លើយថា ក្នុងកាយទ្វារ ចេតនាដែលធ្វើដោយខ្លួនឯងជាមូល ២០ ដែលបុគ្គលដទៃប្រើជាមូល ២០ ដែលដឹងខ្លួនជាមូល ២០ ដែលមិនដឹងខ្លួនជាមូល ២០ រួមជាចេតនា ៨០ ។ ក្នុងវចីទ្វារក៏ដូចគ្នា ។ តែក្នុងមនោទ្វារ វិកប្ប (ការគិត) មួយៗ វិកប្បមួយមាន ២៩ (៤ វិកប្ប) រួមជា ១១៦ ។ ដូច្នោះ ចេតនាសូម្បីទាំងអស់ក្នុងទ្វារ ៣ មាន ២៧៦ ចេតនាទាំងអស់នោះ រមែងរាប់បានថា ជាសង្ខារក្ខន្ធនោះឯង ការសោយអារម្មណ៍សម្បយុត្តដោយសង្ខារក្ខន្ធនោះ ជាវេទនាខន្ធ អាការចាំជាសញ្ញា-ខន្ធ ចិត្តជាវិញ្ញាណក្ខន្ធ កាយជាឧបាទារូប ធាតុ ៤ ដែលជាបច្ច័យនៃឧបា-ទារូប ជាភូតរូប ៤ ខន្ធ ៥ ដូចពោលមកទាំងនេះ ឈ្មោះថា ទុក្ខសច្ចៈ ។

បទថា **ឥមេសុ ភិក្ខវេ ធម្មេសុ អវិជ្ជា អនុបតិតា** (អវិជ្ជារមែងជាប់តាមទៅក្នុងធម៌ទាំងនេះ) សេចក្តីថា អវិជ្ជាធ្លាក់ទៅហើយក្នុងចេតនាធម៌ មានប្រភេទដូចពោលហើយទាំងនេះ ដោយអំណាចសហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ជាការដែលទ្រង់សម្តែងដល់វដ្ដៈ និងអវិជ្ជាដែលជាមូលនៃវដ្ដៈ ដោយអាការយ៉ាងនេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សរសើរព្រះខីណាស្រព ដែលចម្រើនវិបស្សនាដោយហេតុត្រឹមតែប៉ុណ្ណោះ ហើយសម្រេចព្រះអរហត្ត ទើបត្រាស់ថា **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា** (ព្រោះអវិជ្ជារលត់មិនមានសេសសល់) ដូច្នេះជាអាទិ ។ ក្នុងបទទាំងនោះ បទថា **អសេសវិរាគនិរោធា** (រលត់អស់មិនមានសេសសល់) បានដល់ វិនាសមិនសេសសល់ និងរលត់ដោយមិនសេសសល់ ។

បទថា **សោ កាយោ ន ហោតិ** (កាយ... នោះរមែងមិនមាន) សេចក្តីថា ការធ្វើផ្លូវកាយរបស់ព្រះខីណាស្រព រមែងប្រាកដជាដើម យ៉ាងនេះគឺ ការបោសលានព្រះចេតិយ ការបោសលានព្រះពោធិ៍ ការឈានទៅ និងការថយត្រឡប់ ការធ្វើវត្តបដិបត្តិ ។ តែក្នុងកាយទ្វារ ចេតនា ២០ របស់ព្រះខីណាស្រពនោះ រមែងជាកិច្ចតែមិនមានវិបាកជាធម្មតា ។ ដោយហេតុនោះ

លោកទើបពោលថា **សោ កាយោ ន ហោតិ យម្បច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ** (កាយដែលជាបច្ច័យឲ្យសុខទុក្ខខាងក្នុងនោះកើតឡើងដល់បុគ្គលនោះ រមែងមិនមាន) ចេតនាដែលប្រព្រឹត្តទៅក្នុងផ្លូវកាយទ្វារ លោកបំណងថា កាយ ក្នុងទីនេះ ។ ក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។ សូម្បីបទមានជាអាទិ៍ថា **ខេត្តំ** (ខេត្ត) ក៏ជាឈ្មោះរបស់កម្ម ទាំងជាកុសល និងអកុសលទុំះឯង ។ ពិតហើយ សុខ និងទុក្ខនោះ លោកពោលថា ឈ្មោះថា ខេត្ត ព្រោះអត្ថថា ជាទីដុះនៃវិបាក ឈ្មោះថា **វត្ថុ** ព្រោះអត្ថថា ជាទីតាំង ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាហេតុ ឈ្មោះថា **អធិករណ** ព្រោះអត្ថថា ជារឿងរ៉ាវ ។

ព្រះសាស្តា គ្រាទ្រង់សម្តែងកម្មដែលប្រមូលមក ដោយទ្វារ ៣ ដោយឋានៈ ប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងដល់ឋានៈ ដែលជាផលរបស់កម្មនោះ ទើបត្រាស់ថា **ចត្តារោមេ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ... នេះ) ដូច្នេះ ជាអាទិ៍ ។ ក្នុងបទនោះ បទថា **អត្តភាវប្បដិលាភា** (ការបានអត្តភាព) បានដល់ អត្តភាពដែលខ្លួនបានហើយ ។ បទថា **អត្តសញ្ចេតនា កមតិ** (សញ្ចេតនារបស់ខ្លួននាំទៅ) បានដល់ ចេតនាដែលខ្លួនត្រិះរិះទុក រមែងនាំទៅ គឺ រមែងប្រព្រឹត្តទៅ ។ ក្នុងបទមានជាអាទិ៍ថា **អត្តសញ្ចេត-**

នាហេតុ តេសំ សត្តានំ តម្ហា កាយា ចុតិ ហោតិ (ការចុតិចាកអត្តភាព នោះនៃពួកសត្វរមែងមាន ព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ) បានដល់ ពួកទេវតាដែលជាខិឌ្ឌាបទោសិកៈ (ប្រាថ្នាតែនឹងលេង) រមែងចុតិ ព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ ។ ព្រោះថា កាលពួកទេវតាទាំងនោះ ជាប់ចិត្តក្នុងរបស់ទិព្វក្នុងសួននន្ទវ័ន ចិត្តលតាវ័ន និងបារុសកវ័នជាដើម ហត់នឿយភ្លេចផឹក និងបរិភោគ ។ គេរមែងចុតិទៅ ព្រោះអត់អាហារ ដូចផ្កាឈើដែលស្ថិតក្នុងកំដៅថ្ងៃ ។

មនោបទោសិកា (ពួកទេវតាអ្នកក្រោធ) រមែងចុតិ ព្រោះសញ្ចេតនារបស់អ្នកដទៃជាហេតុ បានដល់ ពួកទេវតាជាន់ចាតុម្មហារាជិកា ។ បានឮថា បណ្តាពួកទេវតាទាំងនោះ ទេវបុត្រមួយអង្គបំណងនឹងលេងនក្ខត្តឫក្ស ទើបព្រមទាំងបរិវារ ឡើងរថទៅតាមផ្លូវ ទីនោះទេវបុត្រមួយអង្គទៀតចេញទៅ ឃើញទេវបុត្រនោះកំពុងទៅខាងមុខ ទើបក្រោធថា "អ្វីហ្ន៎ គ្នាយើងអ្នកសូមទាននេះ ឃើញទេវបុត្រមួយអង្គ ធ្វើដូចជាមិនធ្លាប់ឃើញ" ហើយជំឡើងមានះក្រអឺតក្រទមទៅតាមថ្នល់ ។ ទេវបុត្រដើរទៅខាងមុខ ក្រឡេកមើលឃើញទេវបុត្រនោះក្រោធ គិតថា ដែលឈ្មោះថា អ្នកក្រោធដឹងបានឆាយ លុះដឹងថា ទេវបុត្រនោះក្រោធហើយ ទើបក្រោធតបថា លោកក្រោធ

នឹងធ្វើអ្វីយើងបាន យើងបានសម្បត្តិនេះមក ដោយអំណាចទាន និងសីល ជាដើម មិនមែនបានមកដោយអំណាចរបស់លោក ក៏កាលទេវបុត្រមួយអង្គក្រោធ មួយអង្គទៀតមិនក្រោធ នៅរក្សាបាន តែកាលក្រោធទាំងសងខាង សេចក្ដីក្រោធរបស់ទេវបុត្រមួយអង្គជាបច្ច័យដល់មួយអង្គទៀត សេចក្ដីក្រោធរបស់ទេវបុត្រអង្គនោះ ក៏ជាបច្ច័យដល់ទេវបុត្រមួយអង្គទៀត ព្រោះដូច្នោះ ទេវបុត្រទាំងពីរអង្គរមែងចុតិ ទាំងដែលទេពអប្សរក៏ទួញយំ ។

មនុស្សទាំងឡាយ រមែងចុតិព្រោះសញ្ចេតនារបស់ខ្លួន និងសញ្ចេតនារបស់អ្នកដទៃជាហេតុ អធិប្បាយថា មនុស្សទាំងឡាយ រមែងចុតិ ព្រោះហេតុនៃសញ្ចេតនារបស់ខ្លួន និងនៃសញ្ចេតនារបស់អ្នកដទៃ ។ ពិតហើយមនុស្សទាំងឡាយ កាលបើក្រោធហើយ ក៏យកដៃខ្លះ ជើងខ្លះ វាយតប់ខ្លួនដោយខ្លួនឯង ចងដោយគ្រឿងចង គឺ ខ្សែជាដើមខ្លះ កាត់សីសៈដោយដាវខ្លះ ផឹកថ្នាំពិសខ្លះ រមែងលោតជ្រោះខ្លះ លោតទឹកខ្លះ ចូលគំនរភ្លើងខ្លះ យកកំណាត់ឈើជាសស្ត្រាប្រហារអ្នកដទៃឲ្យស្លាប់ខ្លះ ។ សញ្ចេតនារបស់ខ្លួនក្ដី សញ្ចេតនារបស់អ្នកដទៃក្ដី រមែងប្រព្រឹត្តទៅក្នុងពួកមនុស្សទាំងនោះដោយអាការយ៉ាងនេះ ។

បទថា កតមេ តេន ទេវា ទដ្ឋព្វា (បានដល់ទេវតាពួកណា) សេចក្ដី

ថា នឹងគប្បីឃើញពួកទេវតាទាំងនោះដូចម្ដេច ឬសេចក្ដីថា នឹងគប្បីឃើញពួកទេវតាដោយអត្តភាពនោះ ដូចម្ដេច ដូច្នេះខ្លះ ។ សួរថា ព្រោះអ្វីព្រះថេរៈទើបសួរបញ្ហានេះ ការពោលអំពីខ្លួនឯងមិនទាន់ល្មមឬ ។ ឆ្លើយថា មិនទាន់ល្មម ។ ក៏បទនេះ ជាបញ្ហាពុទ្ធវិស័យដោយសភាវៈរបស់បញ្ហា ព្រោះហេតុនោះ ព្រះថេរៈទើបមិនពោល ។ បទថា **តេន ទដ្ឋព្វា** (បានដល់) បានដល់ គប្បីឃើញដោយអត្តភាពនោះ ។ ក៏បញ្ហានេះ រមែងបានក្នុងកាមាវចរៈខ្លះ រូបាវចរៈខ្លះក្នុងជាន់ក្រោម តែត្រាស់កំណត់ដោយកវគ្គព្រហ្មក៏ជាការត្រាស់ដោយអស់ជើង ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។ បទថា **អាគន្តារោ ឥត្ថត្តំ** (មកកាន់ភាពយ៉ាងនេះ) បានដល់ជាអ្នកត្រឡប់មកកាន់សភាពយ៉ាងនេះ គឺ កាន់សភាពជាកាមាវចរៈ និងបញ្ចក្ខន្ធទាំងឯង មិនបានកើតក្នុងភពនោះ មិនបានកើតក្នុងភពខាងលើ ។ បទថា **អនាគន្តារោ ឥត្ថត្តំ** (មិនមកកាន់សភាពយ៉ាងនេះ) បានដល់ ជាអ្នកមិនត្រឡប់មកកាន់ខន្ធបញ្ចកៈនេះ គឺ ជាអ្នកមិនមកកើតក្នុងខាងក្រោម អធិប្បាយថា ជាអ្នកកើតក្នុងភពនោះខ្លះ ជាអ្នកកើតក្នុងភពខាងលើខ្លះ ជាអ្នកបរិនិព្វានក្នុងភពនោះឯងខ្លះ ។ ក្នុងបទនេះគប្បីជ្រាប សត្វដែលកើតក្នុងភពខាងលើ សូម្បីដោយអំណាចសត្វទាំងឡាយដែលកើតហើយក្នុងភពជាន់

*ក្រោម ។ ក៏បញ្ចក្ខន្ធនេះ មិនមានក្នុងភវគ្គព្រហ្ម ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយហើយ ។*

ចប់អដ្ឋកថា ចេតនាសូត្រទី ១

# អដ្ឋកថា វិភត្តិសូត្រទី ២

## *“ព្រះសារីបុត្តចែកបដិសម្ភិទា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិភត្តិសូត្រទី ២ ដូចតទៅនេះ ៖*

[២២] *បទថា* ***អត្ថប្បដិសម្ភិទា*** *បានដល់ ញាណដែលបែកធ្លាយក្នុងអត្ថទាំងឡាយ ៥ ។ បទថា* ***ឱធិសោ*** *(ដោយចំណែក) គឺ ដោយហេតុ ។ បទថា* ***ព្យញ្ជនសោ*** *(ដោយព្យញ្ជនៈ) គឺ ដោយអក្សរ ។ បទថា* ***អនេកបរិយាយេន*** *គឺ ដោយហេតុច្រើនយ៉ាង ។ បទថា* ***អាចិក្ខាមិ*** *គឺ និងពោល ។ បទថា* ***ទេសេមិ*** *(សម្តែង) គឺ ប្រាប់ ពោលធ្វើឲ្យប្រាកដ ។ បទថា* ***បញ្ញាបេមិ*** *(បញ្ញត្តិ) គឺ ធ្វើឲ្យយល់ច្បាស់ ។ បទថា* ***បដ្ឋបេមិ*** *(កំណត់) គឺ តាំងផ្តើមឡើង ។ បទថា* ***វិវរាមិ*** *(បើក) គឺ បង្ហាញ ។ បទថា* ***វិភជាមិ*** *(ចែក) គឺ ចែកប្រាប់ ។ បទថា* ***ឧត្តានីករោមិ*** *(ធ្វើឲ្យងាយ) គឺ ប្រាប់សេចក្តីដែលជ្រាលជ្រៅឲ្យរាក់ ។ បទថា* ***សោ មំ បញ្ហេន*** *(សូមសួរខ្ញុំ) បានដល់ លោកចូរចូលមកសួរបញ្ហានឹងខ្ញុំចុះ ។ បទថា* ***អហំ វេយ្យាករណេន*** *(ខ្ញុំពេញចិត្តនឹងឆ្លើយ) បានដល់ ខ្ញុំនឹងញ៉ាំងចិត្តរបស់លោកឲ្យត្រេកអរដោយការដោះស្រាយបញ្ហា ។ បទថា* ***យោ នោ ធម្មានំ សុកុសលោ*** *(របស់យើងទាំងឡាយ ទ្រង់ឆ្លៀវឆ្លាសក្នុងធម៌ទាំងឡាយ) សេចក្តីថា ព្រះ*

សាស្តាទ្រង់ទ្រៀវឆ្លាសក្នុងធម៌ដែលទ្រង់ត្រាស់ដឹងហើយ ព្រះអង្គប្រថាប់គង់ចំពោះមុខយើង ប្រសិនបើអត្ថប្បដិសម្ភិទា យើងមិនអាចធ្វើឲ្យច្បាស់បាន ព្រះអង្គនឹងត្រាស់ថា "ម្នាលសារីបុត្រ អ្នកចូរធ្វើឲ្យជាក់ច្បាស់ចុះ" ព្រះអង្គប្រាកដជានឹងហាម ។ ព្រោះហេតុនោះ ព្រះសារីបុត្រគង់បន្លឺសីហនាទចំពោះព្រះភក្ត្រព្រះសាស្តានោះឯង ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងអស់ ដោយឧបាយនេះ ។ ក៏ក្នុងបដិសម្ភិទាទាំងនេះ បដិសម្ភិទា ៣ ជាលោកិយៈ អត្ថប្បដិសម្ភិទា ជាលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា វិភត្តិសូត្រទី ២

# អដ្ឋកថា កោដ្ឋិត និងអានន្ទសូត្រទី ៣-៤

## *“ព្រះកោដ្ឋិតៈ និងព្រះអានន្ទសួរបញ្ហា”*

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងសូត្រទី ៣-៤ ដូចតទៅនេះ ៖*

*[២៣-២៤] បទថា* ***ផស្សាយតនានំ*** *(ផស្សាយតនៈ) បានដល់អណ្ដូងកើតនៃផស្សៈ អធិប្បាយថា ទីដែលកើតនៃផស្សៈ ។ បទថា* ***អត្ថញ្ញំ កិញ្ចិ*** *(អ្វីៗ ដទៃនៅមានឬ) ព្រះមហាកោដ្ឋិតៈសួរថា កាលផស្សាយតនៈទាំងនោះរលត់មិនសេសសល់ កិលេសណាៗ ក្រៅអំពីនោះ សូម្បីតិចតួចនៅមានឬ ។ សូម្បីក្នុងបទថា* ***នត្ថញ្ញំ កិញ្ចិ*** *(អ្វីៗ ដទៃមិនមានឬ) ព្រះមហាកោដ្ឋិតៈក៏សួរថា កិលេសសូម្បីតិចតួចក៏មិនមានឬ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ព្រះមហាកោដ្ឋិតៈសួរបញ្ហាសូម្បី ៤ ប្រការនេះ ដោយអំណាចសស្សតទិដ្ឋិ ឧច្ឆេទទិដ្ឋិ ឯកច្ចសស្សតទិដ្ឋិ (ការឃើញថាទៀងចំណែកខ្លះ) និងអមរាវិក្ខេបទិដ្ឋិ (ការឃើញបណ្ដោះបណ្ដែមិនឲ្យស្ងាប់ខ្ជួន) ។ ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរ កាលនឹងជំទាស់បញ្ហាដែលព្រះមហាកោដ្ឋិតៈសួរហើយសួរទៀត ទើបពោលថា* ***មាហេវំ*** *(មិនមែនដូច្នោះ) ។ ពាក្យថា* ***ហិ*** *ក្នុងបទនេះ (មាហេវំ) ជានិបាត ។ អធិប្បាយថា លោកកុំនិយាយយ៉ាងនេះ ។ ព្រះមហាកោដ្ឋិតៈសួរដោយអាការ មានសស្ស-*

តទិដ្ឋិជាដើមថា "វត្ថុអ្វីៗ ដទៃ ដោយអំណាចការចូលទៅប្រកាន់ថា មានអត្តា ឬ គឺ ឈ្មោះថា អត្តាអ្វីៗ ដទៃ មានឬ ។ សួរថា ក៏ព្រះមហាកោដ្ឋិតៈជាអត្តបលទ្ធិ (កាន់លទ្ធិថាមានអត្តា) ឬ ។ ឆ្លើយថា មិនមែនអត្តបលទ្ធិ តែភិក្ខុមួយរូបដែលអង្គុយនៅក្នុងទីនោះ មានលទ្ធិយ៉ាងនេះ ភិក្ខុនោះមិនអាចសួរបាន ។ ព្រះមហាកោដ្ឋិតៈសួរយ៉ាងនេះ ដើម្បីនឹងឲ្យព្រះសារីបុត្រដោះស្រាយលទ្ធិក្នុងទីនោះ ។ ព្រះមហាកោដ្ឋិតៈគិតថា "ព្រះមហាសាវកទាំងឡាយដោះស្រាយបញ្ហានេះ សូម្បីក្នុងពុទ្ធកាលដល់បុគ្គលដែលនឹងមានលទ្ធិយ៉ាងនេះក្នុងអនាគតកាល" ទើបសួរដើម្បីកាត់ឱកាសដែលនឹងនិយាយគ្នា ។

បទថា **អប្បបញ្ចំ បបញ្ចេតិ** (ធ្វើរឿងមិនយឺតយូរឲ្យយឺតយូរ) បានដល់ មិនធ្វើសេចក្ដីយឺតយូរក្នុងទីដែលគួរធ្វើឲ្យយឺតយូរ គឺ ក្នុងផ្លូវដែលមិនគួរ ។ បទថា **តាវតា បបញ្ចស្ស គតិ** (បបញ្ចធម៌ក៏នៅប្រព្រឹត្តទៅត្រឹមនោះ) សេចក្ដីថា គតិនៃផស្សាយតនៈ ៦ នៅមានត្រឹមណា គតិនៃបបញ្ចធម៌ មានតណ្ហា ទិដ្ឋិ មានះ ក៏នៅមានត្រឹមនោះ ។ បទថា **ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា បបញ្ចនិរោធោ បបញ្ច-វូបសមោ** (ព្រោះផស្សាយតនៈ ៦ រលត់មិនមានសេសសល់ បបញ្ចធម៌

*ក៏រលត់ បបញ្ចធម៌ក៏ស្ងប់រម្ងាប់ទៅ) សេចក្ដីថា កាលអាយតនៈទាំង ៦ នេះ រលត់ដោយប្រការទាំងពួង សូម្បីបបញ្ចធម៌ក៏ជាការរលត់ទៅ ជាការស្ងប់រម្ងាប់ទៅ , តែក្នុងអរូបភព ផស្សាយតនៈ ៥ របស់ទេវតាជាបុថុជ្ជនរលត់ទៅក៏ពិត តែព្រោះផស្សាយតនៈទី ៦ មិនទាន់រលត់ បបញ្ចធម៌សូម្បី ៣ ក៏ឈ្មោះថា នៅលះមិនបាន ។ ក៏លោកពោលបញ្ហានេះ ដោយអំណាចបញ្ចវោការភព (របស់សត្វដែលមានខន្ធ ៥) ប៉ុណ្ណោះ ។ ក្នុងអានន្ទសូត្រ ក៏គប្បីជ្រាបដោយន័យនេះឯង ។*

ចប់អដ្ឋកថា កោដ្ឋិត និងអានន្ទសូត្រទី ៣-៤

# អដ្ឋកថា ឧបវានសូត្រទី ៥

## “ព្រះឧបវានៈសួរបញ្ហា”

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបវានសូត្រទី ៥ ដូចតទៅនេះ ៖

[២៥] បទថា **វិជ្ជាយន្តករោ ហោតិ** (បុគ្គលធ្វើទីបំផុតទុក្ខដោយវិជ្ជា) សេចក្តីថា បុគ្គលធ្វើនូវទីបំផុតវដ្តទុក្ខបានដោយវិជ្ជា គឺ ធ្វើវដ្តទុក្ខទាំងអស់ឲ្យដាច់ផ្លូវ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា **សឧបាទានោ** (បុគ្គលមានឧបាទាន) បានដល់ ជាបុគ្គលនៅមានសេចក្តីប្រកាន់ ។ បទថា **អន្តករោ អភវិស្ស** (នឹងធ្វើទីបំផុតនៃទុក្ខ) គឺ បុគ្គលនឹងធ្វើទីបំផុតនៃវដ្តទុក្ខបាន ។ បទថា **ចរណសម្បន្នោ** (បុគ្គលមានចរណៈដល់ព្រម) គឺ បុគ្គលដល់ព្រមដោយចរណធម៌ ១៥ ប្រភេទ ។ បទថា **យថាភូតំ ជានំ បស្សំ អន្តករោ ហោតិ** (កាលឃើញតាមសេចក្តីពិតរមែងធ្វើនូវទីបំផុតទុក្ខបាន) សេចក្តីថា បុគ្គលឃើញដោយមគ្គបញ្ញាតាមសេចក្តីពិតហើយ ឈ្មោះថា ជាអ្នកធ្វើនូវទីបំផុតនៃវដ្តទុក្ខបាន ព្រះសារីបុត្តឲ្យបញ្ហាចប់ដល់កំពូលធម៌ គឺ ព្រះអរហត្ត ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឧបវានសូត្រទី ៥

# អដ្ឋកថា អាយាចនសូត្រទី ៦

## *"សេចក្តីប្រាថ្នាដោយប្រពៃរបស់បរិស័ទ ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាយាចនសូត្រទី ៦ ដូចតទៅនេះ ៖*

[២៦] *គប្បីជ្រាបក្នុងសូត្រនេះ ដូចបានពោលហើយក្នុងអដ្ឋកថាឯកនិបាតកន្លងហើយចុះ ។*

ចប់អដ្ឋកថា អាយាចនសូត្រទី ៦

# អដ្ឋកថា រាហុលសូត្រទី ៧

## “ត្រាស់ទូន្មានព្រះរាហុលឲ្យមនសិការក្នុងធាតុ ៤”

*គប្បីជ្រាបវិនិច្ឆ័យក្នុង រាហុលសូត្រទី ៧ ដូចតទៅនេះ ៖*

[២៧] *បទថា* ***អជ្ឈត្តិកា*** *(ជាខាងក្នុង) បានដល់ បឋវីធាតុខាងក្នុង ២០ ចំណែក មានសក់ជាដើម ។ បទថា* ***ពាហិរា*** *(ខាងក្រៅ) បានដល់ គប្បីជ្រាប បឋវីធាតុមានលក្ខណៈរឹងក្នុងផ្ទាំងថ្ម និងភ្នំជាដើម ដែលមិនជាប់ដោយឥន្ទ្រិយ ជាខាងក្រៅ ។ គប្បីជ្រាបធាតុសូម្បីដ៏សេសដោយន័យនេះ ។ បទថា* ***នេតំ មម នេសោហមស្មិ ន មេ សោ អត្តា*** *(នុ៎ះមិនមែនរបស់យើង នុ៎ះមិនមែនជាយើង នុ៎ះមិនមែនខ្លួនរបស់យើង) នេះ លោកពោលដោយអំណាចការបដិសេធសេចក្តីប្រកាន់ ដោយតណ្ហា មានះ និងទិដ្ឋិ ។ បទថា* ***សម្មប្បញ្ញាយ ទដ្ឋព្វំ*** *(គប្បីឃើញ... ដោយបញ្ញាដ៏ប្រពៃ) បានដល់ គប្បីឃើញដោយមគ្គប្បញ្ញា ដោយហេតុ ដោយការណ៍ ។*

*បទថា* ***ទិស្វា*** *(ព្រោះឃើញ) បានដល់ ឃើញដោយមគ្គប្បញ្ញាព្រមដោយវិបស្សនា ។ បទថា* ***អច្ឆេជ្ជិ តណ្ហំ*** *(កាត់តណ្ហាបានហើយ) បានដល់ កាត់តណ្ហាព្រមទាំងមូល ដែលគប្បីសម្លាប់ដោយមគ្គ ។ បទថា* ***វិវត្តយិ សំយោជនំ*** *(រុះរើសំយោជនៈបាន) បានដល់ រុះរើ គឺ ដកសំយោជនៈ*

១០ យ៉ាង ។ បទថា *សម្មាមានាភិសមយា* (ព្រោះលះមានះបានដោយល្អ) បានដល់ ព្រោះលះមានះ ៩ យ៉ាង ដោយហេតុ ដោយការណ៍ ។ បទថា *អន្តមកាសិ ទុក្ខស្ស* (ធ្វើទីបំផុតទុក្ខ) បានដល់ កាត់ផ្តាច់ផ្លូវវដ្តទុក្ខ អធិប្បាយថា ធ្វើឲ្យឈប់ហើយ ។ ព្រះសាស្តាត្រាស់វិបស្សនាទុកក្នុងរាហុលោវាទសូត្រក្នុងសំយុត្តនិកាយ ។ សូម្បីក្នុងចូឡរាហុលោវាទសូត្រ ក៏ត្រាស់វិបស្សនា ។ ត្រាស់ការវៀរចាកមុសាវាទរបស់ភិក្ខុកំលោះ ទុកក្នុងរាហុលោវាទសូត្រក្នុងអម្ពលដ្ឋិការាម ។ ត្រាស់វិបស្សនាប៉ុណ្ណោះក្នុងមហារាហុលោវាទសូត្រ ។ ត្រាស់ចតុកោដិកសុញ្ញតា (ភាពសូន្យទទេ ៤ យ៉ាង) ទុកក្នុងអង្គុត្តរនិកាយ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថារាហុលសូត្រទី ៧

# អដ្ឋកថា ជម្ពាលីសូត្រទី ៨

## "បុគ្គលប្រៀបដូចត្រពាំងទឹកធំ"

គប្បីជ្រាបវិនិច្ឆ័យក្នុង ជម្ពាលីសូត្រទី ៨ ដូចតទៅនេះ ៖

[២៨] បទថា **សន្តំ ចេតោវិមុត្តឹ** (ចេតោវិមុត្តិដែលស្ងប់)[១] បានដល់ សមាបត្តិ ៨ ណាមួយ ។ បទថា **សក្កាយនិរោធំ** (សក្កាយនិរោធ) បានដល់ រលត់សក្កាយៈដែល បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ អធិប្បាយថា និព្វាន ។ បទថា **ន បក្ខន្ទតិ** (រមែងមិនស្ទុះទៅ) បានដល់ មិនស្ទុះទៅដោយអំណាចអារម្មណ៍ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **ន បាដិកង្ខោ** (មិនគប្បីសង្ឃឹម) បានដល់ មិនគប្បីបានតាមប្រាថ្នា ។ បទថា **លបគតេន** បានដល់ ប្រឡាក់ដោយជ័រស្អិត ។

ក៏ក្នុងសេចក្តីនេះ គួរនាំមកប្រៀបដោយបុរសដែលប្រាថ្នានឹងឆ្លងទៅនាយ ។ គេឮថា បុរសម្នាក់ប្រាថ្នានឹងឆ្លងទៅត្រើយនាយនៃទន្លេ ដែលមានក្រសែទឹកខៀវស្រងាត់ ពោរពេញទៅដោយត្រីកាច គិតថា ត្រើយនេះក្នុងគួរគ្រៀស មានភ័យចំពោះមុខ ត្រើយនាយជាទីក្សេម រួចពីភ័យ យើងនឹងធ្វើយ៉ាងណាហ្ន៎ ទើបនឹងឆ្លងទៅត្រើយឯណោះបាន ឃើញដើមថ្ងាន់

---

(១) បិដក ប្រែថា សមាបត្តិដ៏ល្អិត ។

៨ ដើម ដុះរៀងគ្នា ក៏គិតថា យើងគួរនឹងទៅតាមលំដាប់តាមដើមឈើនេះ បានឬទេហ្ន៎ គិតទៀតថា ដែលឈ្មោះថា ដើមថ្ងាន់ មានមែករលោង នឹងយកដៃចាប់មែកតោងមិនបាន ទើបយកជរបស់ដើមជ្រៃ និងដើមល្វៀបជាដើមណាមួយប្រឡាក់ដៃ និងជើង យកដៃស្តាំជាប់មែកមួយ ៗ ដៃក៏ជាប់នឹងមែកនោះឯង ។ យកដៃឆ្វេង ជើងស្តាំ ជើងឆ្វេង ចាប់តោងក៏ជាប់ទៀត ព្រោះហេតុនោះ ដៃ និងជើងសូម្បីទាំង ៤ ក៏ជាប់នៅត្រង់មែកនោះឯង ។ គេព្យួរក្បាលចុះ កាលភ្លៀងធ្លាក់ចុះលើទន្លេ គេក៏លិចចុះក្នុងក្រសែទឹកទន្លេដែលពេញ ក្លាយជាចំណីក្រពើជាដើម ។ ក្នុងសេចក្តីនោះ មានឧបមាដូច្នេះ ក្រសែនៃសង្សារគប្បីឃើញដូចក្រសែទឹក ។ ព្រះយោគាវចរ ដូចបុរសប្រាថ្នានឹងឆ្លងទៅត្រើយនាយ សក្កាយៈដូចត្រើយខាងអាយ និព្វានដូចត្រើយខាងនាយ សមាបត្តិ ៨ ដូចដើមថ្ងាន់ ៨ ដើម ដែលដុះរៀងគ្នា ការមិនជម្រះធម៌ដែលធ្វើអន្តរាយដល់ឈាន និងវិបស្សនាឲ្យបរិសុទ្ធ ហើយចូលសមាបត្តិ ដូចយកដៃដែលប្រឡាក់ជរស្អិតចាប់មែកឈើ វេលាដែលត្រូវសេចក្តីពេញចិត្តរួបរិតចិត្តទុកក្នុងបឋមឈាន ដូចយកដៃ និងជើងទាំង ៤ ចាប់ជាប់ត្រង់មែកឈើ ព្យួរក្បាលចុះ វេលាដែលកិលេសកើតក្នុងទ្វារ ៦ ដូចភ្លៀងធ្លាក់ក្នុងទន្លេ វេលាដែលបុគ្គលលិចចុះក្នុងក្រសែសង្សារ សោយ

ទុក្ខក្នុងអបាយ ៤ ដូចវេលាដែលបុរសនោះលិចចុះក្នុងក្រសែទឹកដែលពេញ និងជាចំណីរបស់ក្រពើជាដើម ។

បទថា *សុទ្ធេន ហត្ថេន* (មានដៃបរិសុទ្ធ) បានដល់ មានដៃដែលលាងស្អាតល្អហើយ ។ សូម្បីក្នុងសេចក្តីនេះ ក៏គប្បីប្រៀបធៀបដូច្នោះដូចគ្នា ។ បុរសអ្នកបំណងនឹងឆ្លងត្រើយនាយនោះឯង គិតថា ដែលឈ្មោះថា ដើមថ្ងាន់មានមែករលោង បុគ្គលដែលចាប់ដោយដៃស្មោកគ្រោក ដៃក៏គប្បីជាប់ ទើបលាងដៃ និងជើងឲ្យស្អាត ហើយចាប់មែកមួយឡើងដើមទី ១ ចុះពីដើមទី ១ ឡើងដើមទី ២ ។ល។ ចុះពីដើមទី ៧ ឡើងដើមទី ៨ ចុះពីដើមទី ៨ ហើយក៏ដល់ត្រើយដែលជាទីផុតចាកភ័យក្នុងត្រើយនាយ ។ ក្នុងការឧបមានេះ វេលាដែលព្រះយោគីគិតថា យើងនឹងចូលសមាបត្តិ ៨ លុះចេញចាកសមាបត្តិហើយ នឹងកាន់យកព្រះអរហត្តឲ្យបាន គប្បីជ្រាបដូចវេលាដែលបុរសនោះគិតថា យើងនឹងឆ្លងទៅត្រើយនាយ ដោយដើមឈើទាំងនេះ ការជម្រះធម៌ដែលធ្វើអន្តរាយដល់ឈាន និងវិបស្សនា ហើយចូលសមាបត្តិ ដូចការតោងមែកឈើដោយដៃស្អាត វេលាចូលបឋមឈានដូចវេលាឡើងដើមឈើទី ១ ក្នុងដើមឈើទាំងនោះ វេលាដែលមិនត្រូវសេចក្តីពេញចិត្តចងទុកក្នុងបឋមឈាន ចេញពីបឋមឈាននោះហើយ ចូល

ទុតិយឈាន ។ល។ ដូចវេលាចុះពីដើមឈើទី ១ ហើយឡើងដើមឈើទី ២ ។ល។ វេលាដែលមិនត្រូវសេចក្តីជាប់ចិត្តចង់ទុកក្នុងអាកិញ្ចញ្ញាយតន-សមាបត្តិ ចេញចាកអាកិញ្ចញ្ញាយតនសមាបត្តិនោះហើយ ចូលនៅសញ្ញា-នាសញ្ញាយតនសមាបត្តិ ដូចចុះចាកដើមឈើទី ៧ ហើយឡើងដើមឈើទី ៨ វេលាដែលមិនត្រូវសេចក្តីជាប់ចិត្តចង់ទុកក្នុងនេវសញ្ញានាសញ្ញាយតនៈ ចេញចាកសមាបត្តិហើយ ពិចារណាសង្ខារក៏សម្រេចព្រះអរហត្ត ដូចវេលាដែលបុរសចុះពីដើមឈើទី ៨ ហើយក៏ទៅដល់ត្រើយនាយ ដែលជាទីមិនមានភ័យ ។

បទថា **អវិជ្ជាបភេទំ មនសិករោតិ** (មនសិការដល់ការកម្ចាត់អវិជ្ជា) បានដល់ ភិក្ខុមនសិការព្រះអរហត្ត ពោលគឺ ធម៌ជាគ្រឿងកម្ចាត់អវិជ្ជាធំក្រាស់ ដែលជាសេចក្តីមិនដឹងក្នុងឋានៈ ៨ ។ បទថា **ន បក្ខន្ទតិ** (រមែងមិនស្ទុះទៅ) បានដល់ មិនស្ទុះទៅដោយអារម្មណ៍នោះឯង ។ បទថា **ជម្ពាលី** (ត្រពាំងទឹកធំ) បានដល់ ត្រពាំងទឹកខ្នាតធំជាទីផ្ទុកទឹក ដែលហូរចេញពីស្រុក ។ បទថា **អនេកវស្សគណិកា** (មានអាយុរាប់បានច្រើនឆ្នាំ) បានដល់ត្រពាំងទឹក ឈ្មោះថា **មានអាយុរាប់បានច្រើនឆ្នាំ** បានដល់ ត្រពាំងទឹកឈ្មោះថា មានអាយុរាប់បានច្រើនឆ្នាំ ព្រោះមានត្រពាំងទឹកកើតឡើងរាប់បាន

ច្រើនឆ្នាំ ព្រោះត្រពាំងទឹកនោះកើតឡើងក្នុងវេលាដែលស្រុក ឬនគរកើតឡើង ។ បទថា **អាយមុខានិ** (ផ្លូវហូរចូល) បានដល់ ប្រឡាយហូរចូល ៤ កន្លែង ។ បទថា **អបាយមុខានិ** (ផ្លូវហូរចេញ) បានដល់ គន្លងហូរចេញ ។

បទថា **ន បាលិប្បភេទោ**[១] **បាជិកង្ខោ** (មិនគប្បីសង្ឃឹមនឹងមានទឹកធ្លាយចេញតាមក្លឹទៅបាន) បានដល់ មិនគប្បីសង្ឃឹមថា នឹងមានទឹកហូរចេញពីក្លឹទៅបាន ព្រោះថា ទឹកជន់ក្នុងទីនោះមិនអាចទម្លាយក្លឹ ហើយហូរយកសម្រាមទៅមហាសមុទ្របាន ដើម្បីអធិប្បាយសេចក្តីនេះឲ្យជាក់ច្បាស់ គួរនាំរឿង បុគ្គលស្វែងរកចំការមកដើម្បីឧបមា ។ មានរឿងដំណាលថា កុលបុត្រអ្នកក្រុងម្នាក់ស្វែងរកចំការ បានឃើញត្រពាំងធំមិនឆ្ងាយពីក្រុងពេក ។ គេយល់ថា ទីនេះនឹងជាចំការគួររីករាយ ទើបកាន់យកចបបិទផ្លូវ ៤ ផ្នែក ហើយបើកប្រឡាយឲ្យទឹកហូរ ។ ភ្លៀងមិនធ្លាក់បន្ថែម ។ ទឹកដែលនៅសល់ក៏ហូរទៅតាមប្រឡាយទឹក ចំនៀរស្បែក និងសំពត់មិនល្អជាដើមក៏ស្អុយក្នុងទីនោះឯង ។ ជនទាំងឡាយក៏ឈប់នៅជុំវិញនោះ មិនព្រមចូលទៅ ។ សូម្បីដែលចូលទៅ ក៏ត្រូវបិទច្រមុះដើរគេចទៅ ។ កន្លងទៅ ២-៣ ថ្ងៃ គេក៏ថយទៅឈរមើល មិនអាចចូលទៅបាន ហើយក៏គេចទៅ ។

---

(១) បិដក = អាលិប្បភេទោ

ក្នុងការឧបមានោះ យោគាវចរគប្បីឃើញដូចកុលបុត្រអ្នកក្រុង ។ កាយ គឺ មហាភូតរូប ៤ ដូចវេលាដែលកុលបុត្រអ្នកស្វែងរកចំការ ឃើញត្រពាំងទឹកជំជិតទ្វារស្រុក វេលាដែលខ្លួនមិនបានទឹក គឺ ការស្តាប់ធម៌ ដូចវេលាដែលបិទផ្លូវទឹកហូរចូល វេលាដែលលះបង់សេចក្តីសង្រួមក្នុងទ្វារ ៦ ដូចវេលាដែលបើកផ្លូវទឹកឲ្យហូរចេញ វេលាដែលមិនបានកម្មដ្ឋានជាទីសប្បាយ ដូចវេលាដែលភ្លៀងមិនធ្លាក់ត្រូវតាមរដូវកាល វេលាដែលគុណខាងក្នុងសាបសូន្យ ដូចវេលាដែលទឹកដែលនៅសល់ហូរចេញតាមប្រឡាយ វេលាដែលមិនអាចទម្លាយក្តី គឺ អវិជ្ជាបានដោយអរហត្តមគ្គហើយ កម្ចាត់កងកិលេសចេញធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ ដូចវេលាដែលទឹកជន់ហើយមិនអាចទម្លាយក្តីហូរនាំសម្រាមចុះទៅមហាសមុទ្របាន វេលាដែលពេញទៅដោយកិលេសមានរាគៈជាដើមខាងក្នុង ដូចចំនៀរស្បែក និងសំពត់ក្រខ្វក់ជាដើម ស្អុយនៅក្នុងអណ្តូងទឹកនុ៎ះឯង វេលាដែលបុគ្គលមានការព្រមព្រៀងក្នុងវដ្តៈ ភ្លើតភ្លើនក្នុងវដ្តៈ ដូចវេលាដែលគេមកឃើញ (ត្រពាំងទឹក) ហើយមានសេចក្តីទាស់ចិត្តត្រឡប់ទៅវិញ ។

បទថា **បាលិប្បភេទោ បាជិកង្ខោ** បានដល់ គប្បីសង្ឃឹមថា ទឹកនឹងទម្លាយក្តីទៅបាន ។ អធិប្បាយថា ពិតណាស់ ទឹកដែលហូរពីនោះ នឹងអាច

ទម្លាយភ្លឺត្រពាំង ហើយហូរនាំយកសម្រាមទៅកាន់មហាសមុទ្របាន ។ សូម្បីក្នុងសេចក្តីនេះ ក៏គប្បីនាំការប្រៀបធៀបនោះមកបាន ។ វេលាដែលបានស្តាប់ធម៌ជាទីសប្បាយ គប្បីជ្រាប ដូចវេលាដែលបើកផ្លូវទឹកឲ្យហូរចេញពីត្រពាំងទឹកនោះ វេលាសង្រួមក្នុងទ្វារ ៦ តាំងមាំហើយ ដូចវេលាដែលបិទផ្លូវទឹកហូរចេញ វេលាដែលខ្លួនបានកម្មដ្ឋានជាទីសប្បាយ ដូចវេលាដែលភ្លៀងធ្លាក់ត្រូវតាមរដូវកាល វេលាខ្លួនទម្លាយអវិជ្ជាចេញបានដោយអរហត្តមគ្គ ហើយកម្ចាត់កងអកុសល ធ្វើនិព្វានឲ្យជាក់ច្បាស់ ដូចវេលាទឹកជន់ឡើងហូរទម្លាយភ្លឺនាំយកសម្រាមទៅកាន់មហាសមុទ្រ វេលាដែលពេញប្រៀបដោយលោកុត្តរធម៌ខាងក្នុង ដូចវេលាដែលត្រពាំងពេញប្រៀបដោយទឹកដែលចូលតាមផ្លូវទឹកហូរចូល វេលាដែលឡើងកាន់ធម្មប្រាសាទអង្គុយជាសុខក្នុងផលសមាបត្តិមាននិព្វានជាអារម្មណ៍ ដូចដែលបុគ្គលដាំដុះកូនឈើទុកដោយជុំវិញ ហើយសាងប្រាសាទត្រង់កណ្តាលចំការ មានអ្នកបម្រើមកបំរើ ហើយអង្គុយបរិភោគអាហារដែលឆ្ងាញ់ៗ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានសេចក្តីងាយហើយ ។ ក៏ទ្រង់ត្រាស់ព្រះទេសនាលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

ចប់អដ្ឋកថា ជម្ពាលីសូត្រទី ៨

# អដ្ឋកថា និព្វានសូត្រទី ៩

## *"ពោលដោយនិព្វាន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វានសូត្រទី ៩ ដូចតទៅនេះ ៖*

*[២៩] ក្នុងបទទាំងឡាយ មានជាអាទិ៍ថា* **ហានភាគិយា សញ្ញា** *(សញ្ញាចំណែកវិនាស) គប្បីជ្រាបសេចក្តីដោយន័យដែលលោកពោលទុកហើយក្នុងអភិធម្មនុ៎ះឯង យ៉ាងនេះថា ការមនសិការដោយសញ្ញាដែលសហគតៈដោយកាម រមែងធ្វើអ្នកបានបឋមឈានឲ្យរាយមាយ សញ្ញាក៏ឈ្មោះ* **ហានភាគិនី** *(សញ្ញា[១] ចំណែកវិនាស) ។ បទថា* **យថាភូតំ នប្បជានាតិ** *(មិនដឹងច្បាស់តាមសេចក្តីពិត) បានដល់ មិនដឹងដោយមគ្គញាណ តាមសេចក្តីពិត ។*

ចប់អដ្ឋកថា និព្វានសូត្រទី ៩

---

*(១) ច្បាប់ភូមា = ជាបញ្ញា ។*

# អដ្ឋកថា មហាបទេសសូត្រទី ១០

## *"មហាបទេស ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មហាបទេសសូត្រទី ១០ ដូចតទៅនេះ ៖*

[៣០] *បទថា* ***ភោគនគរេ វិហរតិ*** *(ប្រថាប់នៅ... ជិតភោគនគរ) បានដល់ ក្នុងសម័យដែលស្តេចនឹងបរិនិព្វាន ព្រះមានព្រះភាគស្តេចចារិកទៅនគរនោះ ហើយប្រថាប់នៅ ។ បទថា* ***អានន្ទចេតិយេ*** *(ត្រង់អានន្ទចេតិយ) បានដល់ ក្នុងវិហារដែលតាំងនៅត្រង់ទីនៅរបស់អានន្ទយក្ខ ។ បទថា* ***មហាបទេស*** *ប្រែថា គោលការធំ ឬប្រការដែលអាងធំ អធិប្បាយថា ហេតុធំ ដែលពោលអាងបុគ្គលធំៗ មានព្រះពុទ្ធជាដើម ។ បទថា* ***នេវ-អភិនន្ទិតព្វំ*** *(មិនគួរត្រេកអរ) សេចក្តីថា ភាសិតនោះ កាលស្តាប់លើកដំបូង អ្នកទាំងឡាយកុំជាអ្នករីករាយត្រេកអរ ឲ្យសាធុការឡើយ ព្រោះកាលមានអ្នកធ្វើយ៉ាងនេះ ភិក្ខុនោះសូម្បីនឹងត្រូវតវ៉ាក្នុងខាងក្រោយថា ពាក្យនេះមិនសម ក៏នឹងពោលថា កាលមុន នេះជាធម៌ ឥឡូវនេះ មិនមែនធម៌ ឬ ហើយមិនព្រមលះបង់លទ្ធិ ។ បទថា* ***នប្បដិក្កោសិតព្វំ*** *(មិនគប្បីជំទាស់) បានដល់ មិនគប្បីពោលមុនថា បុគ្គលល្ងង់នេះនិយាយអ្វី ។ ព្រោះកាលពោលយ៉ាងនេះហើយ ភិក្ខុនោះនឹងមិនពោលដល់សូម្បីប្រការដែលត្រូវ និង*

ខុស ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **មិនគប្បីត្រេកអរ មិនគប្បីជំទាស់** ។ បទថា **បទព្យញ្ជនានិ** (បទព្យញ្ជនៈ) បានដល់ ព្យញ្ជនៈ ពោលគឺ បទ ។ បទថា **សាធុកំ ឧគ្គហេត្វា** (រៀន... ឲ្យល្អ) បានដល់ រៀនដោយល្អថា លោកពោលបាលីទុកក្នុងទីនេះ ពោលអត្ថទុកក្នុងទីនេះ ពោលអនុសន្ធិទុកក្នុងទីនេះ ពោលបទដើមបទចុងទុកក្នុងទីនេះ ។ បទថា **សុត្តេ ឱតារេតព្វានិ** (គប្បីប្រៀបធៀបក្នុងព្រះសូត្រ) បានដល់ គប្បីត្រួតពិនិត្យជាមួយព្រះសូត្រ ។ បទថា **វិនយេ សន្ទស្សេតព្វានិ** (គប្បីសាកសួរក្នុងព្រះវិន័យ) បានដល់ គប្បីពិនិត្យមើលក្នុងព្រះវិន័យ ។

ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ព្រះវិន័យថាជា **សូត្រ** ដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា (ការរក្សាអំបិលទុកក្នុងក្លាក់) ព្រះមាន-ព្រះភាគត្រាស់ហាមទុកក្នុងទីណា ត្រាស់ហាមទុកក្នុងក្រុងសាវត្ថី ប្រាកដក្នុងសុត្តវិភង្គ ។ ត្រាស់ខន្ធកៈថា **វិន័យ** ដូចដែលលោកពោលទុកថា "ការល្មើសក្នុងវិន័យ ឯក្រុងកោសម្ពី" ។ មិនកាន់យកសូម្បីវិន័យបិដកយ៉ាងនេះ តែកាន់យកវិន័យបិដកយ៉ាងនេះថា "ឧភតោវិភង្គ ជាព្រះសូត្រខន្ធកៈ និងបរិវារៈ ជាព្រះវិន័យ" ។ម្យ៉ាងទៀត កាន់យកបិដកពីរយ៉ាងនេះ គឺ សុត្តន្តបិដកជាព្រះសូត្រ វិន័យបិដកជាព្រះវិន័យ ។ ឬថា មិនកាន់

យកបិដកបីយ៉ាងនេះ គឺ សុត្តន្តបិដក និងអភិធម្មបិដកជាព្រះសូត្រ វិន័យ-បិដកជាព្រះវិន័យ ។ ពិតហើយ ឈ្មោះថា ពុទ្ធវចនៈដែលមិនមានឈ្មោះថាសូត្រក៏មាន គឺ ជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទានឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន ។

តែព្រះសុទិន្នត្ថេរជំទាស់ពាក្យទាំងអស់នោះថា ពុទ្ធវចនៈដែលមិនមានឈ្មោះថាសូត្រនោះ មិនមាន ហើយពោលថា បិដក ៣ ជាព្រះសូត្រ តែព្រះវិន័យជាការណៈ (ហេតុ) ។ កាលនឹងសម្ដែងដល់ការណៈតពីនោះ ទើបពោលសូត្រនេះថា ម្នាលគោតមី នាងគប្បីដឹងធម៌ពួកណា ធម៌ពួកនេះរមែងប្រព្រឹត្តទៅដើម្បីប្រកបដោយរាគៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ រមែងប្រព្រឹត្តទៅដើម្បីសំយោជនៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកសំយោជនៈ រមែងប្រព្រឹត្តទៅដើម្បីការប្រកាន់មាំ មិនប្រព្រឹត្តទៅដើម្បីការមិនប្រកាន់មាំ រមែងប្រព្រឹត្តទៅដើម្បីជាអ្នកប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីជាអ្នកប្រាថ្នាតិច រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្ដីព្យាយាម រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីច្របូកច្របល់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីវិវេក រមែងប្រព្រឹត្តទៅដើម្បីសេចក្ដី

សន្សំ មិនប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្សំ ម្នាលគោតមី នាងគប្បីដឹងដោយចំណែកមួយថា នេះមិនមែនធម៌ នេះមិនមែនវិន័យ នេះមិនមែនពាក្យទូន្មានរបស់ព្រះសាស្តា ម្នាលគោតមី នាងគប្បីដឹងធម៌ពួកណា ធម៌ពួកនេះរមែងប្រព្រឹត្តទៅដើម្បីការប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីការមានរាគៈ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកសំយោជនៈ មិនមែនប្រព្រឹត្តទៅដើម្បីការបានសំយោជនៈ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនប្រកាន់មាំ មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រកាន់មាំ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស រមែងប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស រមែងប្រព្រឹត្តទៅដើម្បីវិវេក មិនប្រព្រឹត្តទៅដើម្បីសេចក្តីច្របូកច្របល់ រមែងប្រព្រឹត្តទៅដើម្បីការមិនសន្សំ មិនប្រព្រឹត្តទៅដើម្បីការសន្សំ ម្នាលគោតមី នាងគប្បីដឹងដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

ព្រោះដូច្នោះ សេចក្តីក្នុងប្រការនេះទើបមានដូច្នេះថា បទថា **សុត្តេ** (ក្នុងព្រះសូត្រ) បានដល់ គប្បីប្រៀបធៀបក្នុងព្រះពុទ្ធវចនៈ គឺ បិដក ៣ ។

បទថា ***វិនយេ*** (ក្នុងព្រះវិន័យ) បានដល់ គប្បីសាកសួរក្នុងហេតុនៃការកម្ចាត់កិលេស មានរាគៈជាដើមតែម្យ៉ាង ។

បទថា ***នចេវ សុត្តេ ឱតរន្តិ*** (ប្រៀបធៀបគ្នាមិនបានក្នុងព្រះសូត្រ) សេចក្តីថា បទព្យញ្ជនៈទាំងឡាយមិនមានមកក្នុងទីណាៗ តាមលំដាប់ ក្នុងព្រះសូត្រ លើកសំបកឡើងហើយ ប្រាកដច្បាស់ថា មកពីគម្ពីរគុឡ្ហវេស្សន្តរៈ គុឡ្ហវិន័យ និងវេទល្លបិដកណាមួយ (ជាគម្ពីរបកាយមហាយាន) ។ ក៏បទព្យញ្ជនៈដែលមកហើយយ៉ាងនេះ និងមិនប្រាកដក្នុងការនាំកិលេស មានរាគៈជាដើមចេញ ក៏គប្បីលះបង់ចេញ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ***ឥតិ ហិទំ ភិក្ខវេ ឆឌ្ឌេយ្យាថ*** (អ្នកទាំងឡាយគប្បីលះពាក្យនោះចេញ) គប្បីជ្រាបសេចក្តីក្នុងទីទាំងពួងដោយឧបាយនេះ ។ បទថា ***ឥទំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ*** (ម្នាលភិក្ខុទាំងឡាយ នេះមហាបទេសប្រការទី ៤ អ្នកទាំងឡាយគប្បីចាំទុក) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចងចាំទុក នូវឱកាសជាទីប្រតិស្ឋានធម៌ប្រការទី ៤ នេះទុក ។

ចប់អដ្ឋកថា មហាបទេសសូត្រទី ១០

## ចប់សញ្ចេតនិយវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# យោធាជីវវគ្គវណ្ណនាទី ៤

## អដ្ឋកថា យោធាសូត្រទី ១

*"គុណសម្បត្តិរបស់អ្នកច្បាំង និងភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យោធាសូត្រទី ១ ដូចតទៅនេះ ៖*

[៣១] *បទថា ឋានកុសលោ (អ្នកឆ្លាតក្នុងឋានៈ) បានដល់ ជាអ្នកឈ្លាសវៃក្នុងទីដែលខ្លួនឈរហើយបាញ់មិនខុស ។ បទដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយក្នុងកាលមុននុ៎ះឯង ។*

ចប់អដ្ឋកថា យោធាសូត្រទី ១

# អដ្ឋកថា បាដិភោគសូត្រទី ២

## *“ធម៌ដែលមិនមាននរណាធានាបាន”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បាដិភោគសូត្រទី ២ ដូចតទៅនេះ ៖*

[៣២] *បទថា* ***នត្ថិ កោចិ បាដិភោគោ*** *(នរណាៗ ដែលនឹងជាអ្នកធានា) សេចក្តីថា ឈ្មោះថា អ្នកដែលអាចនឹងធានាយ៉ាងនេះថា យើងជាអ្នកធានាក្នុងធម៌នេះ ដូច្នេះ រមែងមិនមាន ។ បទថា* ***ជរាធម្មំ*** *(វត្ថុដែលមានសេចក្តីចាស់ជាធម្មតា) បានដល់ ភាវៈដែលមានការចាស់ ។ ក្នុងបទទាំងអស់ ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា បាដិភោគសូត្រទី ២

# អដ្ឋកថា សុតសូត្រទី ៣

*"វត្ថុដែលមិនបានស្តាប់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុតសូត្រទី ៣ ដូចតទៅនេះ ៖*

[៣៣] *បទថា **នត្ថិ តតោ ទោសោ** (ទោសពីការនិយាយនោះមិនមាន) សេចក្តីថា ឈ្មោះថា ទោសក្នុងការនិយាយនោះ មិនមាន ។*

ចប់អដ្ឋកថា សុតសូត្រទី ៣

# អដ្ឋកថា អភយសូត្រទី ៤

## *“បុគ្គលដែលខ្លាចស្លាប់ និងមិនខ្លាចស្លាប់”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អភយសូត្រទី ៤ ដូចតទៅនេះ ៖*

[៣៤] *រោគទាំងឯង ឈ្មោះថា* ***រោគាតង្កោ*** *(រោគធ្ងន់) ព្រោះអត្ថថា ជាហេតុធ្វើជីវិតឲ្យលំបាក ។ បទថា* ***ផុដ្ឋស្ស*** *(ពាល់ត្រូវ) បានដល់ ប្រកប ដោយរោគធ្ងន់នោះ ។ បទថា* ***ឧរត្តាឡឹ កន្ទតិ*** *(គក់ទ្រូងទួញយំ) បានដល់ គក់ទ្រូងស្រែកយំ) ។ បុញ្ញកម្ម ហៅថា សេចក្តីល្អ (កល្យាណៈ) ក្នុងបទ មានជាអាទិ៍ថា* ***អកតកល្យាណោ*** *(មិនបានធ្វើល្អ) ។ ឈ្មោះថា* ***មិនបានធ្វើ សេចក្តីល្អ*** *ព្រោះគេមិនបានធ្វើបុញ្ញកម្មនោះទុក ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ពិតហើយ បុញ្ញកម្មទាំងឯង ឈ្មោះថា* ***កុសល*** *ព្រោះ កើតពីសេចក្តីឆ្លាត ។ កុសលហៅថា* ***ភីរុត្តាណ*** *(កម្មជាគ្រឿងការពារនូវ សេចក្តីខ្លាច) ព្រោះជាគ្រឿងការពារសម្រាប់បុគ្គលអ្នកខ្លាច ។ អកុសលកម្ម ដ៏លាមក លោកហៅថា បាប ក្នុងបទមានជាអាទិ៍ថា* ***កតបាបោ*** *(ធ្វើតែ បាប) ។ បទថា* ***លុទ្ទំ*** *(កម្មអាក្រក់) បានដល់ កម្មដែលគ្រោតគ្រាត ។ បទថា* ***កិព្វិសំ*** *(កម្មដែលសៅហ្មង) បានដល់ កម្មមិនបរិសុទ្ធមានមន្ទិល ។ បទថា* ***កង្ខី ហោតិ*** *(ជាអ្នកមានសេចក្តីសង្ស័យ) បានដល់ ជាបុគ្គលប្រកប*

ដោយសេចក្តីសង្ស័យក្នុងឋានៈទាំង ៨ គឺ ក្នុងពុទ្ធគុណ ធម្មគុណ និង សង្ឃគុណ ក្នុងសិក្ខា ក្នុងអតីត ក្នុងអនាគត ទាំងក្នុងអតីត និងអនាគត និងក្នុងបដិច្ចសមុប្បាទ ។ បទថា **វិចិកិច្ឆី** (សន្និះសង្ស័យ) បានដល់ ជាបុគ្គលប្រកបដោយសេចក្តីងឿងឆ្ងល់ គឺ មិនជឿក្នុងព្រះសទ្ធម្ម ជាពាក្យប្រៀនប្រដៅ មិនអាចដាក់ចិត្តក្នុងការរៀន និងការសាកសួរ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងអស់ដោយន័យនេះ ។

ចប់អដ្ឋកថា ភយសូត្រទី ៤

# អដ្ឋកថា ព្រាហ្មណសច្ចសូត្រទី ៥

## *“សច្ចៈរបស់ព្រាហ្មណ៍”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណសច្ចសូត្រទី ៥ ដូចតទៅនេះ ៖*

[៣៥] *បទថា* ***ព្រាហ្មណសច្ចានិ*** *(សច្ចៈរបស់ព្រាហ្មណ៍) ប្រែថា សច្ចៈរបស់ព្រាហ្មណ៍ទាំងឡាយ ។ បទថា* ***សោ តេន ន សមណោតិ មញ្ញតិ*** *(ដោយការពោលពិតនោះ គេរមែងមិនសម្គាល់ខ្លួនថា ជាសមណៈ) សេចក្តីថា ដោយសច្ចៈនោះ ព្រះខីណាស្រពនោះ រមែងមិនសម្គាល់ដោយតណ្ហា មានះ ទិដ្ឋិ ថាយើងជាសមណៈ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា* ***យទេវ តត្ថ សច្ចំ តទភិញ្ញាយ*** *(គេដឹងច្បាស់សច្ចៈក្នុងការបដិបត្តិនោះហើយ) សេចក្តីថា សច្ចៈណាជារបស់ពិត មិនប្រែប្រួលក្នុងការបដិបត្តិនោះថា សត្វទាំងពួងមិនគួរសម្លាប់ ។ ដោយបទនេះ ទ្រង់ធ្វើវចីសច្ចៈទុកក្នុងខាងក្នុង ហើយសម្តែងនិព្វានជាបរមត្ថសច្ចៈ ។ បទថា* ***តទភិញ្ញាយ*** *(ដឹងច្បាស់សច្ចៈ) បានដល់ ដឹងសច្ចៈទាំងពីរនោះ ដោយបញ្ញាដែលវិសេសក្រៃលែង ។ បទថា* ***អនុទយា អនុកម្បាយ បដិបន្នោ ហោតិ*** *(ជាអ្នកបដិបត្តិដើម្បីអាណិត អនុគ្រោះ) សេចក្តីថា ជាអ្នកបដិបត្តិបដិបទាដើម្បីសេចក្តីអាណិត និងដើម្បីសេចក្តីអនុគ្រោះ អធិប្បាយថា ជា*

បុគ្គលត្រាស់ដឹងសច្ចៈនោះ ។

បទថា **សព្វេ កាមា** (កាមទាំងពួង) បានដល់ វត្ថុកាមទាំងអស់ កិលេសកាមទាំងអស់ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា **ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ** (កាលព្រាហ្មណ៍ពោលដូច្នេះ ឈ្មោះថា ពោលពិត) បានដល់ ព្រាហ្មណ៍ជាខីណាស្រព សូម្បីពោលហើយយ៉ាងនេះ ក៏ឈ្មោះថាពោលពិតនោះឯង ។ បទថា **សព្វេ ភវា** (ភពទាំងពួង) បានដល់ ភព ៣ មានកាមភពជាដើម ។

ក៏ក្នុងបទថា **នាហំ ក្វចិនិ** (យើងរមែងមិនមានក្នុងអ្វីៗ) នេះ ត្រាស់សុញ្ញតា (សេចក្តីសូន្យ) ៤ ប្រការ ។ ពិតណាស់ ព្រះខីណាស្រពមិនឃើញខ្លួនក្នុងទីណាៗ ថា យើងរមែងមិនមានក្នុងអ្វីៗ ។ បទថា **កស្សចិ កិញ្ចនតស្មឹ** (យើងរមែងមិនមានក្នុងភាពជាអ្វីៗ របស់នរណាៗ) សេចក្តីថា មិនឃើញខ្លួនរបស់ខ្លួន ដែលគប្បីនាំចូលទៅក្នុងភាពជាអ្វីៗ របស់បុគ្គលដទៃ អធិប្បាយថា មិនឃើញថាបងប្រុស គួរសម្គាល់នាំចូលទៅក្នុងឋានៈបងប្រុស សម្លាញ់ក្នុងឋានៈសម្លាញ់ ឬបរិក្ខារក្នុងឋានៈបរិក្ខារ ។ ក្នុងបទថា **ន ច មម ក្វចិនិ** (និងភាពជាអ្វីៗ ក្នុងនរណាៗ របស់យើងមិនមាន) នេះ វៀរ មម ស័ព្ទទុកសិន មានសេចក្តីដូច្នេះថា ព្រះខីណាស្រពមិនឃើញ

ខ្លួនក្នុងអ្វីៗ និងមិនឃើញខ្លួនរបស់បុគ្គលដទៃក្នុងអ្វីៗ ឥឡូវនេះនាំ មមសព្ទមក មានសេចក្តីថា ភាពជាអ្វីៗ ក្នុងវត្ថុអ្វីៗ មិនមានដល់យើង អធិប្បាយថា បុគ្គលណាមិនឃើញថា ខ្លួនរបស់បុគ្គលដទៃរមែងមានដល់យើង ក្នុងភាពជាអ្វីៗ ក្នុងវត្ថុអ្វីៗ បុគ្គលនោះឈ្មោះថា មិនឃើញខ្លួនរបស់បុគ្គលដទៃគួរនាំចូលមកដោយភាពជាអ្វីៗ នេះ មិនថាក្នុងឋានៈណាៗ គឺ បងប្រុសក្នុងឋានៈជាបងប្រុសរបស់ខ្លួន សម្លាញ់ក្នុងឋានៈជាសម្លាញ់ បរិក្ខារក្នុងឋានៈជាបរិក្ខារ ។ ព្រាហ្មណ៍នេះ គឺយ៉ាងនេះឯង ព្រោះមិនឃើញខ្លួនក្នុងទីណាៗ មិនឃើញខ្លួនដែលគួរនាំចូលទៅក្នុងភាពជាអ្វីៗ របស់បុគ្គលដទៃ មិនឃើញខ្លួនរបស់បុគ្គលដទៃ ដែលគួរនាំចូលទៅក្នុងភាពជាអ្វីៗ របស់ខ្លួន ។ បទថា **ឥតិ វទំ ព្រាហ្មណោ** (កាលព្រាហ្មណ៍ពោលដូច្នេះ) គប្បីជ្រាបសេចក្តីថា ព្រាហ្មណ៍ជាទីណាស្រេពសូម្បីពោលសុញ្ញតាទាំង ៤ ប្រការ ឈ្មោះថា ពោលសេចក្តីពិតនោះឯង ព្រោះដឹងច្បាស់ដោយប្រពៃដោយបដិបទានោះហើយ មិនបានពោលកុហកឡើយ ទាំងមិនប្រកាន់ខ្លួន ព្រោះខ្លួនលះសេចក្តីប្រកាន់ទាំងឡាយក្នុងគ្រប់វារៈបានហើយ ។ បទថា **អាកិញ្ចញ្ញំយេវ បដិបទំ** (បដិបទាដែលរកភាពជាអ្វីៗ មិនបាន) បានដល់ បដិបទាដែលវៀរចាកសេចក្តីកង្វល់ មិនមានការហួងហែង មិនប្រកាន់នោះឯង ។

បទថា បដិបន្នោ ហោតិ (បដិបត្តិ) បានដល់ បំពេញបរិបូរហើយ ។ បទថា ឥមានិ ខោ បរិព្វាជកា ចត្តារិ ព្រាហ្មណសច្ចានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ (បរិព្វាជកទាំងឡាយ សច្ចៈរបស់ព្រាហ្មណ៍ ៤ ប្រការនេះឯង ដែលតថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង ប្រកាសហើយ) សេចក្ដីថា តថាគតត្រាស់ដឹងសច្ចៈ ៤ ទាំងនេះរបស់ព្រាហ្មណ៍ ដែលមានបាបបន្សាត់បង់ហើយ ក្រៅពីសច្ចៈរបស់លោកព្រាហ្មណ៍ដែលលោកពោល តថាគតដឹងត្រាស់ដឹងដោយមគ្គ ៤ កិច្ច ១៦ យ៉ាងហើយ ទើបប្រកាសសម្ដែងឲ្យដឹងច្បាស់ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់វចីសច្ចៈតែម្យ៉ាងចំពោះព្រះខីណាស្រព ក្នុងឋានៈទាំង ៤ ដូច្នេះឯង ។

ចប់អដ្ឋកថា ព្រាហ្មណសច្ចសូត្រទី ៥

# អដ្ឋកថា ឧម្មគ្គសូត្រទី ៦

## *"អ្នកមានបញ្ញាវាងវៃ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧម្មគ្គសូត្រទី ៦ ដូចតទៅនេះ ៖*

[៣៦] *បទថា* ***បរិកស្សតិ*** *(នាំមក) បានដល់ អូសទាញមក ។ បទថា* ***ឧម្មគ្គោ*** *(បញ្ញា) បានដល់ ការផុសឡើង អធិប្បាយថា ការស៊ុះទៅនៃបញ្ញា ។ ម្យ៉ាងទៀត បញ្ញាទុំះឯង ហៅថា* ***ឧម្មគ្គៈ*** *ព្រោះអត្ថថា ផុសឡើង ឧម្មគ្គប្បញ្ញានោះ ឈ្មោះថា* ***បដិភាណ*** *ព្រោះអត្ថថា ដឹងច្បាស់ រហ័ស ។ បទថា* ***ចិត្តស្ស ឧប្បន្នស្ស វសំ គច្ឆតិ*** *(និងបុគ្គលធ្លាក់ចុះកាន់អំណាចរបស់ចិត្តដែលកើតឡើងហើយ) សេចក្តីថា បុគ្គលពួកណារមែងលុះក្នុងអំណាចចិត្ត គប្បីជ្រាប ការបញ្ជាក់ដល់បុគ្គលទាំងនោះក្នុងទីនេះ ។ បទថា* ***អត្ថមញ្ញាយ ធម្មមញ្ញាយ*** *(ដឹងទូទៅដល់អត្ថ ដឹងទូទៅដល់ធម៌) បានដល់ ដឹងអត្ថ និងបាលី ។ បទថា* ***ធម្មានុធម្មប្បដិបន្នោ ហោតិ*** *(ការបដិបត្តិធម៌សមគួរដល់ធម៌) សេចក្តីថា ជាអ្នកបដិបត្តិធម៌ដែលសមគួរដល់លោកុត្តរធម៌ គឺ បដិបទាជាចំណែកខាងដើម ព្រមដោយសីល ។ បទថា* ***និព្វេធិកប្បញ្ញោ*** *(មានបញ្ញាជម្រះកិលេស) បានដល់ មានបញ្ញាជាគ្រឿងកម្ចាត់កិលេស ។ បទថា* ***ឥទំ ទុក្ខំ*** *(នេះទុក្ខ) លោកអធិប្បាយថា ខន្ធ ៥*

ដែលប្រព្រឹត្តទៅក្នុងភូមិបីដ៏សេសវៀរតណ្ហា ជាទុក្ខ ។ បទថា **បញ្ញាយ** (ដោយបញ្ញា) គឺ ដោយមគ្គបញ្ញា ។ បទថា **អយំ ទុក្ខសមុទយោ** (នេះទុក្ខសមុទយៈ) លោកអធិប្បាយថា តណ្ហា ជាមូលនៃវដ្ដៈ ជាហេតុកើតទុក្ខនោះ ។ សូម្បីក្នុងពីរបទដ៏សេស គប្បីជ្រាបសេចក្តីដោយន័យនេះ ។ អរហត្តផល គប្បីជ្រាបថា ត្រាស់ដោយការឆ្លើយបញ្ហាប្រការទី ៤ ។

ចប់អដ្ឋកថា ឧម្មង្គសូត្រទី ៦

# អដ្ឋកថា វស្សការសូត្រទី ៧

## "វស្សការព្រាហ្មណ៍"

គប្បីជ្រាបវិនិច្ឆ័យក្នុង វស្សការសូត្រទី ៧ ដូចតទៅនេះ ៖

[៣៧] បទថា **តោទេយ្យស្ស** (តោទេយ្យៈ) គឺ ព្រាហ្មណ៍អ្នកស្រុកតុទិគ្រាម ។ បទថា **បរិសតិ** (ក្នុងបរិស័ទ) បានដល់ ក្នុងបរិស័ទដែលប្រជុំគ្នាហើយ ។ បទថា **បរូបារម្ភំ វត្តេតិ** (កើតការពោលតិះដៀលអ្នកដទៃ) បានដល់ ឲ្យការតិះដៀលប្រព្រឹត្តទៅ គឺ ពោលតិះដៀលអ្នកដទៃ ។ បទថា **ពាលោ អយំ រាជា** (ព្រះរាជា... ទ្រង់ជាបុគ្គលពាល) ជាអាទិ៍ លោកពោលដើម្បីសម្តែងពាក្យតិះដៀលដល់ជនទាំងនោះប្រព្រឹត្ត ។ បទថា **សមណេ រាមបុត្តេ** (ក្នុងសមណរាមបុត្ត) បានដល់ ឧទ្ទកតាបសរាមបុត្រ ។ បទថា **អភិប្បសន្នោ** (ជ្រះថ្លាក្រៃលែង) បានដល់ ជ្រះថ្លាខ្លាំង ។ បទថា **បរមនិបច្ចការំ** (ការគោរពយ៉ាងក្រៃលែង) បានដល់ កិរិយាដែលឱនលំទោនយ៉ាងក្រៃលែង គឺ ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **បរិហារកា** (ពួករាជបរិវារ) បានដល់ ពួកបរិវារ ។ បទជាដើមថា **យមកោ** (យមកៈ) ជាឈ្មោះរបស់បរិវារជនទាំងនោះ ។ ពិតហើយ បណ្តាបរិវារជនទាំងនោះ បុគ្គលម្នាក់ឈ្មោះយមកៈ ម្នាក់ឈ្មោះមោគ្គល្លាន ម្នាក់ឈ្មោះឧគ្គៈ ម្នាក់ឈ្មោះនាវិនាកី

ម្នាក់ឈ្មោះគន្ធព្វៈ ម្នាក់ឈ្មោះអគ្គិវេស្សៈ ។ បទថា **តេ អស្សុទំ** ក្នុងបទថា **ត្យស្សុទំ** (ចំណែក... បរិស័ទទាំងនោះ) នេះ ត្រឹមតែនិបាត ។ អធិប្បាយថា នូវបរិវារជនទាំងនោះដែលអង្គុយក្នុងបរិស័ទរបស់ខ្លួន ។ បទថា **ឥមិនា នយេន នេតិ** (ណែនាំ... ដោយន័យនេះថា) សេចក្ដីថា គោទេយ្យព្រាហ្មណ៍ត្រឡប់ណែនាំ គឺ ឲ្យគេដឹងដោយហេតុនេះ ។

បទថា **ករណីយាធិករណីយេសុ** (ក្នុងកិច្ចដែលគួរធ្វើ និងកិច្ចដែលគួរធ្វើដ៏ក្រៃលែង) បានដល់ ក្នុងកិច្ចដែលណ្ឌិតគួរធ្វើ និងកិច្ចដែលគួរធ្វើដ៏ក្រៃលែង ។ បទថា **វចនីយាធិវចនីយេសុ** បានដល់ ក្នុងពាក្យគួរពោល និងពាក្យគួរពោលដ៏ក្រៃលែង ។ ក្នុងបទថា **អលមត្ថទសតរេហិ** (ជាងអ្នកអាចសម្លឹងឃើញប្រយោជន៍) នេះ មានវិនិច្ឆ័យថា អ្នកអាចឃើញប្រយោជន៍ទាំងឡាយ ឈ្មោះថា **អលមត្ថទសា** អ្នកអាចឃើញប្រយោជន៍លើសជនជាបរិវារទាំងនោះ ឈ្មោះថា **អ្នកអាចឃើញប្រយោជន៍ច្រើនជាង** ។ ជាងជនទាំងនោះ ដែលអាចសម្លឹងឃើញប្រយោជន៍ ។ បទថា **អលមត្ថទសតរោ** (អាចសម្លឹងឃើញប្រយោជន៍ក្រៃលែងជាង) បានដល់ ព្រះបាទឯឡេយ្យៈជាអ្នកក្រៃលែងជាង ព្រោះអាចឃើញប្រយោជន៍ ។ គោទេយ្យព្រាហ្មណ៍កាលសួរថា "សមណរាមបុត្រជាអ្នកឆ្លាតជាងអ្នកឆ្លាតទាំងឡាយ ជាបណ្ឌិត

លើសបណ្ឌិតទាំងឡាយ" ទើបពោលយ៉ាងនេះ ។ ដូច្នេះ បរិវារទាំងនោះ កាលនឹងសាកសួរ ទើបពោលពាក្យជាដើមថា **ឯវំ ភោ** (យ៉ាងនោះឯង លោកដ៏ចម្រើន) ដល់តោទេយ្យព្រាហ្មណ៍នោះ ។ ដូច្នោះ ព្រាហ្មណ៍សរសើរព្រះបាទឯឡេយ្យៈខ្លះ បរិវាររបស់ព្រះបាទឯឡេយ្យៈនោះខ្លះ ឧទ្ទកតាបស-រាមបុត្រខ្លះ ព្រោះខ្លួនជាសប្បុរស ។ អសប្បុរស ដូចជាមនុស្សខ្វាក់ភ្នែក សប្បុរសដូចជាមនុស្សមានភ្នែកល្អ ។ មនុស្សខ្វាក់ រមែងមើលមិនឃើញទាំងមនុស្សមិនខ្វាក់ ទាំងមនុស្សខ្វាក់ យ៉ាងណា អសប្បុរសរមែងមិនដឹងទាំងសប្បុរស ទាំងអសប្បុរស ដូច្នោះ ។ មនុស្សភ្នែកល្អ រមែងឃើញទាំងមនុស្សខ្វាក់ ទាំងមនុស្សមិនខ្វាក់ យ៉ាងណា សប្បុរសរមែងដឹងទាំងសប្បុរស ទាំងអសប្បុរស ដូច្នោះ ។ ព្រាហ្មណ៍បានអាស្រ័យប្រយោជន៍នេះថា "សូម្បីតោទេយ្យព្រាហ្មណ៍ បានដឹងហើយនូវអសប្បុរសទាំងឡាយព្រោះជាសប្បុរស" ទើបមានចិត្តត្រេកអរ ពោលពាក្យជាអាទិ៍ថា **អច្ឆរិយំ ភោ គោតម** (បពិត្រព្រះគោតមដ៏ចម្រើន គួរអស្ចារ្យ) អនុមោទនាភាសិតរបស់ព្រះតថាគត ធ្វើសក្ការៈហើយ ក៏ត្រឡប់ទៅ ។

ចប់អដ្ឋកថា វស្សការសូត្រទី ៧

# អដ្ឋកថា ឧបកសូត្រទី ៨

## "ឧបកមណ្ឌិកាបុត្រ"

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបកសូត្រទី ៨ ដូចតទៅនេះ ៖

[៣៨] បទថា **ឧបកោ** (ឧបក:) ជាឈ្មោះរបស់មណ្ឌិកាបុត្រនោះ ។ បទថា **មណ្ឌិកាបុត្តោ** (មណ្ឌិកាបុត្រ) បានដល់ បុត្ររបស់នាងមណ្ឌិកា ។ បទថា **ឧបសង្កមិ** (ចូលទៅគាល់) សេចក្តីថា បានឮថា ឧបកមណ្ឌិកាបុត្រនោះ ជាឧបដ្ឋាករបស់ព្រះទេវទត្ត ចូលទៅគាល់ដើម្បីកំណត់ថា កាលយើងចូលទៅគាល់ ព្រះសាស្តានឹងត្រាស់សរសើរ ឬត្រាស់តិះដៀលហ្ន៎ អាចារ្យពួកខ្លះពោលថា ចូលទៅគាល់ បំណងនឹងស្តាប់ពាក្យថា ព្រះទេវទត្តធ្លាក់នរក តាំងនៅអស់មួយកប្ប នរណាក៏កែខៃមិនបាន ហើយនឹងបានសើកសៀតព្រះសាស្តា ។ បទថា **បរូបារម្ភំ វត្តេតិ** (ពោលតិះដៀលអ្នកដទៃ) បានដល់ ពោលតិះដៀលអ្នកដទៃ ។ បទថា **សព្វោ សោ ន ឧប្បាទេតិ** (ទាំងអស់នោះ រមែងមិនអាចឲ្យកុសលធម៌កើតឡើងបាន) សេចក្តីថា បុគ្គលទាំងអស់នោះ មិនធ្វើកុសលធម៌ឲ្យកើតឡើង ឬមិនអាចដើម្បីនឹងធ្វើពាក្យរបស់ខ្លួនដ៏សមគួរកើតឡើងបានឡើយ ។ បទថា **អនុប្បាទេន្តោ គារយ្ហោ ហោតិ** (កាលមិនអាចឲ្យកុសលធម៌កើតឡើងបាន រមែងជាអ្នកត្រូវតិះដៀល) សេចក្តី

ថា កាលមិនអាចឲ្យកុសលធម៌កើតឡើងបាន កាលមិនអាចធ្វើពាក្យរបស់ខ្លួនឲ្យសមគួរបាន ក៏រមែងជាអ្នកត្រូវតិះដៀល ។ បទថា **ឧបវជ្ជោ** (តិះដៀល) សេចក្តីថា រមែងជាបុគ្គលត្រូវតិះដៀលដូចគ្នា ឬជាបុគ្គលប្រកបដោយទោស អធិប្បាយថា មានទោស ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចាប់វាទៈរបស់ឧបកៈនោះហើយ ពាក់ត្រង់.កឧបកៈនោះឯង ទើបត្រាស់ថា **បរូបារម្ភំ** (តិះដៀលអ្នកដទៃ) ជាអាទិ៍ ។ បទថា **ឧម្មុជ្ជមានកំយេវ** (ពេលត្រីផុសឡើងប៉ុណ្ណោះ) បានដល់ លូមផុសក្បាលឡើងពីទឹកប៉ុណ្ណោះ ។ ក្នុងបទថា **តត្ថ អបរិមាណា បទា** (បទ... ក្នុងប្រការនោះរកប្រមាណមិនបាន) ជាអាទិ៍ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការបញ្ញត្តិពាក្យក្តី អក្ខរៈក្តី ធម៌ទេសនាក្តី ថា ជាកុសលក្នុងធម៌ប្រការនោះ រាប់មិនបានឡើយ ។ បទថា **ឥតិបីទំ អកុសលំ** (នេះជាអកុសលសូម្បីព្រោះហេតុនេះ) សេចក្តីថា សូម្បីបទទាំងឡាយដែលមកហើយក្នុងអកុសលបញ្ញត្តិយ៉ាងនេះថា នេះក៏អកុសល សូម្បីនេះជាអកុសល សូម្បីព្រោះហេតុនេះៗ ក៏អកុសល ក៏រាប់មិនបាន ។ សូម្បីដូច្នោះ ព្រះតថាគតគប្បីទ្រង់សម្តែងធម៌នោះ ដោយអាការមួយយ៉ាង ទេសនារបស់ព្រះអង្គយ៉ាងនេះ ក៏គប្បីរាប់មិនបាន ។ ដូចដែលលោកពោលថា ធម្មទេសនារបស់

ព្រះតថាគតនោះ កាន់យកមិនបានអស់ បទព្យញ្ជនៈនៃធម៌ក៏កាន់យកមិនបានអស់ សេចក្ដីក្នុងគ្រប់វារៈគប្បីជ្រាបដោយឧបាយនេះ ។

បទថា **យាវធំសីវតាយំ** (ក្មេងនេះ... បានមាត់បាន.ក) គឺ ក្មេងនេះពោលលុបលាងគុណ ។ **លោណការកទរកោ** (ក្មេងអ្នកស្រែអំបិល) គឺ ក្មេងក្នុងស្រុកធ្វើអំបិល ។ ពាក្យថា **យត្រ ហិ នាម** (ដូចម្ដេច) កែបទជា **យោ ហិ នាម** ។ បទថា **អបសាទេតព្វំ មញ្ញិស្សតិ** (នឹងសម្គាល់... ថាគួររុកកួន) គឺ នឹងសម្គាល់ព្រះពុទ្ធថា គួររុកកួន ។ បទថា **អបេហិ** (ចូរចេញទៅ) សេចក្ដីថា អ្នកចូរចេញទៅ កុំមកឈរនៅចំពោះមុខអញ ក៏ព្រះបាទអជាតសត្តុត្រាស់យ៉ាងនេះហើយ ទ្រង់ឲ្យបរិវារចាប់អូសកចេញទៅ ។

ចប់អដ្ឋកថា ឧបកសូត្រទី ៨

# អដ្ឋកថា សច្ឆិកិរិយសូត្រទី ៩

## *“ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយកាយជាដើម”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សច្ឆិកិរិយសូត្រទី ៩ ដូចតទៅនេះ ៖*

[៣៩] *បទថា* ***កាយេន*** *(ដោយកាយ) បានដល់ ដោយនាមកាយ ។ បទថា* ***សច្ឆិករណីយា*** *(ដែលគួរធ្វើឲ្យជាក់ច្បាស់) បានដល់ គប្បីធ្វើឲ្យប្រចក្ស ។ បទថា* ***សតិយា*** *(ដោយសតិ) បានដល់ ដោយបុព្វេនិវាសានុស្សតិ ។ បទថា* ***ចក្ខុនា*** *(ដោយចក្ខុ) គឺ ដោយទិព្វចក្ខុ ។ បទថា* ***បញ្ញាយ*** *(ដោយបញ្ញា) សេចក្តីថា វិបស្សនាបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយឈានបញ្ញា , មគ្គបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយវិបស្សនាបញ្ញា , ផលបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយមគ្គបញ្ញា , បច្ចវេក្ខណបញ្ញា គប្បីធ្វើឲ្យជាក់ច្បាស់ដោយផលបញ្ញា ។ អធិប្បាយថា គប្បីសម្រេច ។ ចំណែកព្រះអរហត្ត ពោលគឺ ការអស់អាសវៈ ឈ្មោះថា គប្បីធ្វើឲ្យជាក់ច្បាស់ដោយបច្ចវេក្ខណបញ្ញា ។*

ចប់អដ្ឋកថា សច្ឆិកិរិយាសូត្រទី ៩

# អដ្ឋកថា ឧបោសថសូត្រទី ១០

## *“ទ្រង់សរសើរភិក្ខុក្នុងថ្ងៃឧបោសថ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបោសថសូត្រទី ១០ ដូចតទៅនេះ ៖*

[៤០] *បទថា* ***តុណ្ហីភូតំ តុណ្ហីភូតំ*** *(ជាអ្នកស្ងៀមនៅ) សេចក្តីថា ព្រះមានព្រះភាគទ្រង់ក្រឡេកមើលទិសណាៗ ទិសនោះៗ ភិក្ខុសង្ឃក៏ស្ងប់-ស្ងៀមនោះឯង ។ បទថា* ***ភិក្ខូ អាមន្តេសិ*** *(ត្រាស់នឹងភិក្ខុទាំងឡាយ) សេចក្តីថា ទ្រង់ក្រឡេកមើលដោយព្រះចក្ខុដ៏ថ្លាស្អាតហើយ ទ្រង់កើតបាមោជ្ជៈក្នុងធម៌ ទើបត្រាស់នឹងភិក្ខុទាំងឡាយដែលដល់ព្រមដោយវត្តបដិបត្តិ ព្រោះទ្រង់បំណងនឹងលើកសរសើរធម៌ ។ បទថា* ***អប្បលាបា*** *(ស្ងៀម) បានដល់បរិស័ទវៀរការសន្ទនា ។ បទក្រៅពីនេះ ជាវេវចនៈរបស់បទថា* ***ស្ងៀម*** *នោះឯង ។ បទថា* ***សុទ្ធា*** *(បរិសុទ្ធ) គឺ អស់មន្ទិល ។ បទថា* ***សារេ បតិដ្ឋិតា*** *(តាំងនៅក្នុងសារៈ) បានដល់ តាំងនៅក្នុងធម្មសារៈ មានសីល-សារៈជាដើម ។ បទថា* ***អលំ*** *(ក៏គួរ) បានដល់ សមគួរ ។ បទថា* ***យោជនគណនានិ*** *(រាប់ដោយយោជន៍) សេចក្តីថា ចម្ងាយផ្លូវមួយយោជន៍ សូម្បី ១០ យោជន៍ ច្រើនជាងនោះ ក៏ហៅថា រាប់ជាយោជន៍ ។ តែក្នុងទីនេះបំណងយករយយោជន៍ខ្លះ ពាន់យោជន៍ខ្លះ ។ បទថា* ***បុដោសេនាបិ***

(ស្បៀងផ្លូវ) ស្បៀងដើរផ្លូវ អធិប្បាយថា សូម្បីនឹងត្រូវកាន់យកស្បៀងដើរផ្លូវចូលទៅរក ក៏គួរ ។ បាលីថា **បុដំសេន** ដូច្នេះក៏មាន ។ សេចក្តីរបស់បទនោះថា បន្ទិចរបស់មានហើយនៅត្រង់ស្មារបស់បុគ្គលនោះ ហេតុនោះ បុគ្គលនោះឈ្មោះថា មានបន្ទិចស្ពាយនឹងស្មា សំដៅដល់បន្ទិចនៅត្រង់ស្មានោះ ។ មានអធិប្បាយថា ស្ពាយស្បៀងដើរផ្លូវទៅ ។

ឥឡូវនេះ ត្រាស់ថា **សន្តិ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ... ក៏មាន) ជាអាទិ៍ ដើម្បីទ្រង់សម្តែងថា ភិក្ខុអ្នកប្រកបដោយគុណទាំងឡាយបែបនេះមាននៅក្នុងទីនេះ ។ បណ្តាបទទាំងនោះ បទថា **ទេវប្បត្តា** (ដល់ភាពជាទេវតា) បានដល់ ដល់ជាន់ទិព្វវិហារ ជាហេតុកើតជាឧប្បត្តិទេព និងជាន់ព្រះអរហត្តដោយទិព្វវិហារ ។ បទថា **ព្រហ្មប្បត្តា** (ដល់ភាពជាព្រហ្ម) បានដល់ ភិក្ខុទាំងឡាយដល់ជាន់ព្រហ្មវិហារ ហេតុសម្រេចជាព្រហ្ម ដោយអត្ថថា មិនមានទោស និងជាន់ព្រះអរហត្ត ដោយព្រហ្មវិហារ ។ បទថា **អានេញ្ជប្បត្តា** (ដល់ជាន់អានេញ្ជា) បានដល់ ដល់ជាន់អានេញ្ជា ជាហេតុសម្រេចសេចក្តីមិនញាប់ញ័រ និងជាន់ព្រះអរហត្តដោយអានេញ្ជា ។ បទថា **អរិយប្បត្តា** (ដល់ភាពជាអរិយៈ) បានដល់ កន្លងភាវៈបុថុជ្ជន ដល់ភាវៈជាព្រះអរិយៈ ។

ក្នុងបទថា *ឯវំ ខោ ភិក្ខវេ ភិក្ខុ ទេវប្បត្តោ ហោតិ* (យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុទើបឈ្មោះថា ដល់ភាពជាទេព) ជាអាទិ៍ មានវិនិច្ឆ័យដូច្នេះ ភិក្ខុតាំងនៅក្នុងចតុត្ថជ្ឈានដែលជារូបាវចរៈយ៉ាងនេះហើយ ទើបបង្អោនចិត្តទៅសម្រេចព្រះអរហត្ត ឈ្មោះថា ជាអ្នកដល់ភាពជាទេព ។ ភិក្ខុតាំងនៅក្នុងព្រហ្មវិហារ ៤ បង្អោនចិត្តទៅសម្រេចព្រះអរហត្ត ឈ្មោះថា ជាអ្នកដល់នូវភាពជាព្រហ្ម ។ តាំងនៅក្នុងអរូបឈាន ៤ បង្អោនចិត្តទៅសម្រេចព្រះអរហត្ត ឈ្មោះថា ជាអ្នកដល់នូវភាពជាអានេញ្ជា ។ មគ្គ ៤ និងផល ៣ ត្រាស់ដោយសច្ចៈ ៤ មានបទថា *ឥទំ ទុក្ខំ* (នេះទុក្ខ) ដូច្នេះ ជាអាទិ៍ ព្រោះដូច្នោះ ភិក្ខុអ្នកសម្រេចអរិយធម៌នេះ ទើបបានឈ្មោះថា ជាអ្នកដល់នូវភាពជាអរិយៈ ។

ចប់អដ្ឋកថា ឧទោសជសូត្រទី ១០

## ចប់យោធាជីវវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# មហាវគ្គវណ្ណនាទី ៥

## អដ្ឋកថា សោតានុគតសូត្រទី ១

### *"អានិសង្សនៃធម៌ដែលចូលដល់សោតប្បសាទ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោតានុគតសូត្រទី ១ ដូចតទៅនេះ ៖*

[៤១] *បទថា* ***សោតានុគតានំ*** *(ដែលចូលដល់សោតៈ) សេចក្ដីថា ធម៌ដែលបុគ្គលផ្ទៀងសោតប្បសាទស្ដាប់ ហើយកំណត់ដោយសោតញាណ ។ បទថា* ***ចត្តារោ អានិសំសា បាដិកង្ខា*** *(អានិសង្ស ៤ ប្រការ... ដែលបុគ្គលគប្បីប្រាថ្នាបាន) សេចក្ដីថា គុណានិសង្ស ៤ ប្រការ គប្បីប្រាថ្នាបាន ។ ព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ប្រារព្ធដោយអំណាចអត្ថុប្បត្តិ ហេតុកើតនៃរឿង ។ សួរថា ដោយអំណាចហេតុកើតនូវរឿងអ្វី ។ ឆ្លើយថា ដោយអំណាចហេតុកើតនូវរឿង គឺ កាលភិក្ខុទាំងឡាយ មិនចូលទៅស្ដាប់ធម៌ ។ បានឮថា ពួកព្រាហ្មណ៍ ៥០០ បួសហើយ មិនទៅស្ដាប់ធម៌ ដោយគិតថា ព្រះសម្ពុទ្ធ កាលត្រាស់ ក៏ត្រាស់តែលិង្គ វចនៈ វិភត្តិ បទ និងព្យញ្ជនៈជាដើម នឹងត្រាស់តែប្រការដែលពួកយើងដឹងហើយប៉ុណ្ណោះ ប្រការដែលយើងមិនទាន់ដឹង មិនត្រាស់អ្វីដែលយើងមិនទាន់បានដឹង ។ ព្រះសាស្ដាបានស្ដាប់រឿងនោះហើយ ទើបឲ្យហៅព្រាហ្មណ៍ដែលបួសទាំងនោះមក ហើយ*

ត្រាស់ថា ព្រោះអ្វីពួកអ្នកទើបធ្វើយ៉ាងនេះ ពួកអ្នកចូរស្តាប់ធម៌ដោយសេចក្តីគោរព កាលស្តាប់ធម៌ដោយសេចក្តីគោរព និងស្វាធ្យាយធម៌ដោយគោរព អានិសង្សទាំងនេះ នឹងជាទីប្រាថ្នាបាន កាលទ្រង់សម្តែង ទើបផ្តើមទេសនានេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ បរិយាបុណាតិ** (រមែងសិក្សាធម៌) សេចក្តីថា ភិក្ខុរមែងរៀនសូត្រធម៌ គឺ បាលី ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាមានអង្គ ៩ មានសុត្តៈ គេយ្យៈជាអាទិ៍ ។ បទថា **សោតានុគតា ហោន្តិ** (ជាធម៌ចូលដល់សោតៈ) សេចក្តីថា ធម៌ទាំងនោះ ក៏រមែងតាមទៅចូលកាន់សោតៈរឿយៗ ។ បទថា **មនសានុបេក្ខិតា** (តាំងចិត្តបានដល់ ពិចារណាដោយចិត្ត ។ បទថា **ទិដ្ឋិយា សុប្បដិវិទ្ធា** (ចាក់ធ្លុះដោយល្អដោយទិដ្ឋិ) បានដល់ យល់ចូលចិត្ត ចាក់ធ្លុះ គឺ ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាទាំងដោយផល ទាំងដោយហេតុ ។ ព្រះពុទ្ធវចនៈថា **មុដ្ឋស្សតិ កាលំ កុរុមានោ** (ភ្លេចសតិធ្វើមរណៈកាលទៅ) នេះ មិនមែនត្រាស់ព្រោះមិនមានសតិរលឹកដល់ តែត្រាស់សំដៅដល់ការស្លាប់របស់បុថុជ្ជន ។ ពិតហើយ បុថុជ្ជនឈ្មោះថា ស្លាប់ដោយការមិនមានសតិ ។ បទថា **ឧប្បជ្ជតិ** (រមែងចូលដល់) សេចក្តីថា ភិក្ខុតាំងនៅក្នុងសីលដែលបរិសុទ្ធហើយ រមែង

កើតក្នុងទេវលោក ។ បទថា **ធម្មបទាបិលបន្តិ** (បទនៃធម៌ទាំងឡាយរមែងប្រាកដ) សេចក្ដីថា ធម៌ គឺ ព្រះពុទ្ធវចនៈដែលចាំរត់មាត់ ដែលមានការស្វាធ្យាយជាមូលមកពីមុនទាំងអស់ រមែងកើតប្រាកដ ដឹងបានច្បាស់ដល់ភិក្ខុដែលមានសេចក្ដីសុខ កើតក្នុងចន្លោះភពដែលស្ងប់ ដូចស្រមោលក្នុងកញ្ចក់ ។ បទថា **ទន្ធោ ភិក្ខវេ សតុប្បាទោ** (សតិកើតឡើងយឺតយូរ) សេចក្ដីថា ការរលឹកដល់ព្រះពុទ្ធវចនៈកើតឡើងយឺតយូរ គឺ លំបាក ។ បទថា **អថ សោ សត្តោ ខិប្បមេវ**[១] **វិសេសគាមី ហោតិ** (តែចំពោះអ្នកមានសតិ រមែងជាអ្នកសម្រេចគុណវិសេសលឿនរហ័ស) សេចក្ដីថា រមែងសម្រេចព្រះនិព្វាន ។

បទថា **ឥទ្ធិមា ចេតោវសិប្បត្តោ** (អ្នកមានឫទ្ធិដល់នូវភាពជំនាញនៃចិត្ត) បានដល់ ព្រះខីណាស្រពដែលដល់ព្រមដោយឫទ្ធិ ដល់នូវភាពស្ទាត់ជំនាញនៃចិត្ត ។ វា សព្ទ ក្នុងបទថា **អយំ វា សោ ធម្មវិនយោ** (នេះគឺ ធម្មវិន័យនោះ) នេះ មានអត្ថថា ជាក់ច្បាស់ ។ បទថា **យត្ថ** (ក្នុងធម្មវិន័យណា) គឺ ក្នុងធម៌ និងវិន័យណា ។ បទថា **ព្រហ្មចរិយំ អចរឹ** (បានប្រព្រឹត្តព្រហ្មចរិយៈ) បានដល់ យើងបាននៅប្រព្រឹត្តព្រហ្មចរិយៈ ។

---

(១) បិដក = អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ ។

បទនោះ ទ្រង់ត្រាស់ដោយអំណាចការលើកដល់ព្រះពុទ្ធវចនៈថា ឈ្មោះថា ព្រះពុទ្ធវចនៈសូម្បីនេះ យើងក៏បានរៀនមកហើយអំពីមុន ។ បទថា **ទេវ-បុត្តោ** (ទេវបុត្ត) បានដល់ ទេវបុត្រដែលជាធម្មកថិកមួយអង្គ ដូចជា បញ្ចាលចណ្ឌទេវបុត្រ ហត្ថកមហាព្រហ្ម និងសនង្កុមារព្រហ្ម ។ បទថា **ឱបបាតិកោ ឱបបាតិកំ សារេតិ** (ទេវបុត្តដែលកើតមុនដាស់តឿនទេវបុត្តដែលកើតក្រោយ) សេចក្តីថា ទេវបុត្រអ្នកកើតមុន ឲ្យទេវបុត្រអ្នកកើតខាងក្រោយរលឹក ។ ទ្រង់សម្តែងភាពជាសម្លាញ់ទាំងនោះ ស្និទ្ធស្នាលនឹងគ្នាមកយូរហើយ ដោយបទថា **លេងដីជាមួយគ្នា** ។ បទថា **សមាគច្ឆេយ្យុំ** (មកជួបគ្នា) បានដល់ សម្លាញ់ទាំងនោះ គប្បីទៅព្រមគ្នាឯសាលាខ្លះ ត្រង់គល់ឈើខ្លះ ។ បទថា **ឯវំ វទេយ្យ** (គប្បីពោល) សេចក្តីថា សម្លាញ់ដែលអង្គុយមុនត្រង់សាលាខ្លះ ត្រង់គល់ឈើខ្លះ គប្បីពោលយ៉ាងនេះចំពោះសម្លាញ់ដែលមកខាងក្រោយ ។ បទដ៏សេសគ្រប់កន្លែង គប្បីជ្រាបដោយន័យដែលពោលមកហើយនោះឯង ។

ចប់អដ្ឋកថា សោតានុគតសូត្រទី ១

# អដ្ឋកថា ឋានសូត្រទី ២

## *"ឋានៈដែលគប្បីដឹង ៤ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានសូត្រទី ២ ដូចតទៅនេះ ៖*

[៩២] *បទថា* ***ឋានានិ*** *(ឋានៈ) គឺ ហេតុទាំងឡាយ ។ បទថា* ***ឋានេហិ*** *(ដោយឋានៈ) គឺ ដោយហេតុទាំងឡាយ ។ ភាពជាអ្នកស្អាត ឈ្មោះថា* ***សោចេយ្យំ*** *។ បទថា* ***សំវសមានោ*** *បានដល់ កាលនៅរួមគ្នា ។ បទថា* ***ន សតតការី ន សតតវុត្តី សីលេសុ*** *(មិនធ្វើជាប់តគ្នា មិនប្រព្រឹត្តជាប់តគ្នាក្នុងសីលទាំងឡាយ) សេចក្តីថា បុគ្គលនេះ នឹងមានជីវិតរស់នៅដោយសីលជាប់ជានិច្ចគ្រប់វេលា ក៏មិនមែន ។ បទថា* ***សំវោហរមានោ***[១] *(សន្ទនាហើយ) គឺ និយាយហើយ ។ បទថា* ***កេន ឯកោ វោហរតិ*** *(បុគ្គលនេះនិយាយជាមួយមនុស្សម្នាក់ ដោយឡែកផ្សេង) បានដល់ បុគ្គលនេះ និយាយជាមួយមនុស្សម្នាក់ផ្សេង ។ បទថា* ***វោក្កមតិ*** *គឺ ពោល ។ បទថា* ***បុរិមវោហារំ បច្ឆិមវោហារំ*** *(ពាក្យក្រោយខុសអំពីពាក្យមុន) គឺ បុគ្គលនេះនិយាយពាក្យក្រោយខុសពីពាក្យមុន ។ អធិប្បាយថា ពាក្យក្រោយជាមួយពាក្យមុន និងពាក្យមុនជាមួយពាក្យក្រោយមិនតគ្នា ។*

---

*(១) បិដក = សំវោហារមនោ ។*

ក្នុងបទជាដើមថា **ញាតិព្យសនេន** (ការវិនាសញាតិ) គឺ អធិប្បាយថា វិនាសញាតិ ។ សូម្បីក្នុងបទទីពីរក៏ន័យនេះឯង ។ ចំណែកក្នុងការវិនាសព្រោះរោគ រោគនោះឯង ឈ្មោះថា វិនាស ព្រោះធ្វើការមិនមានរោគឲ្យវិនាសទៅ ។ បទថា **អនុបរិវត្តន្តិ** (វិលទៅតាម) គឺ រមែងជាប់តាម ។ ក្នុងបទថា **លាភោ ច** (លាភ) ជាអាទិ៍ គប្បីនាំន័យទៅយ៉ាងនេះថា លាភរមែងប្រព្រឹត្តទៅតាមអត្តភាពមួយ ការវិនាសលាភរមែងប្រព្រឹត្តទៅតាមអត្តភាពមួយ ។ បទថា **សាកច្ឆាយមានោ** (សន្ទនា) បានដល់កាលធ្វើការសន្ទនាដោយអំណាចការសួរ និងការឆ្លើយបញ្ហា ។ បទថា **យថា** (យ៉ាងណា) បានដល់ ដោយអាការណា ។ បញ្ហាក្នុងការឆ្លើយបញ្ហាឈ្មោះថា **ឧមង្គោ** (ភាពជ្រាលជ្រៅ) ។ អភិនិហារនៃចិត្តដោយអំណាចការតែងបញ្ហា ឈ្មោះថា **អភិនិហារ** ។ ការសួរបញ្ហា ឈ្មោះ **សមុទាហារោ**[១] (ការសួរបញ្ហា) ។ បទថា **សន្តំ** (ដែលស្ងប់) សេចក្ដីថា មិនពោលឲ្យស្ងប់ដោយស្ងប់សត្រូវ ។ បទថា **បណីតំ** (ប្រណីត) បានដល់ ដ៏ឧត្តម ។ បទថា **អតក្កាវចរំ** (សាមញ្ញជនមិនគប្បីស្ទង់ប្រមើល) សេចក្ដីថា បុគ្គលនេះមិនពោលដោយប្រការដែលមិនអាចកាន់យកបាន ដោយការប៉ាន់ស្មាន ។ បទថា

(១) បិដក = សមុទាចារោ ។

*__និបុណំ__ (ល្អិត) បានដល់ ល្អិតក្រៃលែង ។ បទថា __បណ្ឌិតវេទនីយំ__ (ដែលបណ្ឌិតគប្បីដឹងបាន) បានដល់ ដែលពួកបណ្ឌិតគប្បីដឹងបាន ។ បទដ៏សេសក្នុងទីគ្រប់កន្លែង គប្បីជ្រាបដោយទំនងដូចពោលហើយនុ៎ះឯង ។*

ចប់អដ្ឋកថា ឋានសូត្រទី ២

# អដ្ឋកថា ភទ្ទិយសូត្រទី ៣

## *“ស្តេចលិច្ឆវីព្រះនាមថា ភទ្ទិយៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភទ្ទិយសូត្រទី ៣ ដូចតទៅនេះ ៖*

*[៤៣] បទថា* ***ឧបសង្កមិ*** *(ចូលទៅគាល់) សេចក្តីថា ស្តេចភទ្ទិយ-លិច្ឆវី បរិភោគអាហារព្រឹកស្រេចហើយ កាន់ផ្កាឈើ គ្រឿងក្រអូប និង គ្រឿងលាប ចូលទៅគាល់ដោយគិតថា យើងនឹងថ្វាយបង្គំព្រះមានព្រះភាគ ។ ក្នុងបទថា មក* ***អនុស្សវេន*** *(កុំទាន់ជឿដោយត្រឹមតែបានស្តាប់តាមគ្នាមក) ជាអាទិ៍ គប្បីជ្រាបដោយន័យនេះថា លោកទាំងឡាយកុំទាន់ជឿពាក្យរបស់ យើង ដោយអំណាចការស្តាប់តាមគ្នាមក ។ បទថា* ***សារម្ភោ*** *(ការវាយ ឫក្សស្មើ) បានដល់ ការវាយឫក្សស្មើដែលជាលក្ខណៈប្រណាំងប្រជែង ។ ធម៌ មានការមិនលោភជាដើម គប្បីជ្រាបដោយន័យដែលផ្ទុយគ្នានឹងសេចក្តី លោភជាដើម ។ បទថា* ***កុសលធម្មូបសម្បទាយ*** *(បំពេញកុសលធម៌) បានដល់ ដើម្បីបំពេញកុសលធម៌ឲ្យដល់ព្រម លោកអធិប្បាយថា ដើម្បី ឲ្យបានកុសលធម៌ ។ បទថា* ***ឥមេ ចេបិ ភទ្ទិយ មហាសាលា*** *(ភទ្ទិយៈ សូម្បីពួកដើមសាលៈធំទាំងនេះ) សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់ សម្តែងដើមសាលៈដែលដុះនៅខាងមុខ ទើបត្រាស់យ៉ាងនេះ ។ បទដ៏សេស*

*ក្នុងសូត្រនេះ ក៏ដឹងបានងាយ ព្រោះមានន័យដូចពោលហើយក្នុងខាងក្រោយ និងព្រោះមានអត្ថងាយ ។ តែកាលព្រះសាស្តាទ្រង់លើកឡើងទេសនា ស្តេចភទ្ទិយៈ ក៏បានសម្រេចជាព្រះសោតាបន្នបុគ្គល ។*

ចប់អដ្ឋកថា ភទ្ទិយសូត្រទី ៣

# អដ្ឋកថា សាបុគិយាសូត្រទី ៤

## *"កោឡិយបុត្រអ្នកនិគមសាបុគៈ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាបុគិយសូត្រទី ៤ ដូចតទៅនេះ ៖*

*[៤៤] បទថា* ***សាបុគិយា*** *បានដល់ កុលបុត្រអ្នកនិគមសាបុគៈ ។ បទថា* ***ព្យគ្ឃបជ្ជ*** *(ព្យគ្ឃបជ្ជៈទាំងឡាយ) ព្រះអានន្ទកាលហៅកោឡិយបុត្រទាំងនោះ ទើបពោលយ៉ាងនេះ ។ ពិតហើយ កោឡនគរ មានពីរឈ្មោះ គឺ នគរកោឡៈ ព្រោះគេនាំឈើក្រពៅមកសាង ១ ឈ្មោះថា ព្យគ្ឃបជ្ជៈ ព្រោះគេសាងក្នុងផ្លូវខ្លាធ្លង ១ ។ បុព្វបុរសរបស់អ្នកស្រុកកោឡិយៈទាំងនោះ អាស្រ័យនៅក្នុងព្យគ្ឃបជ្ជនគរនោះ ព្រោះដូច្នោះ លោកហៅថា ព្យគ្ឃបជ្ជៈ ព្រោះអាស្រ័យនៅក្នុងព្យគ្ឃបជ្ជនគរ ។ ដោយហេតុនោះ ព្រះអានន្ទកាលហៅអ្នកកោឡិយៈទាំងនោះ ទើបពោលយ៉ាងនេះ ។*

*បទថា* ***បារិសុទ្ធិបធានិយង្គានិ*** *(អង្គជាទីតាំងនៃសេចក្តីព្យាយាមដើម្បីសេចក្តីបរិសុទ្ធ) បានដល់ អង្គជាទីតាំងនៃសេចក្តីព្យាយាមដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធិ អធិប្បាយថា អង្គ គឺ ចំណែកនៃសេចក្តីព្យាយាមដែលគួរតាំងទុក ។ បទថាសីល* ***សីលបារិសុទ្ធិបធានិយង្គំ*** *(អង្គជាទីតាំងនៃសេចក្តីព្យាយាម គឺ សីលបារិសុទ្ធិ) នេះ ជាឈ្មោះនៃសេចក្តីព្យាយាមដែល*

ញ៉ាំងសីលឲ្យបរិសុទ្ធ ។ ពិតហើយ បារិសុទ្ធិបធានិយង្គៈនោះ ជាអង្គ ជាទីតាំងនៃសេចក្តីព្យាយាម ដើម្បីឲ្យសេចក្តីបរិសុទ្ធិនៃសីលពេញបរិបូរ ព្រោះហេតុនោះ ទើបឈ្មោះថា អង្គជាទីតាំងនៃសេចក្តីព្យាយាម គឺ សីលបារិ-សុទ្ធិសីល ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។

បទថា **តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** (យើងនឹងប្រើបញ្ញារក្សា... ក្នុងឋានៈនោះៗ) សេចក្តីថា យើងនឹងរក្សាដោយវិបស្សនាបញ្ញាទុកក្នុងទីនោះៗ ។ ក្នុងបទថា **យោ តត្ថ ឆន្ទោ** (សេចក្តីពេញចិត្ត... នោះ) ជាដើម គប្បីជ្រាបសេចក្តីដោយន័យនេះថា សេចក្តីពេញចិត្ត គឺ សេចក្តីប្រាថ្នាធ្វើក្នុងការរក្សានោះ យ៉ាងណា ក៏សតិ សម្បជញ្ញៈ លោកពោលក្នុងទីនេះ ដើម្បីឲ្យភិក្ខុចូលទៅតាំងសតិទុក ហើយកំណត់ដោយញាណ ញ៉ាំងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ ។ បទថា **រជនីយេសុ ធម្មេសុ ចិត្តំ វិរាជេតិ** (រមែងនឿយណាយក្នុងធម៌ដែលជាទីតាំងនៃតម្រេក) សេចក្តីថា រមែងធ្វើដោយអាការដែលចិត្តប្រាសចាកតម្រេកក្នុងឥដ្ឋារម្មណ៍ ដែលជាបច្ច័យនៃរាគៈ ។ បទថា **វិមោចនីយេសុ ធម្មេសុ ចិត្តំ វិមោចេតិ** (ដោះចិត្តក្នុងធម៌ដែលគួរដោះ) សេចក្តីថា រមែងធ្វើចិត្តឲ្យរួចស្រឡះចាកអារម្មណ៍ ដែលចិត្តគួរនឹងរួចផុត ។ ក្នុងបទថា **វិរាជេត្វា** (លុះប្រាសចាកហើយ) នេះ ក្នុង

*ខណៈនៃមគ្គ ឈ្មោះថា កំពុងប្រាសចាក ក្នុងខណៈនៃផល ឈ្មោះថា ប្រាសចាកហើយ ។ សូម្បីក្នុងបទទីពីរ ក៏ន័យនេះដូចគ្នា ។ បទថា* ***សម្មាវិមុត្តឹ ផុសតិ*** *(រមែងពាល់ត្រូវសម្មាវិមុត្តិ) បានដល់ រមែងពាល់ត្រូវអរហត្តផលវិមុត្តិ តាមហេតុ តាមន័យ ដោយញាណផស្សៈ ។*

ចប់អដ្ឋកថា សាបុគិយាសូត្រទី ៤

# អដ្ឋកថា វប្បសូត្រទី ៥

## *“ស្ដេចវប្បសក្យៈ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វប្បសូត្រទី ៥ ដូចតទៅនេះ ៖*

[៨៥] *បទថា* ***វប្បោ*** *(ព្រះនាមថាវប្បៈ) បានដល់ ស្ដេចសក្យៈ ដែលជាស្ដេចពូរបស់ព្រះទសពល ។ បទថា* ***និគណ្ឋសាវកោ*** *(សាវករបស់និគ្រន្ថ) បានដល់ ជាឧបដ្ឋាករបស់និគណ្ឋនាដបុត្រ ដូចជាសីហសេនាបតីក្នុងក្រុងវេសាលី និងដូចជាឧបាលិគហបតីក្នុងក្រុងនាឡន្ទា ។ បទថា* ***កាយេន សំវុតោ*** *(សង្រួមដោយកាយ) សេចក្ដីថា ឈ្មោះថា សង្រួមកាយ ព្រោះសង្រួម គឺ បិទកាយទ្វារ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***អវិជ្ជាវិរាគា*** *(ព្រោះអវិជ្ជារលត់ទៅ) បានដល់ ព្រោះអវិជ្ជាប្រាសទៅ ។ បទថា* ***វិជ្ជុប្បាទា*** *(វិជ្ជាកើតឡើង) បានដល់ ព្រោះមគ្គវិជ្ជាកើតឡើង ។ បទថា* ***តំ ឋានំ*** *(ឋានៈ) បានដល់ ហេតុនោះ ។ បទថា* ***អវិបក្កវិបាកំ*** *(ដែលនៅឲ្យផលមិនទាន់អស់) បានដល់ មិនទាន់ដល់ភាវៈបានទទួលផល ។ បទថា* ***តតោនិទានំ*** *(ព្រោះមានបាបកម្មជាហេតុ) បានដល់ ព្រោះមានកម្មនោះជាហេតុ មានបាបកម្មនោះជាបច្ច័យ ។ បទថា* ***ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ*** *(អាសវៈទាំងឡាយដែលជាបច្ច័យនៃទុក្ខវេទនា*

គប្បីទៅតាមបុគ្គល) សេចក្តីថា កិលេសទាំងឡាយដែលជាបច្ច័យនៃទុក្ខ-វេទនា គប្បីហូរទៅតាម គឺ គប្បីចូលទៅតាម អធិប្បាយថា កិលេសទាំងឡាយគប្បីកើតឡើងដល់បុរសនោះ ។ បទថា **អភិសម្បរាយំ** (ក្នុងសម្បរាយភព) បានដល់ ក្នុងអត្តភាពទីពីរនោះឯង ។ បទថា **កាយសមារម្ភបច្ចយា** (ព្រោះការធ្វើផ្លូវកាយជាបច្ច័យ) បានដល់ ព្រោះកាយកម្មជាបច្ច័យ ។ បទថា **អាសវា** (អាសវៈ) បានដល់ កិលេសទាំងឡាយ ។ ក្នុងបទថា **វិឃាតបរិឡាហា** (កងទុក្ខ សេចក្តីក្តៅក្រហាយ) នេះ មានវិនិច្ឆ័យថា ទុក្ខ ឈ្មោះថា វិឃាតៈ សេចក្តីក្តៅក្រហាយផ្លូវកាយ និងផ្លូវចិត្ត ឈ្មោះថា បរិឡាហៈ ។ បទថា **ផុស្ស ផុស្ស ព្យន្តីករោតិ** (ទទួលផលកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង) សេចក្តីថា កម្មដែលញាណនឹងគប្បីសម្លាប់ ពេលប៉ះខ្ទប់ញាណហើយក៏អស់ទៅ កម្មដែលវិបាកនឹងគប្បីសម្លាប់ ពេលប៉ះខ្ទប់វិបាកហើយក៏អស់ទៅ ។ បទថា **និជ្ជរា** (បដិបទាដុតកិលេសឲ្យវិនាស) បានដល់ បដិបទាដែលធ្វើកិលេសឲ្យទ្រោមទៅ ។ សូម្បីក្នុងវារៈដ៏សេសក៏ន័យនេះដូចគ្នា ។ ភិក្ខុនេះតាំងនៅក្នុងបដិបទានេះគួរជាព្រះខីណាស្រព ។ គួរនាំមហាភូតរូប ៤ ចេញ ហើយសម្តែងការកំណត់ដោយអរិយសច្ចៈ ៤ ហើយគប្បីប្រាប់កម្មដ្ឋានរហូតដល់អរហត្តផល ។

ក៏ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសត្តវិហារធម៌ (ធម៌ជាគ្រឿងនៅជានិច្ច) របស់ព្រះខីណាស្រពនោះ ទើបត្រាស់បទមានជាអាទិ៍ថា **ឯវំ សម្មាវិមុត្តចិត្តស្ស** (មានចិត្តរួចផុតដោយល្អយ៉ាងនេះហើយ) ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សម្មាវិមុត្តស្ស** (រួចផុតដោយប្រពៃ) បានដល់ ផុតហើយដោយប្រពៃ ដោយហេតុ ដោយការណ៍ ដោយន័យ ។ បទថា **សត្តវិហារា** (ធម៌ជាគ្រឿងនៅជានិច្ច) បានដល់ ធម៌ជាគ្រឿងនៅជានិច្ច ធម៌ជាគ្រឿងនៅជាប្រចាំ ។ បទថា **នេវ សុមនោ ហោតិ** (មិនត្រេកអរ) បានដល់ ជាអ្នកមិនកើតសោមនស្សដោយអំណាចតម្រេកក្នុងឥដ្ឋារម្មណ៍ ។ បទថា **ន ទុម្មនោ** (មិនទាស់ចិត្ត) បានដល់ ជាអ្នកមិនកើតទោមនស្សដោយអំណាចការថ្នាំងថ្នាក់ចិត្តក្នុងអនិដ្ឋារម្មណ៍ ។ បទថា **ឧបេក្ខកោ វិហរតិ សតោ សម្បជានោ** (មានឧបេក្ខា មានសតិសម្បជញ្ញៈ) បានដល់ ជាបុគ្គលមានឧបេក្ខា មានភាពជាកណ្តាលក្នុងអារម្មណ៍ទាំងនោះ ដោយឧបេក្ខាដែលមានអាការជាកណ្តាលជាលក្ខណៈ និងមានសតិសម្បជញ្ញៈរក្សា ។

បទថា **កាយបរិយន្តិកំ** (មានកាយជាទីបំផុត) បានដល់ វេទនាមានកាយជាទីបំផុត គឺ កំណត់ដោយកាយ អធិប្បាយថា វេទនាប្រព្រឹត្តទៅក្នុង

ទ្វារ ៥ នៅប្រព្រឹត្តទៅជានិច្ច ជរាបទ្វារ ៥ នៅប្រព្រឹត្តទៅ ។ បទថា **ជីវិតបរិយន្តិកំ** (មានជីវិតជាទីបំផុត) បានដល់ វេទនាមានជីវិតជាទីបំផុត គឺ កំណត់ដោយជីវិត អធិប្បាយថា វេទនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ នៅប្រព្រឹត្តទៅជានិច្ច ជរាបដែលជីវិតនៅប្រព្រឹត្តទៅ ។ ក្នុងវេទនាទាំងនោះ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ កើតពេលក្រោយតែរលត់មុន ។ វេទនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ កើតមុនតែរលត់ក្រោយ ។ ព្រោះវេទនានោះតាំងនៅក្នុងវត្ថុរូបក្នុងខណៈបដិសន្ធិ ។ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ នៅប្រព្រឹត្តទៅ ដោយអំណាចបញ្ចទ្វារក្នុងបច្ចុប្បន្ន គ្រាមានអាយុ ២០ ឆ្នាំ ក្នុងបឋមវ័យ រមែងមានកម្លាំងខ្លាំងដោយអំណាចសេចក្តីស្រឡាញ់ សេចក្តីក្រោធ និងសេចក្តីវង្វេង , លុះមានអាយុ ៥០ ឆ្នាំ ក៏នៅមាំទាំ នឹងអន់ថយតាំងពីអាយុ ៦០ ឆ្នាំ លុះអាយុ ៨០-៩០ ឆ្នាំ ក៏ទន់ទៅព្រម ព្រោះថាក្នុងគ្រានោះ សត្វទាំងឡាយសូម្បីកាលមានអ្នកពោលថា ពួកយើងអង្គុយដេករួមគ្នាមកយូរហើយ ក៏និយាយថា យើងមិនដឹង ដូច្នេះក៏មាន និយាយថា យើងមិនឃើញអារម្មណ៍ មានរូបជាដើម សូម្បីមានប្រមាណច្រើន យើងមិនបានឮ យើងមិនដឹងក្លិនក្រអូប ក្លិនស្អុយ រសឆ្ងាញ់ រសមិនឆ្ងាញ់ ឬរឹងទន់ ដូច្នេះក៏មាន ។ វេទនាប្រព្រឹត្តទៅក្នុងទ្វារ ៥ របស់សត្វទាំងនោះ

ដល់នូវកាលរលត់ទៅ តែវេទនាប្រព្រឹត្តទៅក្នុងមនោទ្វារ ក៏នៅប្រព្រឹត្តទៅដោយប្រការដូច្នេះ ។ វេទនានោះ វិនាសទៅដោយលំដាប់ ក្នុងវេលាជិតស្លាប់អាស្រ័យចំណែករបស់ហទយវត្ថុប៉ុណ្ណោះ នៅប្រព្រឹត្តទៅបាន ។ ក៏វេទនានោះ នៅប្រព្រឹត្តទៅបានត្រឹមណា លោកពោលថា សត្វនៅមានជីវិតត្រឹមនោះ ។ កាលណាវេទនាប្រព្រឹត្តទៅមិនបាន កាលនោះ លោកពោលថា សត្វស្លាប់ហើយ រលត់ហើយ ។

គប្បីឧបមាសេចក្តីនោះដោយត្រពាំងទឹក ។ ឧបមាថា បុរសគប្បីធ្វើត្រពាំងទឹកឲ្យមានផ្លូវទឹក ៥ កាលភ្លៀង ធ្លាក់គ្រាដំបូង ទឹកក៏ហូរចូលទៅតាមផ្លូវទឹកទាំង ៥ ហើយក៏ដក់ពេញអណ្តូងនៅក្នុងត្រពាំងនោះ ។ កាលភ្លៀងធ្លាក់រឿយៗ ទឹកពេញក្នុងផ្លូវទឹក ហើយប្រាលចេញទៅប្រមាណមួយគាវុត ឬកន្លះយោជន៍ ហូរទៅដក់នៅតាមទីនោះៗ កាលអ្នកស្រែបើកក្បឿធ្វើស្រែ ទឹកក៏ហូរចេញ កាលស្រូវចាស់ដើម ទឹកហូរចេញអស់ ទឹកក៏រីងស្ងួតទៅ អ្នកស្រែក៏និយាយថា “យើងនឹងចាប់ត្រី” បន្ទាប់ពីនោះកន្លងទៅ ២-៣ ថ្ងៃ ទឹកក៏ដក់នៅតែក្នុងអណ្តូងប៉ុណ្ណោះ ក៏ដរាបណាទឹកនោះនៅមានក្នុងអណ្តូង ដរាបនោះក៏រាប់បានថា ទឹកនៅមានក្នុងត្រពាំង តែកាលណាទឹកក្នុងអណ្តូងនោះរីងអស់ កាលនោះ ក៏ហៅបានថា ទឹកមិនមានក្នុងត្រពាំង

យ៉ាងណា ការឧបមេយ្យនេះ គប្បីជ្រាបដូច្នោះ ។

វេលាដែលវេទនាប្រព្រឹត្តទៅក្នុងមនោទ្វារ តាំងនៅក្នុងវត្ថុរូប ក្នុងខណៈបដិសន្ធិគ្រាដំបូង ដូចវេលាដែលភ្លៀងធ្លាក់គ្រាដំបូង កាលទឹកហូរចូលទៅដោយផ្លូវទាំង ៥ អណ្ដូងក៏ពេញ វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ក្នុងបវត្តិកាល ក៏ប្រព្រឹត្តទៅបាន ដូចវេលាដែលភ្លៀងធ្លាក់រឿយៗ ទឹកពេញផ្លូវទាំង ៥ ដូចវេទនានោះមានកម្លាំងខ្លាំង ដោយអំណាចរាគៈជាដើម លុះដល់មានអាយុ ២០ ឆ្នាំ ក្នុងបឋមវ័យ ដូចដែលទឹកប្រាលលិចទីវាលប្រមាណមួយគាវុត និងកន្លះយោជន៍ វេលាវេទនានោះនៅមាំទាំក្នុងគ្រាដែលមានអាយុ ៥០ ឆ្នាំ ដូចវេលាដែលទឹកមិនហូរចេញ ដក់នៅពេញក្នុងត្រពាំងទឹក វេទនាទ្រុឌទ្រោមតាំងពីវេលាដែលមានអាយុ ៦០ ឆ្នាំ ដូចវេលាដែលទឹកហូរចេញ លុះបើកភ្លឺធ្វើស្រែ វេលាដែលវេទនាប្រព្រឹត្តទៅក្នុងទ្វារ ៥ ខ្សោយចុះ កាលមានអាយុ ៨០-៩០ ឆ្នាំ ដូចវេលាដែលកាលទឹករីងស្ងួត ទឹកមាននៅសល់បន្តិចបន្តួចត្រង់ផ្លូវទឹក វេលាដែលវេទនាក្នុងមនោទ្វារនៅប្រព្រឹត្តទៅបាន ព្រោះអាស្រ័យចំណែកនៃហទយវត្ថុ ដូចវេលាដែលទឹកដក់នៅក្នុងអណ្ដូងនុ៎ះឯង ដរាបណាដែលវេទនានោះ នៅប្រព្រឹត្តទៅបាន ដរាបនោះ ហៅបានថា សត្វនៅមានជីវិត ដូចវេលាដែលគួរនឹងនិយាយបាន

ថា កាលក្នុងអណ្តូងមានទឹកសូម្បីបន្តិចបន្តួច ទឹកក្នុងត្រពាំងក៏នៅមាន ។ ក៏កាលទឹកក្នុងអណ្តូងរីងអស់ ក៏ហៅបានថា មិនមានទឹកក្នុងត្រពាំងទឹក យ៉ាងណា កាលវេទនាប្រព្រឹត្តទៅក្នុងមនោទ្វារមិនបាន ក៏ហៅបានថា សត្វស្លាប់ហើយ ដូច្នោះ ។ បទថា **កាលសោយវេទនាមានជីវិតជាទីបំផុត** ត្រាស់សំដៅដល់វេទនានេះឯង ។

បទថា **កាយស្ស ភេទា** (កាលកាយបែកធ្លាយ) បានដល់ ព្រោះកាយបែកធ្លាយ ។ បទថា **ឧទ្ធំ ជីវិតបរិយាទានា** (អស់ជីវិតទៅ) បានដល់ខាងមុខពីអស់ជីវិតទៅ ។ បទថា **ឥធេវ** (ក្នុងលោកនេះ) បានដល់ ក្នុងលោកនេះប៉ុណ្ណោះ មិនទៅកាន់លោកខាងមុខដោយអំណាចបដិសន្ធិ ។ បទថា **សីតិ ភវិស្សន្តិ** (នឹងជារបស់ត្រជាក់) បានដល់ វេទនាទាំងពួង វៀរចាកការប្រព្រឹត្តទៅ សេចក្តីលំបាក និងសេចក្តីខ្វល់ខ្វាយ ក៏ជារបស់ត្រជាក់មានការមិនប្រព្រឹត្តទៅជាធម្មតា ។

បទថា **ថូណំ បដិច្ច** (ព្រោះអាស្រ័យដើមឈើ) បានដល់ អាស្រ័យដើមឈើ ។ បទថា **កុទ្ទាលបិដកំ អាទាយ** (កាន់ចប និងកញ្ជើមក) សេចក្តីថា កាន់ចប និងបង្គី តែទេសនាលោកបំណាងដល់ចបប៉ុណ្ណោះ ។ បទថា **មូលេ ឆិន្ទេយ្យ** (កាត់... ត្រង់គល់) បានដល់ យកចបជីកផ្តាច់ត្រង់គល់ ។

បទថា **បលិខណេយ្យ** (ជីកកកាយ) បានដល់ យកចបជីកដោយជុំវិញ ។

ក្នុងបទថា **ឯវមេវ ខោ** (ដូច្នោះដូចគ្នា) នេះ ប្រៀបដោយឧបមាដូច្នេះ អត្តភាព គប្បីឃើញដូចដើមឈើ កុសលកម្ម និងអកុសលកម្ម ដូចស្រមោលអាស្រ័យដើមឈើ ព្រះយោគាវចរ ដូចបុរសអ្នកបំណងនឹងធ្វើស្រមោលមិនឲ្យប្រព្រឹត្តទៅ បញ្ញា ដូចចប សមាធិ ដូចកញ្ច្រែ វិបស្សនាដូចការជីក វេលាដែលកាត់អវិជ្ជាដោយអរហត្តមគ្គ ដូចវេលាដែលយកចបជីកផ្តាច់ឫស វេលាដែលឃើញជាគំនរ ដូចវេលាដែលធ្វើឲ្យជាកំណាត់តូចៗ វេលាដែលឃើញជាអាយតនៈ ដូចវេលាដែលពុះចេញ វេលាដែលឃើញជាធាតុ ដូចវេលាដែលធ្វើឲ្យជាកម្ទេច វេលាដែលធ្វើការព្យាយាមផ្លូវកាយផ្លូវចិត្ត ដូចវេលាដែលហាលឲ្យស្ងួតដោយខ្យល់ និងកំដៅថ្ងៃ វេលាដែលដុតកិលេសដោយញាណ ដូចវេលាដែលយកភ្លើងដុត វេលាដែលខន្ធ ៥ ស្ថិតនៅ ដូចវេលាដែលធ្វើឲ្យជាលំអងផេះ ការរលត់ខន្ធ ៥ ដែលមានឫសដាច់ហើយដោយមិនមានបដិសន្ធិ ដូចវេលាដែលរោយទៅក្នុងខ្យល់ខ្លាំង ដូចវេលាដែលបណ្តែតទៅក្នុងក្រសែទឹក ការមិនមានបញ្ញត្តិព្រោះវិបាកខន្ធមិនកើតក្នុងភពថ្មី គប្បីជ្រាប ដូចការចូលទៅកាន់ការមិនមានបញ្ញត្តិ ព្រោះរោយទៅតាមខ្យល់ និងបណ្តែតទៅតាមទឹក ដូច្នោះ ។

បទថា **ភគវន្តំ ឯតទវោច** (បានក្រាបទូលព្រះមានព្រះភាគ) សេចក្ដីថា កាលព្រះសាស្ដាទ្រង់បញ្ចប់ទេសនា វប្បសក្យរាជក៏បានសម្រេចសោតាបត្តិផល ហើយបានក្រាបទូលពាក្យជាដើមថា "បពិត្រព្រះអង្គដ៏ចម្រើន... សូម្បីយ៉ាងណា" ។ ក្នុងបទទាំងនោះ បទថា **ឧទ្រយត្ថិកោ**(១) (ត្រូវការផល) គឺ ត្រូវការផលកម្រៃ ។ បទថា **អស្សបណិយំ បោសេយ្យ** (ចិញ្ចឹមកូនសេះទុកលក់) សេចក្ដីថា ចិញ្ចឹមដោយគិតថា "យើងនឹងទិញកូនសេះ ៥០០ ក្បាល" ហើយនឹងលក់ជាខាងក្រោយ ។ ត្រូវប្រើគ្រឿងឧបករណ៍ប្រមាណ ៥០០ ជាតម្លៃថែរក្សាសេះដែលមានតម្លៃមួយពាន់ មានគ្រឿងក្រអូប និងផ្កាឈើជាដើម ។ តមក សេះទាំងនោះរបស់គេ កើតរោគក្នុងមួយថ្ងៃប៉ុណ្ណោះ ក៏ស្លាប់អស់ ព្រោះហេតុនោះ ទើបគេពោលយ៉ាងនេះ ។ បទថា **ឧទ្រយស្សេវ នាភិគច្ឆេយ្យ** (ខាតដើម) បានដល់ មិនបានទាំងផល ទាំងដើមក៏ត្រូវអស់ទៅ ។ បទ **បយិរុបាសី** (សេពគប់រក) បានដល់ ទំនុកបម្រុងដោយបច្ច័យ ៤ ។ បទថា **សោហំ ឧទ្រយស្សេវ នាភិគច្ឆិំ** (ខ្ញុំព្រះអង្គ... ត្រូវខាតទុន) សេចក្ដីថា ខ្ញុំព្រះអង្គមិនបានផល ទាំងខាតទុនទៀតផង ។ លោកសម្ដែងថា យើងឈ្មោះថា ជាមនុស្សចិញ្ចឹមសេះទុកលក់ ។ ពាក្យដ៏សេសក្នុងបទនេះ មានសេចក្ដីងាយហើយទាំងនោះឯង ។

ចប់អដ្ឋកថា វប្បសូត្រទី ៥

---

(១) បិដក = ឧទយត្ថិកោ ។

# អដ្ឋកថា សាឡ្ហសូត្រទី ៦

## *"បុច្ឆារបស់ស្តេចសាឡ្ហលិច្ឆវី"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាឡ្ហសូត្រទី ៦ ដូចតទៅនេះ ៖*

[៤៦] *បទថា* ***ទ្វយេន*** *(ដោយហេតុ ២ យ៉ាង) គឺ ដោយចំណែកទាំងពីរ ។ បទថា* ***ឱឃស្ស និត្ថរណំ*** *(ចេញចាកឱឃៈ) បានដល់ ការលោស់ខ្លួនចេញចាកឱឃៈ ៤ ។ បទថា* ***តបោជិគុច្ឆាហេតុ*** *(ព្រោះហេតុខ្ពើមបាបដោយតបៈ) បានដល់ ព្រោះហេតុខ្ពើមបាបដោយប្រព្រឹត្តតបៈ ពោលគឺ ការធ្វើទុក្ករកិរិយា ។ បទថា* ***អញ្ញតរំ សាមញ្ញង្គំ*** *(ជាអង្គនៃសមណធម៌មួយយ៉ាង) បានដល់ ចំណែកនៃសមណធម៌ ១ ។ ក្នុងបទមានជាអាទិ៍ថា* ***អបរិសុទ្ធកាយសមាចារា*** *(មានការប្រព្រឹត្តផ្លូវកាយមិនបរិសុទ្ធ) ព្រះមានព្រះភាគទ្រង់សម្តែងការមិនបរិសុទ្ធនៃសីល ដែលប្រព្រឹត្តផ្លូវកាយ វាចា និងចិត្ត ដោយ ៣ បទមុនហើយ ទើបទ្រង់សម្តែងដល់ភាពជាអ្នកមានអាជីវៈមិនបរិសុទ្ធដោយបទក្រោយ ។ បទថា* ***ញាណទស្សនាយ*** *(ដើម្បីញាណទស្សនៈ) បានដល់ ទស្សនៈ ដែលបានដល់មគ្គញ្ញាណ ។ បទថា* ***អនុត្តរាយ សម្ពោធាយ*** *(ដើម្បីត្រាស់ដឹងដល់ទីបំផុត) បានដល់ ដើម្បីព្រះអរហត្ត ។ លោកអធិប្បាយថា មិនគួរសម្ផស្សដោយញាណផស្សៈ គឺ អរហត្ត ។*

បទថា **សាលលដ្ឋី**[១] (ដើមរាំង) បានដល់ ដើមសាលៈ ។ បទថា **នវំ** (នៅជំទង់) គឺ ខ្ចី ។ បទថា **អកុក្កុច្ចកជាតំ** (មិនស្អប់ខ្ពើម) គឺ មិនកើតសេចក្ដីរង្កៀសថា គួរ ឬមិនគួរ ។ បទថា **លេខណិយា លិខេយ្យ** បានដល់ គូសឲ្យល្អមមានស្នាម ។ បទថា **ធោវេយ្យ** បានដល់ ដុសដោយថ្ម ។ បទថា **អន្តោ អវិសុទ្ធា** (មិនល្អខាងក្នុង) បានដល់ មិនរៀបរយក្នុងខាងក្នុង គឺ មិនយកខ្លឹមចេញ ។ ក្នុងបទថា **ឯវមេវ ខោ** (ដូច្នោះនោះឯង) នេះ ក៏ប្រៀបដោយឧបមាដូច្នេះ ។ ពិតណាស់ អត្តភាព គប្បីឃើញដូចដើមសាលៈ ក្រសែសង្សារ ដូចក្រសែទឹក បុគ្គលប្រកបដោយទិដ្ឋិ ៦២ ដូចបុគ្គលដែលត្រូវការទឹងទៅត្រើយនាយ វេលាដែលប្រកាន់មាំក្នុងអារម្មណ៍ខាងក្រៅ ដូចវេលាដែលធ្វើដើមសាលៈឲ្យរៀបរយល្អតែខាងក្រៅ វេលាដែលសីលខាងក្នុងមិនបរិសុទ្ធ ដូចវេលាដែលមិនធ្វើខាងក្នុងរបស់ដើមសាលៈឲ្យរៀបរយ កាលបុគ្គលប្រកបដោយទិដ្ឋិ រមែងលិចចុះទៅក្នុងក្រសែសង្សារ គប្បីជ្រាប ដូចជាដើមសាលៈលិចចុះទៅខាងក្រោម ។

បទថា **ជិយាវិត្តំ ពន្ធេយ្យ** (ចងប្រវាចែវ) បានដល់ ចងប្រវាភ្ជាប់នឹងទូក ។ បទថា **ឯវមេវ ខោ** (ដូច្នោះឯង) ប្រៀបដោយឧបមាដូច្នេះ

(១) បិដក = ដើមសាលព្រឹក្ស ។

អត្តកាព ដូចដើមសាលៈជំទង់ ។ ក្រសែសង្ហារ ដូចក្រសែទឹក ព្រះយោ-គាវចរ ដូចអ្នកដែលប្រាថ្នានឹងទៅកាន់ត្រើយនាយ វេលាដែលការសង្រួមតាំងមាំក្នុងទ្វារ ៦ ដូចវេលាដែលធ្វើខាងក្រៅឲ្យរៀបរយ សីលាចារបរិសុទ្ធិក្នុងខាងក្នុង ដូចការធ្វើខាងក្នុងឲ្យរៀបរយ ការបំពេញសីល សមាធិ បញ្ញាដោយលំដាប់ ហើយដល់និព្វាន គប្បីឃើញដូចការទៅដល់ត្រើយនាយបានដោយសួស្តី ។

បទថា **កណ្ឋចិត្តកានិ** (ក្បួនធ្នូ) បានដល់ វិធីដែលធ្វើធ្នូ មានច្រើនយ៉ាង ជាដើមថា ដងធ្នូ ខ្សែធ្នូ រាងធ្នូ ឆាកធ្នូ បន្ទោះធ្នូ ក្បាលធ្នូ ។ បទថា **អថខោ សោ តីហិ ឋានេហិ** (ហេតុនោះគេ... ដោយហេតុ ៣ ប្រការ) សេចក្តីថា គេសូម្បីដឹងក្បួនធ្វើធ្នូច្រើនយ៉ាងនេះ ក៏មិនមែនជាគួគួរដល់ព្រះរាជា តែជាគួគួរ ក៏ដោយឋានៈ ៣ ប៉ុណ្ណោះ ។

បទថា **សម្មាសមាធិ ហោតិ** (អ្នកមានសម្មាសមាធិ) ក្នុងបទនេះមានសេចក្តីថា ជាអ្នកតាំងមាំហើយដោយមគ្គសមាធិ និងផលសមាធិ ។ បទថា **សម្មាទិដ្ឋិ** (អ្នកមានសម្មាទិដ្ឋិ) បានដល់ អ្នកប្រកបហើយដោយមគ្គសម្មាទិដ្ឋិ ។ លោកពោល មគ្គ ៤ ផល ៣ ដោយសច្ចៈ ៤ មានជាអាទិ៍ថា **ឥទំ ទុក្ខំ** (នេះទុក្ខ) ក៏បុគ្គលប្រកបដោយសម្មាទិដ្ឋិនេះ គប្បីជ្រាប

ថា ឈ្មោះថា បាញ់មិនខុស ដោយមគ្គប៉ុណ្ណោះ ។ បទថា **សម្មាវិមុត្តិ** (អ្នកមានសម្មាវិមុត្តិ) បានដល់ បុគ្គលប្រកបហើយដោយវិមុត្តិ គឺ អរហត្តផល ។ បទថា **អវិជ្ជាខន្ធំ បទាលេតិ** (រមែងទម្លាយគំនរអវិជ្ជា) សេចក្តីថា បុគ្គលប្រកបដោយសម្មាវិមុត្តិ លោកពោលថា ឈ្មោះថា ទម្លាយគំនរអវិជ្ជា ដោយអរហត្តមគ្គ ពិតណាស់ គំនរអវិជ្ជា ត្រូវទម្លាយដោយអរហត្តមគ្គនេះ ក្នុងខាងក្រោយ តែក្នុងទីនេះគួរពោលថា រមែងទម្លាយអាស្រ័យគំនរអវិជ្ជា ដែលត្រូវទម្លាយហើយ ។

ចប់អដ្ឋកថា សាឡ្ហសូត្រទី ៦

# អដ្ឋកថា មល្លិកាទេវីសូត្រទី ៧

## "បុច្ឆារបស់ព្រះនាងមល្លិកា"

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាឡ្ហសូត្រទី ៦ ដូចតទៅនេះ ៖*

*[៤៧] បទថា **មល្លិកា ទេវី** (មល្លិកាទេវី) បានដល់ ព្រះទេវីរបស់ព្រះបាទបសេនទិកោសល ។ បទថា **យេន មិធេកច្ចា** (មាតុគ្រាមខ្លះក្នុងលោកនេះ) បានដល់ ស្ត្រីខ្លះក្នុងលោកនេះ ។ បទថា **ទុព្វណ្ណា** (មានពណ៌សម្បុរអាក្រក់) បានដល់ មានសម្បុរគួរស្អប់ ។ បទថា **ទុរូបា** (រូបអាក្រក់) បានដល់ មានទ្រង់ទ្រាយមិនល្អ ។ បទថា **សុបាបិកា** (មិនគួរមើល) បានដល់ សែនអាក្រក់ ថោកទាប ។ បទថា **ទស្សនាយ** (មើល) បានដល់ ដើម្បីឃើញ ។ បទថា **ទលិទ្ទា** (ក្រលំបាក) បានដល់ ខ្វះទ្រព្យ ។ បទថា **អប្បស្សកា** (កំសត់) បានដល់ មិនមានទ្រព្យ និងស្រូវអង្ករជារបស់ខ្លួន ។ បទថា **អប្បភោគា** (មានភោគសម្បត្តិតិច) បានដល់ ខ្វះខាតគ្រឿងប្រើប្រាស់ ។ បទថា **អប្បេសក្ខា** (សក្តិតូច) បានដល់ មានបរិវារតិច ។ **អឌ្ឍា** (ស្តុកស្តម) បានដល់ ជាឥស្សរៈ ។ បទថា **មហទ្ធនា** (មានទ្រព្យច្រើន) បានដល់ មានទ្រព្យច្រើន ដោយទ្រព្យសម្រាប់ប្រើប្រាស់ ។ បទថា **មហាភោគា** (មានភោគសម្បត្តិច្រើន) គឺ មានភោគៈច្រើន ដោយភោគៈ*

គ្រឿងឧបភោគបរិភោគ (របស់ប្រើរបស់ស៊ី) ។ បទថា **មហេសក្ខា** (សក្ដិធំ) គឺ មានបរិវារច្រើន ។ បទថា **អភិរូបា** គឺ មានរូបល្អ ។ បទថា **ទស្ស-នីយា** គឺ គួរមើល ។ បទថា **បាសាទិកា** (គួររីករាយ) គឺ មានចិត្តជ្រះថ្លាដោយសេចក្ដីស្រឡាញ់ ។ បទថា **វណ្ណបោក្ខរតាយ** (ជាអ្នកមានពណ៌សម្បុរល្អស្អាត) គឺ ដោយពណ៌សម្បុរ និងទ្រង់ទ្រាយ ។

បទថា **អភិសជ្ជតិ** (រហ័សក្រោធ) គឺ ខឹងក្រោធ ។ បទថា **ព្យាបជ្ជតិ** (ក្រញេងក្រញាង) បានដល់ លះប្រក្រតី ។ បទថា **បតិត្ថីយតិ** (រឹងត្អឹង) បានដល់ ដល់នូវភាពជាបុគ្គលរួញរា និងរឹងត្អឹង ដោយសេចក្ដីក្រោធ ។ បទថា **ន ទាតា ហោតិ** (ជាបុគ្គលមិនឲ្យទាន) គឺ ជាស្ត្រីមិនឲ្យ ។ ក្នុងបទថា **សេយ្យាវសថបទីបេយ្យំ** (ទីដេក ទីអាស្រ័យ និងប្រទីបភ្លើងគោម) គឺ ទីដេក មានគ្រែ និងបន្ទះក្ដារជាដើម ឈ្មោះថា **ទីដេក** ។ ផ្ទះជាទីនៅអាស្រ័យ ឈ្មោះថា **ទីនៅ** ។ គ្រឿងប្រកបប្រទីប មានប្រឆេះ និងប្រេង ជាដើម លោកហៅថា **ប្រទីបភ្លើងគោម** ។ បទថា **ឥស្សាមនិកា** (មានចិត្តឫស្យា) បានដល់ មានចិត្តប្រកបដោយសេចក្ដីច្រណែន ។ គប្បីជ្រាបសេចក្ដីក្នុងបទទាំងអស់ដោយន័យនេះ ។ បទថា **កោធនោ អហោសិ** (ជាអ្នកក្រោធ) គឺ ជាស្ត្រីច្រើនទៅដោយសេចក្ដីក្រោធ ។ បទថា **អនិស្សា-**

***មនិកា អហោសិ*** *(មានចិត្តមិនឥស្សា) គឺ បានជាស្ត្រីមានចិត្តវៀរចាកសេចក្តីឥស្សា ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានសេចក្តីងាយហើយនោះឯង ។*

ចប់អដ្ឋកថា មល្លិកាទេវីសូត្រទី ៧

# អដ្ឋកថា អត្តន្តបសូត្រទី ៨

## *"បុគ្គលដែលដុតកំដៅខ្លួន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អត្តន្តបសូត្រទី ៨ ដូចតទៅនេះ ៖*

*[៤៨] ក្នុងបទថា **អត្តន្តបោ** (ដុតកំដៅខ្លួន) ជាដើម មានវិគ្រោះថា ឈ្មោះថា **ធ្វើខ្លួនឲ្យក្តៅ** ព្រោះដុតខ្លួន គឺ ធ្វើខ្លួនឲ្យដល់សេចក្តីទុក្ខ ។ ការប្រកបសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យក្តៅ ឈ្មោះថា **ខ្វល់ខ្វាយក្នុងការធ្វើខ្លួនឲ្យក្តៅ** ។ បទថា **បរន្តបោ** (ធ្វើអ្នកដទៃឲ្យក្តៅ) ព្រោះដុតអ្នកដទៃ ។ ការប្រកបសេចក្តីព្យាយាមធ្វើអ្នកដទៃឲ្យក្តៅ ឈ្មោះថា **ខ្វល់ខ្វាយក្នុងការធ្វើអ្នកដទៃឲ្យក្តៅ** ។ បទថា **ទិដ្ឋេវ ធម្មេ** (ក្នុងបច្ចុប្បន្ននោះឯង) បានដល់ក្នុងអត្តភាពនេះឯង ។ ក្នុងបទថា **និច្ឆាតោ** (ជាអ្នកមិនស្រេកឃ្លាន) តណ្ហាលោកហៅថា **សេចក្តីស្រេកឃ្លាន** ឈ្មោះថា **ជាអ្នកមិនស្រេកឃ្លាន** ព្រោះមិនមានតណ្ហា ។ ឈ្មោះថា **និព្វុតោ** (រលត់គ្រឿងក្តៅ) ព្រោះកិលេសទាំងអស់រលត់ ។ ឈ្មោះថា **សីតិភូតោ** (មានសន្តានត្រជាក់) ព្រោះជាអ្នកត្រជាក់ ព្រោះមិនមានកិលេសដុតខាងក្នុង ។ បទថា **សុខបដិសំវេទី** (សោយសុខ) ព្រោះសោយសុខក្នុងឈាន មគ្គ ផល និងនិព្វាន ។ បទថា **ព្រហ្មភូតេន អត្តនា** (មានខ្លួនដ៏ប្រសើរ) បានដល់ មានខ្លួនប្រសើរបំផុត ។*

បទមានជាអាទិ៍ថា **អចេលកោ** (ជាអ្នកអាក្រាត) មានសេចក្ដីដូចពោលទុកហើយ ។

ក្នុងបទថា **ការសម្លាប់ពពែ** ជាដើម សត្វកេះទាំងឡាយ លោកហៅពពែ ឈ្មោះថា **ឱរព្ភិកោ** (អ្នកសម្លាប់ពពែ) ព្រោះសម្លាប់ពពែទាំងឡាយ ។ សូម្បីក្នុងបទថា **សូករិកោ** (សម្លាប់ជ្រូក) ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **លុទ្ទោ** (ព្រាន) គឺ មនុស្សកាចសាហាវ មនុស្សអាក្រក់ ។ បទថា **មច្ឆឃាតកោ** (ជាអ្នកសម្លាប់ត្រី) បានដល់ អ្នកចាប់ត្រី គឺ ព្រាននេសាទ ។ បទថា **ពន្ធនាគារិកោ** (នាយគុក) បានដល់ អ្នកគ្រប់គ្រងគុក ។ បទថា **កុរូរកម្មន្តា** (អ្នកធ្វើកម្មអាក្រក់) បានដល់ អ្នកមានការងារអាក្រក់ ។

បទថា **មុទ្ធាភិសិត្តោ** (បានមុទ្ធាភិសេក) បានដល់ ព្រះរាជា ដែលគេប្រូចទឹកលើព្រះសិរសា ហើយអភិសេកជាក្សត្រិយ៍ ។ បទថា **បុរត្ថិមេន នគរស្ស** (ទិសខាងកើតនៃព្រះនគរ) បានដល់ ទិសខាងកើតអំពីនគរ ។ បទថា **សណ្ឋាគារំ** (សណ្ឋាគារ) បានដល់ រោងបូជាយញ្ញ ។ បទថា **ខរាជិនំ និវាសេត្វា** (ដណ្ដប់ស្បែកសត្វទាំងក្រចក) បានដល់ ស្លៀកស្បែកខ្លាទាំងក្រចក ។ បទថា **សប្បិតេលេន** បានដល់ ជាមួយទឹកដោះថ្លា[1] និង

(១) បិជក = ខ្លាញ់ថ្លា ។

ប្រេង ។ វៀរទឹកដោះថ្លា ក្រៅពីនោះរបស់មានជ័រណាមួយ លោកក៏ហៅថា ប្រេង ។ បទថា **កណ្ឌុវមានោ** (អេះខ្នង) បានដល់ ព្រោះគាត់ក្រចកអស់ គ្រានឹងត្រូវការអេះ ទើបអេះដោយស្នែងសត្វនោះ ។ បទថា **អនន្តរហិ-តាយ** (ដែលប្រាសចាកការក្រាលទុក) បានដល់ មិនមានកម្រាល ។ បទថា **សរូបវច្ឆាយ** (កូនគោ) បានដល់ កូនគោមានសម្បុរដូចគ្នា អធិប្បាយថា បើមេគោមានសម្បុរស សូម្បីកូនគោក៏មានសម្បុរស បើមេគោមានសម្បុរខ្មៅ ឬសម្បុរក្រហម សូម្បីកូនគោក៏មានសម្បុរដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបឈ្មោះថា មេគោមានកូនដែលមានសម្បុរដូចគ្នា ។ បទថា **សោ ឯវមាហ** (ព្រះរាជានោះត្រាស់យ៉ាងនេះ) គឺ ព្រះរាជាអន្ធនោះ រមែងត្រាស់យ៉ាងនេះ ។ បទថា **វច្ឆតរា** (គោស្ទាវ) បានដល់ គោមានកម្លាំង (គោប្រើ) ផ្ទាប់ជាគោជំទង់ហើយ ។ សូម្បីក្នុងមេគោជំទង់ ក៏ន័យនេះដូចគ្នា ។ បទថា **ពរិហិសត្ថាយ** (ដើម្បីបាំង និងក្រាល) បានដល់ ដើម្បីប្រយោជន៍ជាសសរ និងដើម្បីក្រាលក្នុងទីបូជាយញ្ញ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់បុគ្គលទី ៤ តាំងពីព្រះពុទ្ធទ្រង់ឧប្បត្តិ ទើបត្រាស់ពាក្យជាអាទិ៍ថា **ឥធ ភិក្ខវេ តថាគតោ** (ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតស្តេចឧប្បត្តិក្នុងលោកនេះ) ។ ក្នុងបទទាំងនោះ

បទថា **តថាគត** ជាដើម មានអត្ថបានពោលទុកហើយ ។ បទថា **តំ ធម្មំ** (ធម៌នោះ) បានដល់ ធម៌ដ៏សម្បូរ ដោយប្រការដូចបានពោលទុកហើយនោះឯង ។ បទថា **សុណាតិ គហបតិ វា** (គហបតី... រមែងស្តាប់) សួរថា ព្រោះហេតុអ្វី ទើបទ្រង់ចង្អុលគហបតីមុន ។ ឆ្លើយថា ព្រោះគហបតីកម្ចាត់មានះហើយ និងព្រោះមានចំនួនច្រើន ។ ពិតហើយ ដោយច្រើនអ្នកដែលបួសពីត្រកូលក្សត្រិយ៍ មានះព្រោះអាស្រ័យជាតិ ។ អ្នកដែលបួសពីត្រកូលព្រាហ្មណ៍ មានះព្រោះអាស្រ័យមន្ត ។ អ្នកដែលបួសពីត្រកូលដែលមានជាតិទាប មិនអាចតាំងនៅបាន ព្រោះខ្លួនមានជាតិថោកទាប ។ ចំណែកពួកទារករបស់គហបតី មានញើសហូរចេញពីក្លៀក ផ្ដាអំបិលពេញខ្នង ព្រោះភ្ជួរស្រែ ជាអ្នកអស់មានះ និងមិនធ្វើងឆ្មៃ ព្រោះមិនមានមានះ ។ ទារកទាំងនោះគ្រាបួសហើយ ក៏មិនធ្វើមានះ ឬភាពឆ្មើងឆ្មៃ រៀនពុទ្ធវចនៈតាមកម្លាំង បំពេញវិបស្សនាកម្មដ្ឋាន អាចតាំងនៅក្នុងព្រះអរហត្តបាន ។ តែអ្នកដែលចេញបួសពីត្រកូលក្រៅពីនេះមានមិនច្រើន អ្នកជាគហបតីចេញបួសមានច្រើន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ទើបចង្អុលដល់គហបតីមុន ព្រោះអាចកម្ចាត់មានះ និងព្រោះមានចំនួនច្រើននោះឯង ។

បទថា **អញ្ញតរស្មឹ វា** (ក្នុងត្រកូលណាមួយ) បានដល់ ត្រកូលក្រៅ

អំពីនេះ ត្រកូលណាមួយ ។ បទថា **បច្ចាជាតោ** (អ្នកកើត) បានដល់ កើតក្នុងខាងក្រោយ ។ បទថា **តថាគតេ សទ្ធំ បដិលភតិ** (រមែងបានសទ្ធា ក្នុងព្រះតថាគត) សេចក្តីថា គេបានស្តាប់ធម៌ដែលបរិសុទ្ធហើយ រមែងបាន សទ្ធាក្នុងព្រះតថាគតទ្រង់ជាធម្មសាមី (ម្ចាស់នៃធម៌) ថា ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** (រមែងសង្កេតឃើញច្បាស់ដូច្នេះ) គឺ រមែងពិចារណាឃើញ យ៉ាងនេះ ។ បទថា **សម្ពាធោ ឃរាវាសោ** (ឃរាវាសចង្អៀតចង្អល់) សេចក្តីថា សូម្បីថា គូស្វាមីភរិយានៅក្នុងផ្ទះទំហំប្រមាណ ៦០ ហត្ថ ឬ មួយរយយោជន៍ក៏ដោយ ការនៅគ្រប់គ្រងផ្ទះ ក៏ឈ្មោះថា ចង្អៀតនោះឯង ព្រោះគូស្វាមីភរិយានោះ នៅមានសេចក្តីកង្វល់ និងសេចក្តីហួងហែង ។ បទថា **រជាបថោ** (ជាផ្លូវនាំមកនូវធូលី) លោកពោលទុកក្នុងមហាអដ្ឋកថា ថា "ជាទីកើតនៃធូលីមានរាគៈជាដើម" ។ នឹងពោលថា **អាគមនបថោ** (ជាផ្លូវមក) ដូច្នេះខ្លះ ក៏គួរ ។ ឈ្មោះថា **អព្ភោកាសោ** (ជាផ្លូវស្រឡះ) ព្រោះដូចជាទីវាល ដោយអត្ថថា មិនមានជាប់ជំពាក់ ។ ពិតហើយ បព្វជិត អ្នកបួស សូម្បីនៅក្នុងកូដាគារ រតនប្រាសាទ ទេវវិមានជាដើម ដែលមាន ទ្វារ និងបង្អួចបិទជិត ជាទីកំបាំង ក៏មិនជាប់មិនជំពាក់ ។ ព្រោះហេតុនោះ

ទើបត្រាស់ថា "បព្វជ្ជាជាផ្លូវស្រឡះ" ។ មួយវិញទៀត យកវាសជាទីចង្អៀត ព្រោះមិនមានឱកាសនឹងធ្វើកុសល សេចក្ដីល្អបានតាមសប្បាយ ។ ឈ្មោះថា ជាផ្លូវហូរមកនៃធូលី ព្រោះជាទីរួមនៃធូលី គឺ កិលេស ដូចផងគំនរសម្រាម ដែលមិនបានគ្របទុក ។ បព្វជ្ជាឈ្មោះថា ជាផ្លូវស្រឡះ ព្រោះមានឱកាសធ្វើកុសល សេចក្ដីល្អបានតាមសប្បាយ ។

ក្នុងពាក្យថា **នយិទំ សុករំ ។បេ។ បព្វជេយ្យំ** (មិនមែនធ្វើបានងាយ... បួស) នេះ ពោលដោយសង្ខេប ដូច្នេះ ។ **ព្រហ្មចរិយៈ** គឺ សិក្ខា ៣ នេះ បានឈ្មោះថា **ឯកន្តបរិបុណ្ណំ** (បរិបូរណ៍ដោយចំណែកមួយ) ព្រោះអ្នកបួសធ្វើមិនឲ្យដាច់សូម្បីមួយថ្ងៃ ហើយក៏គប្បីឲ្យដល់ចរិមកចិត្តបាន ។ និងឈ្មោះថា **ឯកន្តបរិសុទ្ធំ** (បរិសុទ្ធដោយចំណែកមួយ) ព្រោះអ្នកបួសធ្វើមិនឲ្យមានមន្ទិល ដោយមន្ទិល គឺ កិលេសសូម្បីមួយថ្ងៃ ក៏គប្បីឲ្យដល់ចរិមកចិត្តបាន ។ បទថា **សង្ខលិខិតំ** (ដូចស័ង្ខដែលខាត់) បានដល់ គប្បីប្រព្រឹត្តឲ្យដូចជាស័ង្ខដែលខាត់ គឺ ប្រៀបដូចស័ង្ខដែលខាត់ហើយ ។ ឯបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ គឺ នៅកណ្ដាលផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយៈ គឺ សិក្ខា ៣ នេះ ឲ្យបរិសុទ្ធបរិបូរណ៍ដោយចំណែកមួយ ធ្វើមិនបានងាយឡើយ បើដូច្នោះ យើងគប្បីកោរសក់ និងពុកមាត់ ស្លៀកដណ្ដប់សំពត់

ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ឈ្មោះថា សំពត់កាសាយៈ ព្រោះជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះ បួសមិនមានផ្ទះចុះ ។ ក៏ក្នុងសេចក្តីនេះ ព្រោះកសិកម្ម ពាណិជ្ជកម្មជាដើម ជាប្រយោជន៍ចម្រើនដល់ផ្ទះ លោកទើបហៅថា **អគារិយៈ** ក៏អគារិយកិច្ចនោះ មិនមាននៅក្នុងបព្វជ្ជា ដូច្នោះបព្វជ្ជាគប្បីជ្រាបថាជា **អនាគារិយៈ** (មិនមានផ្ទះ) ។ បទថា **បព្វជេយ្យំ** (គប្បី... បួស) បានដល់ គប្បីបដិបត្តិ ។

បទថា **អប្បំ វា** (តិច) បានដល់ គំនរភោគៈតិចជាងមួយពាន់ឈ្មោះថា តិច , តាំងពីមួយពាន់ឡើងទៅ ឈ្មោះថា ច្រើន ។ ញាតិទុំះឯងឈ្មោះថា **ញាតិបរិវដ្តោ** (សាច់ញាតិ) ព្រោះអត្ថថា ពាក់ព័ន្ធគ្នា ។ សាច់-ញាតិតិចជាង ២០ ឈ្មោះថា តិច , ពី ២០ ឡើងទៅ ឈ្មោះថា ច្រើន ។ បទថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** (ដល់ភាពជាអ្នកមានសិក្ខា និងសាជីវៈស្មើជាមួយភិក្ខុទាំងឡាយ) សេចក្តីថា សិក្ខាណា បានដល់ អធិសីលរបស់ភិក្ខុទាំងឡាយ និងភិក្ខុទាំងនោះនៅរួមគ្នា រស់នៅដូចគ្នាតែម្យ៉ាង មានការប្រព្រឹត្តស្មើគ្នាក្នុងសិក្ខាណា បព្វជិតចូលដល់សិក្ខានោះ និងសាជីវៈ គឺសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុកហើយនោះ ដោយការសិក្សាក្នុងសិក្ខា និងសាជីវៈនោះ ព្រោះហេតុនោះ បព្វជិតនោះឈ្មោះថា ជាអ្នក

ដល់ព្រមហើយដោយសិក្ខា និងការនៅរួមគ្នាជាមួយភិក្ខុទាំងឡាយ ។ បទថា **សមាបន្នោ** (ដល់) បានដល់ បព្វជិតបំពេញសិក្ខាឲ្យបរិបូរណ៍ និងមិនល្មើសសាជីវៈការនៅរួមគ្នា អធិប្បាយថា ចូលដល់សិក្ខា និងសាជីវៈទាំងពីរនោះ ។

បទថា **បាណាតិបាតំ បហាយ** (លះបាណាតិបាត) ជាដើម មានអត្ថដូចពោលហើយនុ៎ះឯង ។ បទថា **ឥមេសំ ភេទាយ** (ដើម្បីឲ្យជនពួកនេះបែកពីគ្នា) បានដល់ ដើម្បីឲ្យជនដែលខ្លួនស្តាប់មកពីខាងនេះបែកគ្នា ។ បទថា **ភិន្នានំ វា សន្ធាតា** (សមាគមដែលបែកគ្នាហើយ) សេចក្តីថា កាលមិត្តពីរនាក់ ឬអ្នករួមឧបជ្ឈាយ៍ជាដើមបែកគ្នា ដោយហេតុណាៗ បព្វជិតចូលទៅរកតែមួយនាក់ ហើយពោលពាក្យជាដើមថា នេះមិនសមគួរដល់លោកដែលកើតក្នុងត្រកូលដូច្នេះ អ្នកគប្បីសិក្សាយ៉ាងនេះ ហើយធ្វើសេចក្តីផ្សះផ្សាគ្នា ។ បទថា **អនុប្បទាតា** (សរសើរ) បានដល់ សរសើរបុគ្គលដែលព្រមព្រៀងគ្នា អធិប្បាយថា បព្វជិតឃើញអ្នកពីរនាក់ព្រមព្រៀងគ្នាគប្បីពោលពាក្យជាដើមថា នេះសមគួរដល់ពួកលោក អ្នកកើតក្នុងត្រកូលបែបនេះ អ្នកប្រកបដោយគុណបែបនេះ ហើយធ្វើរឹងមាំឡើង ។ បទថា **សមគ្គារាមោ** (ពេញចិត្តជនដែលព្រមព្រៀង) ព្រោះថា មានការសាមគ្គីជា

ទីត្រេកអរ អធិប្បាយថា មិនប្រាថ្នាសូម្បីតែនៅក្នុងទីដែលមិនមានអ្នកសាមគ្គីគ្នា បាលីថា **សមគ្គារាមោ** ដូច្នេះក៏មាន សេចក្តីដូចគ្នា ។ បទថា **សមគ្គរតោ** (ត្រេកអរក្នុងជនដែលព្រមព្រៀងគ្នា) បានដល់ ត្រេកអរហើយក្នុងបុគ្គលដែលសាមគ្គីគ្នា អធិប្បាយថា មិនប្រាថ្នាលះបង់បុគ្គលដែលសាមគ្គីគ្នាទាំងនោះ ហើយទៅកាន់ទីដទៃ ។ ឈ្មោះថា **សមគ្គនន្ទី** (រីករាយក្នុងជនដែលព្រមព្រៀងគ្នា) ព្រោះឃើញក្តី បានឮក្តី ចំពោះបុគ្គលសាមគ្គីគ្នាក៏រីករាយ ។ បទថា **សមគ្គករណី វាចំ ភាសិតា** (ពោលតែពាក្យដែលធ្វើឲ្យព្រមព្រៀងគ្នា) សេចក្តីថា វាចាណាធ្វើឲ្យបុគ្គលសាមគ្គីគ្នា រមែងពោលវាចានោះ ដែលសម្តែងដល់គុណនៃការសាមគ្គីប៉ុណ្ណោះ មិនពោលក្រៅអំពីនេះ ។

ក្នុងបទថា **នេលា** (ដែលប្រាសចាកទោស) ទោស លោកហៅថា **ឯលៈ** ។ ឈ្មោះថា **ប្រាសចាកទោស** ព្រោះមិនមានទោស អធិប្បាយថា រកទោសមិនបាន ។ ដូច **នេល** ស័ព្ទ ដែលលោកពោលទុកក្នុងបទនេះថា **នេលង្គោ សេតបច្ឆាទោ** (រថមានគ្រឿងប្រកបមិនមានទោស មានដំបូល.ស) ដូច្នេះ ។ បទថា **កណ្ណសុខា** (គួរដល់ត្រចៀក) បានដល់ ជាទីសប្បាយត្រចៀក ព្រោះពីរោះដោយព្យញ្ជនៈ មិនដូចជាលំពែងចាក់ត្រចៀក ឬដូច

ចាក់ដោយឫស ។ បទថា **បេមនិយា** (អ្នកផងស្រឡាញ់) ព្រោះមិនកើតការទើសក្នុងសកលកាយ កើតតែពីសេចក្តីស្រឡាញ់ ព្រោះពីរោះដោយអត្ថ ។ បទថា **ហទយង្គមា** (ចាប់ចិត្ត) ព្រោះជាប់ដល់ចិត្ត មិនខ្វាំងខ្វប់ ចូលទៅដល់ចិត្តដោយស្រួល ។ បទថា **បោរី** (សុភាព) ព្រោះជាសំដីអ្នកក្រុង ព្រោះបរិបូរណ៍ដោយគុណ ។ បទថា **សុភាព** ព្រោះទន់ភ្លន់ ដូចនារីដែលចម្រើនក្នុងក្រុង ដូច្នេះក៏មាន ។ ឈ្មោះថា **សុភាព** ព្រោះជាសំដីអ្នកក្រុង ដូច្នេះក៏មាន អធិប្បាយថា បទថា **ជាសំដីអ្នកក្រុង** បានដល់ ពាក្យសំដីរបស់អ្នកក្រុង ។ ពិតហើយ អ្នកក្រុង រមែងពោលពាក្យដែលសមគួរ ហៅបុគ្គលចំណាស់ឪពុកថា ពុក ចំណាស់បងថា បង ដូច្នេះ ។ បទថា **ពហុជនកន្តា** (មនុស្សដោយច្រើនស្រឡាញ់) ព្រោះពាក្យសំដីបែបនេះ ជាទីស្រឡាញ់របស់ជនច្រើន ។ ឈ្មោះថា **ពហុជនមនាបា** (មនុស្សដោយច្រើនពេញចិត្ត) ព្រោះជាទីពេញចិត្ត គឺ ធ្វើសេចក្តីចម្រើនចិត្តដល់ជនច្រើនដោយជាពាក្យគួរស្រឡាញ់ ។

ឈ្មោះថា **កាលវាទី** (និយាយត្រូវកាល) ព្រោះនិយាយត្រូវកាល អធិប្បាយថា កំណត់កាលដែលគួរនិយាយហើយ ទើបនិយាយ ។ បទថា **ភូតវាទី** (និយាយតែពាក្យពិត) ព្រោះនិយាយតែរឿងដែលពិតប្រាកដ ដែល

មានប៉ុណ្ណោះ ។ បទថា **អត្ថវាទី** (និយាយអាស្រ័យអត្ថ) ព្រោះនិយាយអាស្រ័យប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ក្នុងភពមុខ ។ បទថា **ធម្មវាទី** (និយាយអាស្រ័យធម៌) ព្រោះនិយាយអាស្រ័យនវលោកុត្តរធម៌ ។ បទថា **វិនយវាទី** (និយាយអាស្រ័យវិន័យ) ព្រោះនិយាយអាស្រ័យសំវរវិន័យ និងបហានវិន័យ ។ ឱកាសជាទីតាំងទុក ឈ្មោះថា **និធាន** (មូលដ្ឋាន) គឺគោលរបស់វាចានោះមានហើយ ហេតុនោះ វាចានោះ ឈ្មោះថា **និធានវតី** (មានគោល) អធិប្បាយថា ជាអ្នកពោលពាក្យសំដីគួរស្តាប់ទុកក្នុងចិត្ត ។ បទថា **កាលេន** (ដោយកាលដែលគួរ) បានដល់ សូម្បីកាលពោលវាចាបែបនេះ ក៏គិតថា យើងនឹងពោលវាចាដែលគួរចងចាំ មិនពោលពេលរាយ អធិប្បាយថា ពិចារណាដល់កាលដែលគួរមុនហើយ ទើបពោល ។ បទថា **សាបទេសំ** (មានទីអាង) បានដល់ មានសេចក្តីឧបមា អធិប្បាយថា មានហេតុផល ។ បទថា **បរិយន្តវតី** (មានទីកំណត់) បានដល់ សម្តែងមានគ្របខ័ណ្ឌ អធិប្បាយថា ពោលដោយអាការដែលវាចានោះ មានគោលច្បាស់លាស់ ។ បទថា **អត្ថសញ្ហិតំ** (ប្រកបដោយប្រយោជន៍) បានដល់ មានអ្នកចែកទុកសូម្បីច្រើនន័យ ក៏មិនគប្បីកាន់យក (ទាំងអស់) ឈ្មោះថា ដល់ព្រមដោយអត្ថ ។ ម្យ៉ាងទៀត លោកអធិប្បាយទុកថា រមែងពោលវាចា

ដែលប្រកបដោយប្រយោជន៍ ព្រោះវាចានោះ ប្រកបដោយប្រយោជន៍ ដែលអ្នកពោលអាស្រ័យប្រយោជន៍បំណងពោល មិនមែនលើករឿងមួយឡើងហើយ ពោលរឿងថ្មីដទៃទេ ។

បទថា **ពីជគាមភូតគាមសមារម្ភា** (ប្រាសចាកការធ្វើពីជគាម និងភូតគាម) សេចក្តីថា ជាអ្នកវៀរចាកការកម្ចាត់ គឺ ការទម្លាយ ដោយការកាត់ និងការដុតនូវពីជគាម ៥ យ៉ាង គឺ ពូជកើតពីឫស ១ ពូជកើតពីដើម ១ ពូជកើតពីថ្នាំង ១ ពូជកើតត្រួយ ១ ពូជកើតពីគ្រាប់ ១ និងនូវពីជគាម មានស្មៅពណ៌ខៀវ និងដើមឈើជាដើម ។

បទថា **ឯកភត្តិកោ** (បរិភោគភត្តមួយពេល) បានដល់ ភត្ត (អាហារ) ២ យ៉ាង គឺ ភត្តក្នុងវេលាព្រឹក ១ ភត្តក្នុងវេលាល្ងាច ១ ។ ក្នុងភត្ត ២ យ៉ាងនោះ ភត្តក្នុងវេលាព្រឹក កំណត់ទុកត្រឹមថ្ងៃត្រង់ ភត្តក្នុងវេលាល្ងាច កំណត់ទុកកន្លងថ្ងៃត្រង់ទៅ ព្រោះដូច្នោះ សូម្បីនឹងបរិភោគ ១០ ដង ក្នុងថ្ងៃត្រង់ ក៏ឈ្មោះថា **ឯកភត្តិក** (ជាអ្នកបរិភោគតែមួយដង) ទ្រង់សំដៅដល់ឯកភត្តិកៈនោះ ទើបពោលថា **បរិភោគមួយពេល** ។ ការបរិភោគក្នុងពេលយប់ ឈ្មោះថា **ការបរិភោគក្នុងពេលរាត្រី** ឈ្មោះថា **រត្តូបរតោ** (វៀរការបរិភោគក្នុងវេលាវិកាល) ព្រោះវៀរចាកការបរិភោគក្នុងពេលយប់ ។ កាល

កន្លងថ្ងៃត្រង់ទៅ ហើយបរិភោគដរាបដល់ព្រះអាទិត្យលិច ឈ្មោះថា បរិ-ភោគក្នុងវេលាវិកាល ព្រោះវៀរចាកការបរិភោគក្នុងវេលាវិកាល ឈ្មោះថា **វិរតោ វិកាលភោជនា** (វៀរចាកការបរិភោគក្នុងវេលាវិកាល) ។

បទថា **ជាតរូបំ** បានដល់ មាស ។ បទថា **រជតំ** (ប្រាក់) បានដល់ប្រាក់ដែលមនុស្សលោកគេហៅថា កហាបណៈ លោហមាសកៈ ជតុមាសកៈ (មាសកៈជ័រឈើ) ទារុមាសកៈ (មាសកៈឈើ) វៀរចាកការទទួលមាសនិងប្រាក់សូម្បីទាំងពីរនោះ អធិប្បាយថា មិនទទួលឯង មិនឲ្យអ្នកដទៃទទួល មិនត្រេកអរក្នុងរបស់ដែលគេរក្សាទុក ។

បទថា **អាមកធញ្ញបដិគ្គហណា** (វៀរចាកការទទួលធញ្ញជាតិស្រស់) បានដល់ វៀរចាកការទទួលស្រូវ ៧ យ៉ាងពោលគឺ ស្រូវសាលី ១ ស្រូវខ្សាយ ១ ស្រូវជំណើប ១ ស្រងែ ១ ថ្លៅ ១ ស្កួយ ១ ស្មៅគែលលក ១ ។ មិនមែនទទួលស្រូវទាំងនោះតែម្យ៉ាងប៉ុណ្ណោះដែលមិនគួរ សូម្បីស្ទាបអង្អែលក៏មិនគួរដល់ភិក្ខុទាំងឡាយដោយពិត ។ ក្នុងបទថា **អាមកមំសបដិគ្គហណា** (វៀរចាកការទទួលសាច់ស្រស់) នេះ ការទទួលសាច់ និងត្រីស្រស់ ក៏មិនគួរ ស្ទាបអង្អែលក៏មិនគួរដល់ភិក្ខុទាំងឡាយ វៀរតែព្រះពុទ្ធទ្រង់អនុញ្ញាតទុកដោយចំពោះ ។

ក្នុងបទថា **ឥត្ថីកុមារិកាបដិគ្គហណា** (វៀរចាកការទទួលស្ត្រី និង កុមារី) នេះ គប្បីជ្រាបថា ស្ត្រីដែលនៅជាមួយបុរស ឈ្មោះថា **ឥត្ថី** (ស្ត្រី) ស្រីក្រៅពីនោះ ឈ្មោះថា **កុមារិកា** (កុមារី) ។ ការទទួលក្តី ការស្ទាប អង្អែលក្តីចំពោះស្រីទាំងនោះ ជាអកប្បិយៈ (មិនគួរ) ។ ក្នុងបទថា **ទាសី-ទាសបដិគ្គហណា** (វៀរចាកការទទួលទាសី និងទាសៈ) នេះ ការទទួល មនុស្សជាទាសៈស្រី ទាសៈប្រុស មិនគួរ ប៉ុន្តែថា កាលនិយាយយ៉ាងនេះ ថា យើងថ្វាយជាកប្បិយការកៈ យើងថ្វាយជាញោមវត្ត ដូច្នេះ គួរ ។

សូម្បីក្នុងពពែ និងកែះជាដើម មានស្រែ និងចម្ការជាទីបំផុត គួរ ត្រួតពិនិត្យទីជាកប្បិយៈ និងអកប្បិយៈដោយផ្លូវវិន័យ ។ ក្នុងសេចក្តីនោះ បុព្វណ្ណជាតិ (ស្រូវ) ដុះឡើងក្នុងទីណា ទីនោះឈ្មោះថា ស្រែ , អប-រណ្ណជាតិ (សណ្តែកល្ង) ដុះឡើងក្នុងទីណា ទីនោះឈ្មោះថា ចម្ការ ។ ម្យ៉ាងទៀត ទាំងពីរយ៉ាងដុះឡើងក្នុងទីណា ទីនោះឈ្មោះថា ស្រែ ។ ទីដី ដែលមិនបានធ្វើដើម្បីប្រយោជន៍ស្រែនោះ ឈ្មោះថា ចម្ការ ។ សូម្បីបឹង និងត្រពាំងជាដើម លោកក៏សង្គ្រោះចូលក្នុងបទនេះ ដោយបំណងដល់ស្រែ និងចម្ការ ។

ទូតកម្ម បានដល់ ការទទួលសំបុត្រ ឬដំណឹងរបស់ពួកគ្រហស្ថ

ហើយទៅកាន់ទីនោះៗ លោកហៅថា ជាទូត ភិក្ខុកាលត្រូវគ្រហស្ថបញ្ជូន ពីផ្ទះមួយខ្នង ទៅកាន់ផ្ទះមួយខ្នង លោកហៅថា ការទទួលប្រើ ។ ធ្វើទាំង ពីរយ៉ាងនោះ ឈ្មោះថា ប្រកបរឿយៗ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុង បទនេះ យ៉ាងនេះថា វៀរចាកការប្រកបរឿយៗ នូវទូត និងទទួលបម្រើអំពី គ្រហស្ថ ។ បទថា **កយវិក្កយា** (វៀរចាកការទិញលក់) បានដល់ វៀរចាក ការទិញ និងការលក់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **តុលាកូដា** (ការកោងដោយក្អែកជញ្ជីង) ជាដើម ការបោកបញ្ឆោត ឈ្មោះថា កោង ។ ក្នុងការកោងនោះ ការកោង ដោយក្អែកជញ្ជីងមាន ៤ យ៉ាង គឺ កោងដោយរូប ១ កោងដោយអវយវៈ ១ កោងដោយការចាប់ ១ កោងដោយការកំបាំង ១ ។ ក្នុងការកោង ៤ យ៉ាងនោះ គេធ្វើក្អែកជញ្ជីងពីរដែលមានរូបដូចៗ គ្នា កាលទទួល ក៏ទទួល ដោយក្អែកជញ្ជីងធំ , កាលឲ្យ ក៏ឲ្យដោយក្អែកជញ្ជីងដែលតូច ឈ្មោះថា កោងដោយរូប ។ កាលទទួល ក៏ប្រើដៃសង្កត់ក្អែកជញ្ជីងខាងក្រោយ , កាលឲ្យ ក៏ប្រើដៃសង្កត់ក្អែកជញ្ជីងខាងមុខ ឈ្មោះថា កោងដោយអវយវៈ ។ កាលទទួលក៏ចាប់ខ្សែទុកត្រង់.កជញ្ជីង កាលឲ្យ ក៏ចាប់ខ្សែទុកត្រង់ចុងដង ជញ្ជីង ឈ្មោះថា កោងដោយការចាប់ ។ ធ្វើក្អែកជញ្ជីងឲ្យប្រហោងក្នុង

ដាក់កម្ទេចដែកខាងក្នុង កាលទទួល ក៏ឲ្យកម្ទេចដែកនោះធ្លាក់ទៅចុងជញ្ជីង កាលឲ្យ ក៏ឲ្យកម្ទេចដែកនោះធ្លាក់មក.កជញ្ជីង ឈ្មោះថា កោង ដោយការកំបាំង ។

ថាសមាស លោកហៅថា **កំស:** ការបោកបញ្ឆោតដោយថាសមាស នោះ ឈ្មោះថា **កំសកូដ:** (កោងដោយរបស់ប្ដូម) ។ សួរថា កោងដូចម្ដេច ។ ឆ្លើយថា ធ្វើថាសមាសទុកមួយ ហើយធ្វើថាសលោហ:ដទៃ ២-៣ ទៀតឲ្យមានពណ៌ដូចមាស បន្ទាប់ពីនោះ គេក៏ទៅកាន់ជនបទ ចូលទៅកាន់ត្រកូលដែលស្ដុកស្ដម្ភមួយ ហើយនិយាយថា សូមលោកមេត្តាទិញភាជន: មាសចុះ កាលសួរដល់តម្លៃ បំណងនឹងឲ្យតម្លៃស្មើៗ គ្នា កាលអ្នកទិញសួរថា នឹងដឹងបានដូចម្ដេចថា ថាសទាំងនេះជាមាស អ្នកបោកបញ្ឆោតពោលថា សាកល្បងហើយសឹមទទួល ហើយធូតថាសមាសត្រង់ថ្ម លក់ថាសទាំងអស់ ហើយក៏ទៅ ។

ការកោងដោយគ្រឿងវាល់មាន ៣ យ៉ាង គឺ ហទយភេទ (ទម្លាយដោយរន្ធ) ១ សិក្ខាភេទ (ទម្លាយចុង) ១ រជ្ជុភេទ (ទម្លាយដោយខ្សែ) ១ ។ ក្នុង ៣ យ៉ាងនោះ ហទយភេទ បានក្នុងវេលាវាល់ទឹកដោះថ្លា និងប្រេងជាដើម ព្រោះថា កាលទទួលរបស់ទាំងនោះ ប្រើគ្រឿងវាល់ដែលមានរន្ធ

ខាងក្រោម ប្រាប់ថា ឲ្យឃើតៗ ផ្អៀង ឲ្យហូរចូលក្នុងភាជនៈរបស់ខ្លួនច្រើន ហើយទទួលយកទៅ កាលឲ្យ ក៏ប្រញាប់បិទរន្ធហើយឲ្យ ។ សិក្ខាភេទ បានក្នុងវេលាវាល់ល្ង និងអង្ករជាដើម ព្រោះថា កាលទទួលរបស់ទាំងនោះ ក៏ទទួលឃើតៗ ធ្វើខាងលើឲ្យកំពង់ទទួលយកទៅ កាលឲ្យ ក៏ធ្វើឲ្យរហ័ស ពេញ ហើយគាសមាត់ចេញទើបឲ្យ ។ រជ្ជុភេទ បានក្នុងវេលាវាស់ស្រែ និងទីដីជាដើម ព្រោះថា កាលមិនបានសំណូក សូម្បីស្រែតូច ក៏វាស់ឲ្យធំបាន ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងការទទួលសំណូកជាដើម បទថា **ឧក្កោដនំ** (ការទទួលសំណូក) បានដល់ ទទួលសំណូកដើម្បីធ្វើម្ចាស់របស់មិនឲ្យជាម្ចាស់របស់ ។ បទថា **វញ្ចនំ** (ការកុហក) បានដល់ ការកុហកអ្នកដទៃដោយឧបាយនោះៗ ។ ក្នុងបទទាំងពីរនោះ មានរឿងឧបមាដូច្នេះ ។

បានឮថា ព្រានម្នាក់ ដឹកម្រឹគ និងកូនម្រឹគដើរមក ។ អ្នកលេងម្នាក់និយាយចំពោះព្រាននោះថា ព្រាន ម្រឹគតម្លៃប៉ុន្មាន កូនម្រឹគតម្លៃប៉ុន្មាន ។ ព្រានប្រាប់ថា ម្រឹគតម្លៃពីរកហាបណៈ កូនម្រឹគតម្លៃមួយកហាបណៈ ។ អ្នកលេងទើបឲ្យមួយកហាបណៈ ហើយយកកូនម្រឹគទៅ លុះទៅបានបន្តិច ក៏ត្រឡប់មកវិញ និយាយថា ព្រាន យើងមិនត្រូវការកូនម្រឹគ

ចូរឲ្យម្រឹគដល់យើង ។ ព្រាននិយាយថា បើដូច្នោះ លោកចូរឲ្យយើងពីរកហាបណៈ ។ អ្នកលេងនោះនិយាយថា ព្រាន យើងឲ្យមួយកហាបណៈមុនហើយមិនមែនឬ ។ ព្រានឆ្លើយថា ពិតហើយ លោកឲ្យមួយកហាបណៈហើយ ។ អ្នកលេងនិយាយថា មុននោះមួយកហាបណៈ និងកូនម្រឹគនេះក៏មានតម្លៃមួយកហាបណៈ ព្រោះដូច្នោះ ទើបរួមជាពីរកហាបណៈ ។ ព្រានយល់ថា អ្នកលេងនិយាយសមហេតុផល ទើបទទួលកូនម្រឹគមក ហើយឲ្យម្រឹគទៅ ។

បទថា **និកតិ** (ការក្លែងបន្លំ) បានដល់ បញ្ឆោតដោយរបស់ប្រៀបធៀប គឺ ធ្វើវត្ថុដែលមិនមែនសង្វារ ឲ្យជាសង្វារ ធ្វើវត្ថុដែលមិនមែនកែវមណី ឲ្យជាកែវមណី ធ្វើវត្ថុដែលមិនមែនមាស ឲ្យជាមាស ដោយប្រកបឡើង ឬដោយកលល្បិច ។ បទថា **សាវិយោគោ** (ការកោង) បានដល់វិធីកោង បទនេះ ជាឈ្មោះនៃការទទួលសំណូកជាដើមនោះឯង ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងបទនេះ យ៉ាងនេះថា វិធីកោងដោយការទទួលសំណូក វិធីកោងការបញ្ឆោតបន្លំ វិធីកោងដោយការក្លែងបន្លំ ។ អាចារ្យពួកខ្លះពោលថា ការសម្តែងរបស់មួយហើយផ្លាស់ជារបស់មួយទៀត ឈ្មោះថា វិធីកោង ។ ក៏បទនោះ សង្រ្គោះដោយការបញ្ឆោតបន្លំនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការកាត់ជាដើម ។ បទថា **ឆេទនំ** (ការកាត់) បានដល់ ការកាត់ដៃជាដើម ។ បទថា **វធោ** ការសម្លាប់) បានដល់ ធ្វើឲ្យស្លាប់ ។ បទថា **ពន្ធោ** (ការចង) បានដល់ ចងដោយគ្រឿងចង គឺ ខ្សែជាដើម ។ បទថា **វិបរាមោសោ** (ការលាក់ខ្លួនចាំធ្វើអាក្រក់) បានដល់ ការលាក់ខ្លួនមាន ២ យ៉ាង គឺ ហិមវិបរាមោសៈ (លាក់ខ្លួនក្នុងទីទឹកកកធ្លាក់) ១ គុម្ពវិបរាមោសៈ (លាក់ខ្លួនក្នុងគុម្ពោតព្រៃ) ១ ។ ក្នុងគ្រាទឹកកកធ្លាក់ ចោរទាំងឡាយយកទឹកកកបិទបាំងខ្លួន វាយដណ្តើមទ្រព្យអ្នកដំណើរ ឈ្មោះថា ហិមវិបរាមោសៈ ។ ចោរទាំងឡាយ យកគុម្ពោតព្រៃជាដើមបិទបាំងខ្លួន ហើយចាំវាយដណ្តើមយកទ្រព្យ ឈ្មោះថា គុម្ពវិបរាមោសៈ ។ វិធីកោង ដោយការប្លន់អ្នកស្រុក និងអ្នកនិគមជាដើម លោកហៅថា **អាលោបោ** (ការប្លន់) ។ បទថា **សហសាការោ** (គម្រាមកំហែង) បានដល់ ការធ្វើយ៉ាងខ្លាំងក្លា ។ គឺ ការចូលទៅផ្ទះ យកសស្ត្រាចង្អុលទ្រូងរបស់ពួកមនុស្ស ហើយរក្សារបស់ដែលខ្លួនត្រូវការ ។ ព្រោះដូច្នោះ ភិក្ខុនោះជាអ្នកវៀរដាច់ខាតចាកការធ្វើយ៉ាងនោះ គឺ កាប់ ចាក់ សម្លាប់ កាត់ ពួនធ្វើអាក្រក់ ប្លន់ ដោយប្រការដូច្នេះឯង ។

បទថា **សោ សន្តុដ្ឋោ ហោតិ** (លោកជាអ្នកសន្តោស) បានដល់

ភិក្ខុនោះ ជាអ្នកប្រកបដោយសេចក្តីសន្តោសដោយបច្ច័យ តាមមានតាម បាន ១២ យ៉ាង ក្នុងបច្ច័យ ៤ ដែលពោលទុកហើយក្នុងខាងក្រោយ ។ បរិក្ខារ ៨ គឺ ត្រៃចីវរ បាត្រ កាំបិតកោរ ឈើសួន់ ម្ជុល វត្ថពន្ធចង្កេះ តម្រងទឹក រមែងសមគួរដល់ភិក្ខុដែលប្រកបដោយសេចក្តីសន្តោស ត្រេកអរ ក្នុងបច្ច័យ តាមមានតាមបាន ១២ យ៉ាងនេះ ។ ដូចដែលលោកពោលទុក ថា

> បរិក្ខារ ៨ ទាំងនេះ គឺ ត្រៃចីវរ បាត្រ កាំបិត ម្ជុល
> វត្ថពន្ធចង្កេះ តម្រងទឹក សម្រាប់ភិក្ខុដែលប្រកបដោយ
> សេចក្តីព្យាយាម ។

បរិក្ខារទាំងអស់នោះ ជាគ្រឿងរក្សាកាយខ្លះ រក្សាផ្ទៃខ្លះ ។ សួរថា រក្សាដូចម្តេច ។ ឆ្លើយថា ត្រៃចីវរ រមែងរក្សាកាយក្នុងវេលាភិក្ខុស្លៀក និងដណ្តប់ហើយចារិកទៅ ព្រោះដូច្នោះ ទើបជាគ្រឿងរក្សាកាយ ។ ត្រៃចីវរ រមែងរក្សាផ្ទៃក្នុងវេលាយកជាយចីវរត្រងទឹកផឹក និងក្នុងវេលាគ្របរបស់ ទំពារ និងផ្លែឈើ ព្រោះដូច្នោះ ទើបជាគ្រឿងរក្សាផ្ទៃ ។ សូម្បីបាត្រ ក៏ ជាគ្រឿងរក្សាកាយ ក្នុងវេលាយកបាត្រនោះដងទឹកងូត និងក្នុងវេលាធ្វើការ សម្អាតកុដិ ជាគ្រឿងរក្សាផ្ទៃ ក្នុងវេលាទទួលអាហារបរិភោគ ។ សូម្បី

កាំបិត ក៏ជាគ្រឿងរក្សាកាយ ក្នុងវេលាយកកាំបិតនោះសម្រួចឈើស្ទន់ និង ក្នុងវេលាតាក់តែងចំណែកនៃជើងគ្រែ និងតាំង និងដងឆ័ត្រ ជាគ្រឿងរក្សាផ្ទៃ ក្នុងវេលាសកអំពៅ និងបកដូងជាដើម ។ ម្ជុលជាគ្រឿងរក្សាកាយ ក្នុងវេលាដេរចីវរ ជាគ្រឿងរក្សាផ្ទៃ ក្នុងវេលាចាក់នំ ឬផ្លែឈើទំពារស៊ី ។ វត្ថពន្ធចង្កេះជាគ្រឿងរក្សាកាយ ក្នុងវេលាកាយត្រាច់ទៅ ជាគ្រឿងបរិហារផ្ទៃ ក្នុងវេលាចងអំពៅជាដើម ហើយយួរទៅ ។ តម្រងទឹក ជាគ្រឿងរក្សាកាយ ក្នុងវេលាយកគ្រឿងត្រងទឹកនោះ ត្រងទឹកផ្ទូត និងក្នុងវេលាធ្វើការសម្អាតសេនាសនៈ ជាគ្រឿងរក្សាផ្ទៃ ក្នុងវេលាត្រងទឹកផឹក និងក្នុងវេលាដាក់ល្ង អង្ករ និងអំបុកជាដើម ដោយគ្រឿងតម្រងទឹកនោះទំពារស៊ី ។ នេះត្រឹមតែបរិក្ខាររបស់ភិក្ខុ ដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ។

តែសម្រាប់ភិក្ខុដែលមានបរិក្ខារ ៩ ដែលចូលទៅកាន់ទីដេក កម្រាលដែលតាំងនៅលើទីដេកនោះ ឬសោរ រមែងគួរ ។ សម្រាប់ភិក្ខុមានបរិក្ខារ ១០ ទីអង្គុយ ឬបន្ទះស្បែក រមែងគួរ ។ សម្រាប់ភិក្ខុដែលមានបរិក្ខារ ១១ ឈើច្រត់ ឬដបប្រេង រមែងគួរ ។ សម្រាប់ភិក្ខុដែលមានបរិក្ខារ ១២ ឆ័ត្រ ឬស្បែកជើង រមែងគួរ ។ បណ្ដាភិក្ខុដែលមានបរិក្ខារទាំងនេះ ភិក្ខុដែលមានបរិក្ខារ ៨ ប៉ុណ្ណោះ ជាអ្នកសន្តោស ។ មិនគួរពោលភិក្ខុក្រៅពី

នោះថា ជាអ្នកមិនសន្តោស ជាអ្នកប្រាថ្នាច្រើន ប្រាថ្នាធំ ។ ស្ចប្បីភិក្ខុទាំងនេះ ក៏ជាអ្នកប្រាថ្នាតិច សន្តោស ចិញ្ចឹមងាយ មានការប្រព្រឹត្តស្រាល ។ តែព្រះមានព្រះភាគ មិនបានត្រាស់ព្រះសូត្រនេះ ដោយសំដៅយកភិក្ខុទាំងនោះ ។ ត្រាស់ដោយសំដៅយកភិក្ខុដែលមានបរិក្ខារ ៨ ។ ពិតណាស់ ភិក្ខុដែលមានបរិក្ខារ ៨ នោះ ដាក់កាំបិតតូច និងម្ជុលក្នុងថ្នាំងតម្រងទឹក ហើយដាក់ទុកក្នុងបាត្រ ស្ពាយបាត្រស្ពាយនៅស្មា ធ្វើត្រៃចីវរឲ្យណែនកាយ គេចចេញទៅរកសេចក្តីសុខតាមប្រាថ្នា ។ ឈ្មោះថា ភិក្ខុនោះនឹងត្រឡប់មកកាន់យកអ្វីទៀតមិនមាន ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងថា ភិក្ខុនេះ ជាអ្នកមានការប្រព្រឹត្តស្រាល ទើបត្រាស់ថា ភិក្ខុជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ ជាដើម ។

ក្នុងបទទាំងនោះ បទថា **កាយបរិហារិកេន** (ជាគ្រឿងរក្សាកាយ) បានដល់ ត្រឹមតែជាគ្រឿងរក្សាកាយ ។ បទថា **កុច្ឆិបរិហារិកេន** (ជាគ្រឿងរក្សាផ្ទៃ) បានដល់ ត្រឹមតែជាគ្រឿងរក្សាផ្ទៃ ។ បទថា **សមាទាយេវ បក្កមតិ** (កាន់ទៅបានឯង) សេចក្តីថា ភិក្ខុកាន់យកបរិក្ខារទាំងអស់នោះត្រឹមតែ ៨ យ៉ាង ជាប់ទៅជាមួយកាយ ភិក្ខុនោះមិនមានសេចក្តីជាប់ជំពាក់ថា វិហាររបស់យើង បរិវេណរបស់យើង ឧបដ្ឋាករបស់យើង ។ ភិក្ខុនោះ

ប្រើប្រាស់សេនាសនៈ ព្រៃស្បាត់ គល់ឈើ ព្រៃ ញកក្តី ដែលខ្លួនប្រាថ្នាហើយ ដូចកូនសរចេញផុតអំពីខ្សែធ្នូ ដូចដំរីចុះប្រេងចៀសចេញចាកហ្វូងដូច្នោះ ឈរតែម្នាក់ឯង អង្គុយតែម្នាក់ឯង តែម្នាក់ឯងគ្រប់ឥរិយាបថ មិនមានសម្លាញ់ ដល់ភាពដូចជាដូចកុយរមាស ដែលលោកពណ៌នាទុកយ៉ាងនេះថា

> ភិក្ខុដែលសន្តោសដោយបច្ច័យតាមមានតាមបាន
> ត្រាច់ទៅទាំង ៤ ទិស មិនបដិឃៈ អត់ធន់ចំពោះ
> អន្តរាយ មិនភ័យតក់ស្លុត ត្រាច់ទៅតែម្នាក់ឯង
> ដូចកុយរមាស ។

ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សាធកៈសេចក្តីនោះ ដោយការឧបមា ទើបត្រាស់ពាក្យជាអាទិ៍ថា **សេយ្យថាបិ** (យ៉ាងណា) ។ ក្នុងបទទាំងនោះ បទថា **បក្ខី សកុណោ** បានដល់ សត្វមានស្លាប ។ បទថា **ឌេតិ** (នឹងហើរ) បានដល់ ហើរទៅ ។ សេចក្តីសង្ខេបក្នុងរឿងនេះ មានដូច្នេះ ធម្មតាសត្វទាំងឡាយដឹងថា ទីឯណោះមានដើមឈើ មានផ្លែទុំ ទើបនាំគ្នាមកពីទិសផ្សេងៗ យកក្រចក ស្លាប និងចំពុះជាដើម ចឹកស៊ីផ្លែឈើនៃដើមឈើនោះ បក្សីទាំងនោះមិនបានគិតថា ផ្លែឈើទាំងនេះសម្រាប់ថ្ងៃនេះ

ផ្លែនេះសម្រាប់ថ្ងៃស្អែក ក៏កាលផ្លែឈើអស់ បក្សីទាំងឡាយមិនបានដាក់ការ រក្សាដើមឈើ មិនបានដាក់ស្លាប រោម ក្រចក ឬចំពុះ ទុកត្រង់ដើមឈើ នោះ មិនហួងហែងដើមឈើនោះ ប្រាថ្នានឹងទៅទិសណា ក៏មានភារៈ គឺ ស្លាបប៉ុណ្ណោះ ហើរទៅកាន់ទិសនោះ ភិក្ខុនេះក៏ដូចគ្នា អស់សេចក្តីជាប់ ជំពាក់ អស់សេចក្តីហួងហែង ចៀសចេញទៅ គឺ កាន់យកត្រឹមតែបរិក្ខារ ៨ ប៉ុណ្ណោះ ។ បទថា **អរិយេន** (ដែលជាអរិយៈ) បានដល់ មិនមានទោស ។ បទថា **អជ្ឈត្តំ** (ខាងក្នុង) បានដល់ ក្នុងអត្តភាពរបស់ខ្លួន ។ បទថា **អនវ-ជ្ជសុខំ** (សុខប្រាសចាកទោស) បានដល់ សេចក្តីសុខដែលមិនមានទោស ។

បទថា **សោ ចក្ខុនា រូបំ ទិស្វា** (ភិក្ខុឃើញរូបដោយចក្ខុ) សេចក្តីថា ភិក្ខុនោះ ប្រកបហើយដោយសីលក្ខន្ធដែលជាអរិយៈនេះ ឃើញរូបដោយ ចក្ខុវិញ្ញាណ ។ សូម្បីក្នុងបទដ៏សេស បទដែលគួរពោល ក៏បានពោលទុក អស់ហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **អព្យាសេកសុខំ** (សុខដែលបរិសុទ្ធ មិនលាយដោយកិលេស) បានដល់ សេចក្តីសុខមិនសើមដោយកិលេស ។ លោកពោលថា **អវិកិណ្ណសុខំ** ដូច្នេះខ្លះ ។ ព្រោះថា សុខកើតពីឥន្ទ្រិយសំវរៈ ឈ្មោះថា ជាសេចក្តីសុខដែលមិនក្រវល់ក្រវាយ ព្រោះប្រព្រឹត្តទៅត្រឹមតែ ថា ឃើញជាដើម ក្នុងអារម្មណ៍មានរូបដែលខ្លួនឃើញជាដើមប៉ុណ្ណោះ ។

បទថា **សោ អភិក្កន្តេ បដិក្កន្តេ** (ភិក្ខុ... ក្នុងឈានទៅ ក្នុងការថយក្រោយ) សេចក្ដីថា ភិក្ខុដែលប្រកបដោយការសង្រួមឥន្ទ្រិយ ដែលមានចិត្តជាទី ៦ រមែងជាអ្នកធ្វើសេចក្ដីដឹងខ្លួន ដោយសតិសម្បជញ្ញៈក្នុងឋានៈ ៧ មានឈានទៅ និងថយត្រឡប់ជាដើម ។ ក្នុងបទទាំងនោះ បទថា **អភិក្កន្តំ** (ឈានទៅ) បានដល់ ដើរទៅខាងមុខ ។ បទថា **បដិក្កន្តំ** (ថយត្រឡប់) បានដល់ ថយក្រោយ ។ បទថា **សម្បជានការី ហោតិ** (ធ្វើសេចក្ដីដឹងខ្លួន) សេចក្ដីថា ភិក្ខុចូលទៅតាំងសតិទុក ដោយអំណាចសម្បជញ្ញៈដែលសម្បយុត្តដោយសតិ ៤ ទាំងនេះ គឺ **សាត្ថកសម្បជញ្ញៈ** (សេចក្ដីដឹងខ្លួនក្នុងកិច្ចដែលជាប្រយោជន៍ដល់ខ្លួន) **សប្បាយសម្បជញ្ញៈ** (សេចក្ដីដឹងខ្លួនក្នុងបច្ច័យដែលសប្បាយ) **គោចរសម្បជញ្ញៈ** (សេចក្ដីដឹងខ្លួនក្នុងធម៌ជាគោចរ) **អសម្មោហសម្បជញ្ញៈ** (សេចក្ដីដឹងខ្លួនក្នុងការមិនវង្វេង) ហើយកំណត់ដោយញាណ ធ្វើការឈានទៅ និងថយត្រឡប់នោះឯង ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ នេះជាសេចក្ដីសង្ខេបក្នុងទីនេះ ចំណែកសេចក្ដីពិស្ដារ លោកអ្នកប្រាថ្នា គប្បីមើលបានពីអដ្ឋកថាសាមញ្ញផលសូត្រក្នុងទីឃនិកាយ ឬពីអដ្ឋកថាសតិប្បដ្ឋានសូត្រក្នុងមជ្ឈិមនិកាយ ។

សួរថា ព្រះមានព្រះភាគទ្រង់សម្ដែងដល់អ្វី ដោយបទមានជាអាទិ៍ថា

*សោ ឥមិនា ច (ភិក្ខុ... ដូច្នេះ)* ។ ឆ្លើយថា ទ្រង់សម្តែងដល់បច្ច័យសម្បត្តិរបស់ភិក្ខុដែលនៅព្រៃ ។ ព្រោះថា បច្ច័យ ៤ ទាំងនេះ មិនមានដល់ភិក្ខុណា ការនៅព្រៃរបស់ភិក្ខុនោះរមែងមិនសម្រេច ភិក្ខុនោះគួរនឹងត្រូវពោល (ប្រៀប) ដោយសត្វតិរច្ឆាន ឬពួកព្រាន ។ ទេវតាដែលស្ថិតនៅក្នុងព្រៃនឹងនាំគ្នាធ្វើសំឡេងដែលគួរខ្លាចថា ប្រយោជន៍អ្វីដោយការនៅក្នុងព្រៃរបស់ភិក្ខុលាមកបែបនេះ ដូច្នេះ ហើយខោកក្បាលបណ្តេញឲ្យចេញទៅ ។ ការមិនមានកិត្តិយសក៏នឹងផ្សាយចេញទៅថា ភិក្ខុរូបឯណោះចូលទៅព្រៃ បានធ្វើកម្មដ៏លាមកយ៉ាងនេះៗ ។

ក៏បច្ច័យ ៤ ទាំងនេះមាននៅដល់ភិក្ខុណា ការនៅព្រៃរបស់ភិក្ខុនោះរមែងសម្រេច ។ ព្រោះថា ភិក្ខុនោះពិចារណាសីលរបស់ខ្លួន កាលមិនឃើញសៅហ្មង ឬដាច់ ក៏កើតបីតិ កាលឃើញបីតិនោះដោយការអស់ទៅ ដោយការវិនាសទៅ រមែងឈានចុះកាន់អរិយភូមិ ។ ពួកទេវតាដែលស្ថិតនៅក្នុងព្រៃ មានចិត្តត្រេកអរក៏នាំគ្នាសរសើរ កិត្តិយសរបស់ភិក្ខុនោះរមែងផ្សាយចេញទៅ ដូចតំណក់ប្រេងដែលគេដាក់ចុះក្នុងទឹក ដោយប្រការដូច្នេះ ។

បទថា ***វិវិត្តំ*** *(ស្ងាត់)* បានដល់ ព្រៃមានសំឡេងតិច ។ អធិប្បាយ

ថា មានសំឡេងអឺកធឹកតិច ។ ក្នុងវិកប្បសំដៅដល់សំឡេងអឺកធឹកតិចនោះ ទើបពោលទុកថា បទថា ដែលស្ងាត់ សេចក្ដីថា សូម្បីសេនាសនៈនៅជិតគ្នា តែសេនាសនៈនោះមិនខ្វល់ខ្វាយដោយគ្រហស្ថបព្វជិត ព្រោះហេតុនោះ សេនាសនៈនោះទើបឈ្មោះថា ស្ងាត់ ។ ឈ្មោះ សេនាសនៈ ព្រោះជាទីដេក និងដែលអង្គុយ ។ ពាក្យនេះជាឈ្មោះរបស់គ្រែ និងតាំងជាដើម ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា សេនាសនៈ បានដល់ គ្រែខ្លះ ទីដេក ទីអង្គុយខ្លះ តាំងខ្លះ ពូកខ្លះ ខ្នើយខ្លះ វិហារខ្លះ ផ្ទះដំបូលមួយខ្លះ ប្រាសាទខ្លះ ប្រាសាទត្រងោលខ្លះ ល្អាងខ្លះ ប៉មខ្លះ ផ្ទះកំពូលខ្លះ ទីពួនសម្ងំខ្លះ គុម្ពឫស្សីខ្លះ គល់ឈើខ្លះ មណ្ឌបខ្លះ ឬថា ភិក្ខុទាំងឡាយចៀសចេញទៅក្នុងទីណា ទីទាំងអស់នោះឈ្មោះថា សេនាសនៈ ។ម្យ៉ាងទៀត សេនាសនៈនេះ គឺ វិហារ ផ្ទះដំបូលមួយ ប្រាសាទ ប្រាសាទត្រងោល ល្អាង ឈ្មោះសេនាសនៈ គឺ វិហារ ។ សេនាសនៈនេះ គឺ គ្រែ តាំង ពូក ខ្នើយ ឈ្មោះថា សេនាសនៈ គឺ គ្រែតាំង ។ សេនាសនៈនេះ គឺ បន្ទះស្បែកធ្វើស្រោមខ្នើយ កម្រាលស្មៅ កម្រាលស្លឹកឈើ ឈ្មោះថាសេនាសនៈ គឺ សន្ថត ។ ឬថា ភិក្ខុទាំងឡាយចៀសចេញទៅក្នុងទីណា នេះឈ្មោះថា សេនាសនៈ គឺ ឱកាស ។ សេនាសនៈមាន ៤ យ៉ាង ដោយប្រការដូច្នេះ ។

សម្បីសេនាសនៈនោះ លោកប្រើស័ព្ទថា សេនាសនៈ ដូចគ្នាទាំងអស់ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់សេនាសនៈដែលសមគួរដល់ភិក្ខុអ្នកចារិកទៅក្នុងទិសទាំង ៤ ដូចជាបក្សីនេះ ទើបត្រាស់ថា **អរញ្ញំ រុក្ខមូលំ** (ព្រៃ គល់ឈើ) ជាដើម ។ ក្នុងបទទាំងនោះ បទថា **ព្រៃ** បានដល់ ទីដែលចេញទៅខាងក្រៅពីសសរខឿនទាំងអស់ ។ បទថា **ព្រៃ** នេះ ចាត់ថាព្រៃ ដែលមកព្រោះអំណាចភិក្ខុនី (បទបញ្ញត្តិរបស់ភិក្ខុនីហាមមិនឲ្យនៅព្រៃ) ។ ឈ្មោះថា សេនាសនៈព្រៃ បានដល់ សេនាសនៈដែលកំណត់ទុកប្រមាណ ៥០០ ធ្នូ ព្រោះដូច្នោះ សេនាសនៈនេះ ទើបគួរដល់ភិក្ខុនេះ ។ លក្ខណៈនៃសេនាសនៈនោះ ពោលទុកហើយក្នុងធុតង្គ-និទ្ទេស គម្ពីរវិសុទ្ធិមគ្គ ។ បទថា **រុក្ខមូលំ** (គល់ឈើ) បានដល់ គល់ឈើដែលស្ងាត់ មានម្លប់ក្រាស់កន្លែងណាមួយ ។ បទថា **បព្វតំ** (ភ្នំ) បានដល់ ភ្នំថ្ម ។ ពិតហើយ ក្នុងទីនោះ ភិក្ខុងូតទឹកត្រង់ថ្លុកទឹក ហើយអង្គុយក្រោមម្លប់ឈើដ៏ត្រជាក់ កាលទិសផ្សេងៗ ប្រាកដហើយ ត្រូវខ្យល់ត្រជាក់បក់មក ចិត្តក៏មានអារម្មណ៍តែមួយ ។ បទថា **កន្ទរំ** (ញកភ្នំ) មានវិនិច្ឆ័យថា ទឹក លោកហៅថា **កំ** ចំណែកខ្លះនៃភ្នំដែលត្រូវទឹកប្រោះ ដាច់ព្រោះទឹក គេហៅថា **និតម្ពៈ** (ចង្កេះភ្នំ) ខ្លះ ថ្លុកទឹកខ្លះ ពោះភ្នំខ្លះ ។ ក៏ក្នុងទីនោះ

មានខ្សាច់ពណ៌ស្រដៀងផែនប្រាក់ ។ ទឹកស្រដៀងដុំកែវមណី ហូរទៅខាងលើដងព្រៃ ដូចពិតានកែវមណី ភិក្ខុចុះទៅកាន់ថ្នុកទឹកបែបនេះ ផឹកទឹក យកទឹកលាបស្រឡាបខ្លួនឲ្យត្រជាក់ ពូនខ្សាច់ឡើង ហើយក្រាលសំពត់បង្សុកូលចីវរ អង្គុយបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយ ។ បទថា **គិរិគុហំ** (ល្អាង) បានដល់ ចន្លោះភ្នំពីរ ឬប្រហោងធំ ស្រដៀងខម្មន្តក្នុងភ្នំមួយ ។ លក្ខណៈ **ព្រៃខ្មោច** បានពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **វនបត្ថំ** (ដងព្រៃ) បានដល់ ទីដែលកន្លងឧបចារៈរបស់ពួកមនុស្ស ដែលគេមិនភ្ជួររាស់ ។ ព្រោះហេតុនោះឯង លោកទើបពោលពាក្យមានជាអាទិ៍ថា បទថា **ដងព្រៃ** នេះ ជាឈ្មោះរបស់សេនាសនៈដែលនៅឆ្ងាយ ។ បទថា **អព្ភោកាសំ** (ទីវាល) បានដល់ ទីមិនមានការប្រក់បាំង ។ ក៏ភិក្ខុកាលប្រាថ្នា ក៏ធ្វើឆត្រក្នុងទីនេះហើយនៅចុះ ។ បទថា **បលាលបុញ្ជំ** (គំនរចំបើង) បានដល់ គំនរចំបើង ។ ពិតហើយ ភិក្ខុទាំងឡាយនាំចំបើងមកពីគំនរចំបើង ហើយធ្វើឲ្យជាទីនៅ ស្រដៀងទីពួនសម្ងំក្នុងញកភ្នំ ដាក់ចំបើងទុកខាងលើមែកឈើ គល់ឈើជាដើម ហើយអង្គុយខាងក្រោមធ្វើសមណធម៌ ។ លោកពោលបទនេះ សំដៅដល់ចំបើងនោះ ។

បទថា **បច្ឆាភត្តំ** បានដល់ ខាងក្រោយនៃភត្ត (អាហារ) ។ បទថា

**បិណ្ឌបាតបដិក្កន្តោ** (ត្រឡប់ពីបិណ្ឌបាត) បានដល់ ត្រឡប់ពីការស្វែងរកបិណ្ឌបាត ។ បទថា **បល្លង្កំ** (បល្ល័ង្ក) បានដល់ អង្គុយពត់ភ្នែនតម្រង់កាយឲ្យត្រង់ ។ បទថា **អាភុជិត្វា** បានដល់ ប្រុងស្មារតី ។ បទថា **ឧជុំ កាយំ បណិធាយ** (តាំងកាយឲ្យត្រង់) បានដល់ តាំងសរីរៈខាងលើឲ្យត្រង់ ឲ្យចុងឆ្អឹងខ្នងទាំង ១៨ កង់ទល់គ្នា កាលអង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃក៏មិនកោង ដូច្នោះ វេទនាពួកណាដែលមានការកោងជាបច្ច័យ នឹងគប្បីកើតឡើងគ្រប់ខណៈដល់ភិក្ខុទាំងនោះ វេទនានោះក៏នឹងមិនកើតឡើង កាលវេទនាទាំងនោះមិនកើត ចិត្តក៏រមែងមានអារម្មណ៍តែមួយ កម្មដ្ឋានក៏មិនធ្លាក់ចុះ មានតែចម្រើនដុះដាលឡើង ។

បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** (តាំងសតិទុកចំពោះមុខ) សេចក្តីថា តាំងសតិឆ្ពោះកម្មដ្ឋាន ឬធ្វើទុកជិតមុខ ។ ព្រោះហេតុនោះឯង លោកទើបពោលទុកក្នុងវិភង្គថា សតិនេះជាការចូលទៅតាំងទុកហើយ ចូលទៅតាំងទុកហើយដោយល្អ ត្រង់ចុងច្រមុះ ឬត្រង់មុខនិមិត្តជិតមុខ ព្រោះហេតុនោះ លោកទើបពោលថា តាំងសតិទុកចំពោះមុខ ។ ន័យម្យ៉ាងទៀត **បរិ** ស័ព្ទ មានអត្ថថា កំណត់ **មុខំ** ស័ព្ទ មានអត្ថថា នាំចេញទៅ ។ បទថា **សតិ** មានអត្ថថា ប្រាកដ ព្រោះហេតុនោះ ទើបពោលថា **បរិមុខំ សតឹ**

(តាំងសតិទុកចំពោះមុខ) ។ សេចក្តីសង្ខេបក្នុងបដិសម្ភិទា ធ្វើសតិដែលកំណត់ទុក និងនាំចេញទៅ ។

ក្នុងបទថា **អភិជ្ឈំ លោកេ** (សេចក្តីលោភក្នុងលោក) នេះ ឧបាទានក្ខន្ធ ៥ ឈ្មោះថា លោក ព្រោះអត្ថថា ទ្រុឌទ្រោមទៅ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា លះរាគៈ គ្របសង្កត់កាមច្ឆន្ទៈក្នុងឧបាទានក្ខន្ធ ៥ ។ បទថា **វិគតាភិជ្ឈេន** (មានចិត្តប្រាសចាកសេចក្តីលោភ) សេចក្តីថា មានចិត្តប្រាសចាកសេចក្តីលោភ ព្រោះលះបានដោយការគ្របសង្កត់ មិនមែនមានចិត្តដូចជាចក្ខុវិញ្ញាណ ។ បទថា **អភិជ្ឈាយ ចិត្តំ បរិសោធេតិ** (រមែងជម្រះចិត្តឲ្យបរិសុទ្ធពីសេចក្តីលោភ) បានដល់ ជម្រះចិត្តឲ្យបរិសុទ្ធពីអភិជ្ឈា ។ អធិប្បាយថា ភិក្ខុធ្វើដោយអាការដែលអភិជ្ឈាត្រូវលះបង់ហើយ មិនត្រឡប់មកគោងចិត្តទៀត ។ សូម្បីក្នុងបទថា **ព្យាបាទប្បទោសំ បហាយ** (លះទោសមនស្ស គឺ ព្យាបាទ) ជាដើម ក៏ន័យនេះដូចគ្នា ។ ឈ្មោះថា ព្យាបាទ ព្រោះជាហេតុបៀតបៀនចិត្ត គឺ ចិត្តត្រូវលះភាពប្រក្រតីដែលធ្លាប់មានមកក្នុងកាលមុន ដោយព្យាបាទនេះ ដូចនំផ្អូមជាដើម ។ ឈ្មោះថា បទោសៈ ព្រោះប្រទូស្តខ្លួនឯង ឬប្រទូស្តអ្នកដទៃ គឺឲ្យអ្នកដទៃវិនាស ឲ្យដល់នូវភាពពិការ ។ ទាំងពីរនេះ ជាឈ្មោះរបស់សេចក្តី

ក្រោធនោះឯង ។

ជម្ងឺផ្លូវចិត្ត ឈ្មោះថា **ថីន:** ។ ជម្ងឺផ្លូវចេតសិក ឈ្មោះថា **មិទ្ធ:** ថីន: និងមិទ្ធ: ឈ្មោះថា **ថីនមិទ្ធ:** ។ បទថា **អាលោកសញ្ញី** (មានការកំណត់ទីភ្លឺស្រឡះ) សេចក្តីថា ភិក្ខុប្រកបដោយសញ្ញាដែលបរិសុទ្ធប្រាស-ចាកនីវរណៈ អាចកំណត់ពន្លឺដែលឃើញ ទាំងពេលយប់ទាំងពេលថ្ងៃ ។ បទថា **សតោ សម្បជានោ** (មានសតិមានសម្បជញ្ញ:) បានដល់ ប្រកបដោយសតិ និងញាណ ។ លោកពោលទុកទាំងពីរនេះ ក៏ព្រោះជាធម៌ឧបការៈដល់អាលោកសញ្ញា ។ សេចក្តីរាយមាយ និងសេចក្តីរំខាន ឈ្មោះថា **ឧទ្ធច្ច-កុក្កុច្ច:** ។

បទថា **តិណ្ណវិចិកិច្ឆោ** ឆ្លងវិចិកិច្ឆា) បានដល់ ឆ្លង គឺ កន្លងវិចិកិច្ឆាបាន ។ ឈ្មោះថា **អកថំកថី** (មិនមានសេចក្តីសង្ស័យ) ព្រោះមិនមានសេចក្តីសម្គាល់ថា នេះជាអ្វី នេះជាអ្វី ។ បទថា **កុសលេសុ ធម្មេសុ** (ក្នុងកុសលធម៌ទាំងឡាយ) បានដល់ ក្នុងធម៌ដែលមិនមានទោស ។ អធិប្បាយថា មិនសង្ស័យ គឺ មិនឆ្ងល់យ៉ាងនេះថា ធម៌ទាំងនេះមិនមែនជាកុសល ធម៌ទាំងនេះជាកុសល ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។ ក៏ក្នុងនីវរណៈទាំងនេះ ពាក្យដែលគួរពោល មានបទ សេចក្តី និងលក្ខណៈជាដើម ក៏បាន

ពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **បញ្ញាយ ទុព្វលីករណេ** (ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វល) សេចក្តីថា ព្រោះហេតុនីវរណៈទាំង ៥ នេះ កាលកើត រមែងមិនឲ្យកើតបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ដែលមិនទាន់កើតឡើង សូម្បីកើតឡើងហើយ ក៏កម្ចាត់សមាបត្តិ ៨ ឬអភិញ្ញា ៥ ឲ្យធ្លាក់ចុះ ដូច្នោះ ទើបត្រាស់ថា **ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វល** ។ បទទាំងឡាយមានជាអាទិ៍ថា **វិវិច្ចេវ កាមេហិ** (ស្ងាត់ចាកកាម) បានពោលទុកពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទជាដើមថា **ឥមេ អាសវា** (អាសវៈទាំងនេះ) ត្រាស់ដើម្បីប្រកាសសច្ចៈ ៤ ដោយបរិយាយដទៃទៀត ។ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីដែលលទ្ធិខាងក្រៅមិនមានផល ដោយអង្គ ៣ ក្នុងខាងក្រោយ ហើយទ្រង់ប្រកាសនូវពាក្យទូន្មានរបស់ព្រះអង្គដ៏ជ្រាលជ្រៅដោយអង្គទី ៤ ទ្រង់បញ្ចប់ទេសនាឲ្យដល់កំពូលធម៌ គឺ ព្រះអរហត្ត ដោយបទត្រឹមប៉ុណ្ណោះថា **នាបរំ ឥត្ថត្តាយាតិ បជានាតិ** (ដឹងច្បាស់ថា... កិច្ចដទៃដើម្បីជាយ៉ាងនេះ មិនមាន) ដូច្នេះ ។ ឥឡូវនេះ កាលនឹងទ្រង់ធ្វើព្រះទេសនាឲ្យតម្កល់ស៊ប់ ទើបត្រាស់បទជាអាទិ៍ថា **ឯវំ ខោ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ ដូច្នេះឯង) ដូច្នេះ ។

ចប់អដ្ឋកថា អត្តន្តបសូត្រទី ៨

# អដ្ឋកថា តណ្ហាសូត្រទី ៩

## *“តណ្ហាដូចជាសំណាញ់”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តណ្ហាសូត្រទី ៩ ដូចតទៅនេះ ៖*

*[៤៩] បទថា **ជាលិនី** គឺ ដូចសំណាញ់ ។ អធិប្បាយថា ដែលឈ្មោះថា សំណាញ់ដែលគេក្រងទុក ជំពាក់ ស្មុកស្មាញដោយជុំវិញ យ៉ាងណា សូម្បីតណ្ហាក៏ដូច្នោះ លោកហៅថា **សំណាញ់** ព្រោះដូចជាសំណាញ់ ។ តណ្ហាឈ្មោះថា **សំណាញ់** ព្រោះតណ្ហានេះ គ្របសង្កត់ភព ៣ មានសំណាញ់ដែលជាចំណែករបស់ខ្លួនក្នុងភពនោះៗ ដូច្នេះក៏មាន ។ បទថា **សំសរិតំ** (ត្រាច់រង្គាត់) គឺ ត្រាច់ទៅក្នុងភពនោះៗ ។ បទថា **វិសដំ** (ផ្សាយទៅ) បានដល់ ផ្សាយទៅ គឺ ជ្រួតជ្រាបទៅ ។ បទថា **វិសត្តិកំ** ជាប់នៅក្នុងអារម្មណ៍ផ្សេងៗ) បានដល់ ជាប់ជំពាក់នៅក្នុងភពនោះៗ ។ម្យ៉ាងទៀត គប្បីឃើញអត្ថដោយន័យជាដើមថា តណ្ហាឈ្មោះ **វិសត្តិកា** ព្រោះមានឫសជាពិស តណ្ហាឈ្មោះ **វិសត្តិកា** មានផ្លែជាពិស ដូច្នេះ ។ បទថា **ឧទ្ធស្តោ** (គ្របដណ្តប់) បានដល់ គ្របដណ្តប់ខាងលើ ។ បទថា **បរិយោនទ្ធោ** (រុំព័ទ្ធ) បានដល់ រួបរឹតទុកដោយជុំវិញ ។*

*បទថា **តន្តាកុលកជាតោ** (ស្មុកស្មាញដូចជាអំបោះដែលជំពាក់) គឺ*

ស្អុកស្អាញដូចអំបោះជំពាក់ ។ អធិប្បាយថា អំបោះជាងតម្បាញដែលគេរក្សាទុកមិនល្អ ត្រូវកណ្ដុរកាត់ រមែងស្អុកស្អាញក្នុងទីនោះៗ លំបាកនឹងកំណត់ចុងនឹងចុង ឬគល់នឹងគល់ ថា នេះចុង នេះគល់ យ៉ាងណា សត្វទាំងឡាយក៏ដូច្នោះ ត្រូវតណ្ហានេះរួបរឹត ចាក់ស្រែះ មិនអាចនឹងធ្វើផ្លូវស្រុះចេញពីតណ្ហារបស់ខ្លួនឲ្យត្រង់បាន ។ បទថា **គុលាគុណ្ឋិកជាតោ** (ដែលជំពាក់ដូចអំបោះប្រឡាក់ដោយទឹកបាយ) បានដល់ អំបោះដែលសើមដោយទឹកបាយរបស់ជាងតម្បាញ លោកហៅថា **គុលាគុណ្ឋិកៈ** (អំបោះប្រឡាក់ទឹកបាយ) អាចារ្យពួកមួយពោលថា សំបុករបស់បក្សី ឈ្មោះថា **គុលា** ដូច្នេះក៏មានគប្បីប្រកបសេចក្ដីដោយន័យមុនថា សូម្បីទាំងពីរនោះ ក៏ស្អុកស្អាញ លំបាកនឹងកំណត់ចុងនឹងចុង ឬគល់នឹងគល់ យ៉ាងណា ។

បទថា **មុញ្ជបព្វជភូតោ** (ចាក់កណ្ដាញ់ដូចស្មៅជំណោកទន្សាយ) បានដល់ កើតដូចជាស្មៅជំណោកទន្សាយ និងស្មៅយាប្លង គឺ លោកកើតមានដូច្នោះ ។ ការនឹងកាន់យកខ្សែដែលគេជំស្មៅទាំងនោះៗ ធ្វើ ហើយធ្លាក់ទៅក្នុងទីណាៗ ក្នុងវេលាដែលស្មៅនោះចាស់ហើយ ក៏លំបាកនឹងកំណត់ចុងឬគល់របស់ស្មៅទាំងនោះបានថា នេះចុង នេះគល់ បុគ្គលដែលតាំងនៅក្នុងសេចក្ដីព្យាយាមចំពោះខ្លួន ទើបអាចធ្វើខ្សែនោះឲ្យត្រង់បាន វៀរព្រះពោ-

ធិសត្វចេញ សត្វដទៃមិនអាចនឹងទម្លាយសំណាញ់ គឺ តណ្ហា ដោយធម្មតារបស់ខ្លួន ហើយធ្វើផ្លូវចេញចាកទុក្ខរបស់ខ្លួនឲ្យគ្រង់បាន យ៉ាងណា លោកនេះក៏យ៉ាងនោះ ត្រូវសំណាញ់ គឺ តណ្ហាចងហើយ រមែងមិនកន្លងផុតអបាយ ទុគ្គតិ វិនិបាត វដ្តសង្សារទៅបាន ។

ក្នុងបទទាំងនោះ បទថា **អបាយោ** (អបាយ) បានដល់ នរក កំណើតតិរច្ឆាន បេត្តិវិស័យ និងអសុរកាយ ។ សូម្បីទាំងអស់នោះ លោកហៅថា អបាយ ព្រោះមិនមានសេចក្តីចម្រើន ពោលគឺ សេចក្តីលូតលាស់ ។ មួយទៀត ឈ្មោះថា ទុគ្គតិ ព្រោះជាផ្លូវទៅនៃទុក្ខ ។ ឈ្មោះ វិនិបាត ព្រោះធ្លាក់ទៅចាកកាយដែលជាសុខ ។ ចំណែកក្រៅពីនេះ មានអធិប្បាយថា

*តំណរនៃខន្ធ ធាតុ អាយតនៈ ប្រព្រឹត្ត*
*ទៅមិនដាច់ខ្សែ លោកហៅថា សង្សារ ។*

សត្វលោកកន្លងមិនផុតទាំងអស់នោះ ដោយពិត សត្វលោកកាន់យកចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺ តពីចុតិ ក៏គឺ បដិសន្ធិ តពីបដិសន្ធិ ក៏គឺ ចុតិ ។ រមែងវិលវល់ក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណឋិតិ ៧ សត្តាវាស ៩ ដូចទូកត្រូវខ្យល់នៅក្នុងមហាសមុទ្រ ដូចគោដែលទឹមដោយយន្ត ដូច្នោះ ។

បទថា **អជ្ឈត្តិកស្ស ឧបាទាយ** បានដល់ អាស្រ័យខន្ធបញ្ចកៈខាងក្នុង ។ បទថា **អជ្ឈត្តិកស្ស** នេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **ពាហិរស្ស ឧបាទាយ** បានដល់ អាស្រ័យខន្ធ ៥ ខាងក្រៅ ។ បទថា **អស្មីតិ ភិក្ខវេ សតិ** (កាលមានសេចក្តីប្រកាន់ថា យើងមាន) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ការប្រកាន់ដោយអំណាចតណ្ហា មានះ ទិដ្ឋិ អាស្រ័យខន្ធ ៥ ខាងក្នុងនេះ មានហើយ ការគិតថា យើងមាន រមែងមាន គឺ ការគិតក្នុងខន្ធ ៥ នោះ ។ ក៏ក្នុងបទទាំងឡាយមានជាអាទិ៍ថា **ឥត្ថស្មីតិ ហោតិ** (រមែងមានការប្រកាន់ថា យើងមានយ៉ាងនេះ) កាលមានការប្រកាន់ដោយបំព្រួញយ៉ាងនេះថា ជាយើង រមែងប្រកាន់ដោយចំណែកពីរអំពីការប្រកាន់នោះ គឺ មិនប្រៀបធៀប និងប្រៀបធៀប ។ ពាក្យថា មិនប្រៀបធៀប សេចក្តីថា មិនប្រៀបធៀបហេតុដទៃ គឺ រមែងមានការគិតថា យើងជាយ៉ាងនេះ រមែងមាន ព្រោះធ្វើឲ្យជាអារម្មណ៍ក្នុងធម៌ គឺ ភាពលាមកតាមភាវៈរបស់ខ្លួន អធិប្បាយថា រមែងមានការគិតថា ក្នុងបណ្តាក្សត្រិយ៍ជាដើម យើងជាយ៉ាងនេះ ដោយអំណាចតណ្ហា មានះ និងទិដ្ឋិយ៉ាងនេះ ។ នេះគឺការមិនប្រៀបធៀប ហើយប្រកាន់ ។ ចំណែកការប្រៀបធៀបហើយប្រកាន់មានពីរយ៉ាង គឺ ដោយស្មើគ្នា និងដោយមិនស្មើគ្នា ។ កាលទ្រង់សម្តែង

ប្រការនោះ ទើបត្រាស់ថា យើងជាយ៉ាងនេះ និងយើងជាយ៉ាងដទៃ ។ ក្នុងបទទាំងនោះ បទថា **ឯវស្មិ** (យើងជាយ៉ាងនោះ) នេះ បានដល់ ប្រៀបធៀបដោយស្មើគ្នាថា យើងក៏ដូចជាក្សត្រិយ៍អង្គនេះ ដូចជាព្រាហ្មណ៍ម្នាក់នេះ ។ បទថា **អញ្ញថាស្មិ** (យើងជាយ៉ាងដទៃ) សេចក្តីថា ប្រកាន់ដោយមិនស្មើគ្នា ដូច្នេះថា យើងជាមនុស្សអាក្រក់ ឬជាមនុស្សល្អជាង ក្រៅពីក្សត្រិយ៍អង្គនេះ ព្រាហ្មណ៍ម្នាក់នេះ ។ គប្បីជ្រាបតណ្ហាវិចរិត ៤ យ៉ាង ទាំងនេះ ក្នុងបច្ចុប្បន្នកាល ។

ក៏តណ្ហាវិចរិត ២ នេះ គឺ **អសស្មីតិ សតស្មីតិ** (អាត្មាអញទៀង អាត្មាអញមិនទៀង) គប្បីជ្រាបថា ព្រោះហេតុនៃបទថា **អសស្មិ** នេះ ជាឈ្មោះនៃសេចក្តីទៀងក្នុងវត្ថុដែលមិនទៀង ។ បទថា **សតស្មិ** ជាឈ្មោះនៃសេចក្តីមិនទៀងក្នុងវត្ថុដែលទៀង ដូច្នោះ ទ្រង់ទើបត្រាស់ដោយអំណាចសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ តណ្ហាវិចរិត ៤ មានបទថា **សន្តិ** (យើងគប្បីមាន) ជាដើម បន្ទាប់ពីនេះ ត្រាស់ដោយអំណាចសេចក្តីសង្ស័យ និងការត្រិះរិះ ។ ក្នុងតណ្ហាវិចរិតទាំងឡាយ មានជាអាទិ៍យ៉ាងនេះថា **សន្តិ ហោតិ** (យើងគប្បីមាន) គប្បីជ្រាបសេចក្តីយ៉ាងនេះថា រមែងមានការគិតថា អាត្មាអញគប្បីមាន ។ ឯការអធិប្បាយក្នុងបទនេះ គប្បីកាន់យកដោយន័យដែល

ពោលហើយក្នុងពួក ៤ មុនៗ ។ មួយវិញទៀត តណ្ហាវិចរិត ៤ មានបទថា **អបិ សន្តិ** (យើងគប្បីមានខ្លះ) ជាអាទិ៍ ត្រាស់ដោយអំណាចសេចក្តីប្រាថ្នា និងការតាំងចិត្តយ៉ាងនេះថា អាត្មាអញនឹងគប្បីមានឬ ។ តណ្ហាវិចរិតទាំងនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងពួក ៤ មុនៗ ។ ក៏តណ្ហា-វិចរិត ៤ មានបទថា **ភវិស្សន្តិ** (យើងនឹងមាន) ជាអាទិ៍ ត្រាស់ដោយអំណាចអនាគតកាល ។ គប្បីជ្រាបសេចក្តីនៃតណ្ហាវិចរិតទាំងនោះ ដោយន័យដែលពោលហើយក្នុងពួក ៤ មុនៗ នោះឯង ។

**បណ្ឌិតគប្បីធ្វើឲ្យជាក់ច្បាស់តណ្ហាវិចរិត ១៨ ទាំងនេះ**

**គឺ ទិដ្ឋិសីសៈ ២ សុទ្ធសីសៈ ៤ សីសមូលកៈ ១២ ។**

ក៏ក្នុងតណ្ហាវិចរិតទាំងនោះ ២ ប្រការទាំងនេះ គឺ យើងមាន ១ យើងមានយ៉ាងនេះ ១ ឈ្មោះថា **ទិដ្ឋិសីសៈ** ។ ៤ ប្រការទាំងនេះ គឺ យើងមានយ៉ាងនោះ ១ យើងមានជាយ៉ាងដទៃ ១ យើងទៀង ១ យើងមិនទៀង ១ ឈ្មោះថា **សុទ្ធសីសៈ** ។ ១២ ប្រការ គឺ តណ្ហាវិចរិត ៣ មានជាអាទិ៍ថា យើងមានយ៉ាងនេះ ឈ្មោះថា **សីសមូលកៈ** ។ គប្បីជ្រាបធម៌ គឺ តណ្ហាវិចរិត ១៨ ទាំងនេះ គឺ ទិដ្ឋិសីសៈ ២ សុទ្ធសីសៈ ៤ សីសមូ-លកៈ ១២ ដូចពោលមកដូច្នេះ ។ គប្បីជ្រាប តណ្ហាវិចរិត ១៨ អាស្រ័យ

ខន្ធ ៥ ខាងក្នុងទាំងនេះ ។ ចំណែកក្នុងតណ្ហាវិចរិត អាស្រ័យខន្ធ ៥ ខាងក្រៅ ក៏ន័យនេះដូចគ្នា ។ បទថា **ឥមិនា** (ដោយខន្ធ ៥ នេះ) គប្បីជ្រាបសេចក្តីផ្សេងគ្នានេះ គឺ ដោយរូបនេះឬ ។ល។ ដោយវិញ្ញាណនេះ ។ បទដ៏សេសក៏ដូច្នោះដូចគ្នា ។ បទថា **ឥតិ ឯវរូបានិ អតីតានិ ឆត្តឹស** (តណ្ហា-វិចរិតបែបនេះ ដែលជាអតីត ៣៦) បានដល់ តណ្ហាវិចរិត ៣៦ ក្នុងកាលជាអតីតរបស់បុគ្គលតែម្នាក់ ។ បទថា **អនាគតានិ ឆត្តឹស** (អនាគត ៣៦) បានដល់ តណ្ហាវិចរិត ៣៦ ក្នុងអនាគតកាលរបស់បុគ្គលតែម្នាក់ ។ បទថា **បច្ចុប្បន្នានិ ឆត្តឹស** (ជាបច្ចុប្បន្ន ៣៦) បានដល់ តណ្ហាវិចរិត ៣៦ ក្នុងបច្ចុប្បន្នកាលរបស់បុគ្គលម្នាក់ ឬច្រើននាក់តាមហេតុដែលមាន ។ តណ្ហា-វិចរិតក្នុងអតីតកាល ៣៦ ក្នុងអនាគតកាល ៣៦ ក្នុងបច្ចុប្បន្នកាល ៣៦ ដោយទំនងនេះឯង របស់សត្វទាំងអស់ ។ ពិតណាស់ សត្វទាំងឡាយរមែងប្រកបដោយតណ្ហា មានះ ទិដ្ឋិ រកប្រមាណមិនបាន មិនមានទីបំផុត ។ ក៏ក្នុងបទថា **អដ្ឋតណ្ហាវិចរិតសតំ ហោតិ** (តណ្ហាវិចរិត ១០៨) នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា តណ្ហាវិចរិត រួមមាន ១០៨ ដូច្នេះ ។

ចប់អដ្ឋកថា តណ្ហាសូត្រទី ៩

## អដ្ឋកថា បេមសូត្រទី ១០

*"សេចក្តីស្រឡាញ់ សេចក្តីស្អប់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បេមសូត្រទី ១០ ដូចតទៅនេះ ៖*

[៥០] *បទថា **ន ឧស្សេនេតិ** (មិនប្រកាន់)[១] បានដល់ មិនលើកឡើងដោយអំណាចទិដ្ឋិ ។ បទថា **ន បដិសេនេតិ** (មិនតបត) បានដល់ សូម្បីនឹងក្រោធ ក៏មិនបង្កជាហេតុឈ្លោះ ប្រេះឆា ។ បទថា **ន ធូបាយតិ** (មិនរបិញរបុញ) បានដល់ មិនរបិញរបុញ ដោយអំណាចតណ្ហាវិចរិតអាស្រ័យខន្ធ ៥ ជាខាងក្នុង ។ បទថា **ន បជ្ជលតិ** (ឆួរឆេះ) បានដល់ មិនឆេះជាអណ្តាត ដោយអំណាចតណ្ហាវិចរិតអាស្រ័យខន្ធ ៥ ខាងក្រៅ ។ បទថា **ន បជ្ឈាយតិ** (មិនត្រូវភ្លើងឆេះ)[២] បានដល់ មិនត្រូវឆេះ ដោយអំណាចអស្មិមានះ ។ បទដ៏សេស គប្បីជ្រាបដោយន័យនៃបាលីនុ៎ះឯង ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ។*

ចប់អដ្ឋកថា បេមសូត្រទី ១០

### ចប់មហាវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

## ចប់ចតុត្ថបណ្ណាសកៈ

---

*បិដក (១) មិនលោលៅ , (២) មិនសុបសៅ ។*

# វគ្គមិនសង្គ្រោះចូលបណ្ណាសកៈ
## អដ្ឋកថា សិក្ខាបទសូត្រទី ១
### *"ពោលដោយសិក្ខាបទ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខាបទសូត្រទី ១ ដូចតទៅនេះ ៖*

[៥១] *បទថា* ***អសប្បុរិសំ*** *(អសប្បុរស) បានដល់ បុរសលាមក បុរសទទេ បុរសវង្វេង បុរសដែលត្រូវធ្វើឲ្យខ្វាក់ដោយអវិជ្ជា ។ បទថា* ***អសប្បុរិសតរំ*** *(អសប្បុរសក្រៃលែងជាងអសប្បុរស) បានដល់ ក្រៃលែងជាងអសប្បុរស ។ គប្បីជ្រាប សប្បុរសទាំងពីរក្រៅពីនេះ ដោយន័យផ្ទុយគ្នាដូចបានពោលហើយ ។ បទដ៏សេសក្នុងបទនេះ ងាយទាំងនោះ ។*

ចប់សិក្ខាបទ សូត្រទី ១

# អដ្ឋកថា អសទ្ធសូត្រទី ២

*“បុគ្គលមិនមានសទ្ធា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសទ្ធសូត្រទី ២ ដូចតទៅនេះ ៖*

[៥២] *ទ្រង់ត្រាស់ដល់អសទ្ធម្ម ។*

ចប់អដ្ឋកថា អសទ្ធសូត្រទី ២

# អដ្ឋកថា សត្តកម្មសូត្រទី ៣

*“កម្ម ៧ ប្រការ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តកម្មសូត្រទី ៣ ដូចតទៅនេះ ៖*

[៥៣] *ទ្រង់ត្រាស់ដល់កាយទ្វារ និងវចីទ្វារ ។*

ចប់អដ្ឋកថា សត្តកម្មសូត្រទី ៣

# អដ្ឋកថា ទសកម្មសូត្រទី ៤

*“កម្ម ១០ ប្រការ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទសកម្មសូត្រទី ៤ ដូចតទៅនេះ ៖*

[៥៤] *ទ្រង់ត្រាស់ដល់មនោទ្វារ ។*

ចប់អដ្ឋកថា ទសកម្មសូត្រទី ៤

# អដ្ឋកថា អដ្ឋង្គិកសូត្រទី ៥

*“ពោលដោយមគ្គមានអង្គ ៨”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អដ្ឋង្គិកសូត្រទី ៥ ដូចតទៅនេះ ៖*

[៥៥] *ទ្រង់ត្រាស់ដល់មិច្ឆត្ត: ៨ ។*

ចប់អដ្ឋកថា អដ្ឋង្គិកសូត្រទី ៥

# អដ្ឋកថា ទសមគ្គសូត្រទី ៦

## *"មគ្គ ១០ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទសមគ្គសូត្រទី ៦ ដូចតទៅនេះ ៖*

[៥៦] *ទ្រង់ត្រាស់ដល់មិច្ឆត្តៈ ១០ ។*

ចប់អដ្ឋកថា ទសមគ្គសូត្រទី៦

# អដ្ឋកថា បឋមបាបធម្មសូត្រទី ៧

## *“ធម៌អាក្រក់ និងធម៌ល្អ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបាបធម្មសូត្រទី ៧ ដូចតទៅនេះ ៖*

*[៥៧] បទថា **បាបំ** (មនុស្សអាក្រក់) បានដល់ មនុស្សលាមក គឺ បុគ្គលសៅហ្មង ។ បទថា **កល្យាណំ** (មនុស្សល្អ) បានដល់ បុគ្គលចម្រើន គឺ បុគ្គលមិនមានទោស ។ បទដ៏សេសក្នុងសូត្រនេះ ងាយហើយ ។*

ចប់អដ្ឋកថា បឋមបាបធម្មសូត្រទី ៧

# អដ្ឋកថា ទុតិយបាបធម្មសូត្រទី ៨

## "ធម៌អាក្រក់ និងធម៌ល្អ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយបាបធម្មសូត្រទី ៨ ដូចតទៅនេះ ៖*

[៥៨] *ក្នុងទុតិយបាបធម្មសូត្រ ក៏ន័យដូចគ្នា ។*

ចប់អដ្ឋកថា ទុតិយបាបធម្មសូត្រទី ៨

# អដ្ឋកថា តតិយបាបធម្មសូត្រទី ៩

## "ធម៌អាក្រក់ និងធម៌ល្អ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយបាបធម្មសូត្រទី ៩ ដូចតទៅនេះ ៖*

[៥៩] *បទថា* **បាបធម្មំ** *(អ្នកមានធម៌អាក្រក់) បានដល់ អ្នកមានធម៌លាមក ។ បទថា* **កល្យាណធម្មំ** *(អ្នកមានធម៌ល្អ) បានដល់ អ្នកមានធម៌ដែលមិនមានទោស ។ បទដ៏សេសក្នុងសូត្រនេះ ងាយហើយ ។*

ចប់អដ្ឋកថា តតិយបាបធម្មសូត្រទី ៩

# អដ្ឋកថា ចតុត្ថបាបធម្មសូត្រទី ១០

## *"ធម៌អាក្រក់ និងធម៌ល្អ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចតុត្ថបាបធម្មសូត្រទី ១០ ដូចតទៅនេះ ៖*

*[៦០] សូម្បីក្នុងចតុត្ថបាបធម្មសូត្រនេះ ក៏មានន័យដូចគ្នា ។*

*ក្នុងវគ្គនេះ លោកពោលដល់បដិបទារបស់អ្នកគ្រប់គ្រងផ្ទះ ទាំង ១០ សូត្រ ។ ប្រសិនបើគ្រហស្ថជា ព្រះសោតាបន្ន ព្រះសកទាគាមី រមែងគួរដូចគ្នា ។*

ចប់អដ្ឋកថា ចតុត្ថបាបធម្មសូត្រទី ១០

## ចប់សប្បុរិសវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សោភនវគ្គវណ្ណនាទី ២

## អដ្ឋកថា បរិសាសូត្រទី ១

### *"បុគ្គលទ្រុស្តបរិស័ទ ៤ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិសាសូត្រទី ១ ដូចតទៅនេះ ៖*

[៦១] *ឈ្មោះថា* ***បរិសទូសនា*** *(បុគ្គលទ្រុស្តបរិស័ទ) ព្រោះប្រទូសបរិស័ទ ។ ឈ្មោះថា* ***បរិសសោភនា*** *(បុគ្គលធ្វើបរិស័ទឲ្យស្អាត) ព្រោះញ៉ាំងបរិស័ទឲ្យស្អាត ។*

ចប់អដ្ឋកថា បរិសសូត្រទី ១

# អដ្ឋកថា ទិដ្ឋិសូត្រទី ២

## *“ពោលអំពីទិដ្ឋិ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទិដ្ឋិសូត្រទី ២ ដូចតទៅនេះ ៖*

[៦២] *មិច្ឆាទិដ្ឋិ សូម្បីរាប់បញ្ចូលនៅក្នុងមនោទុច្ចរិត លោកពោលទុកផ្សេង ក៏ព្រោះមានទោសច្រើន ចំណែកសម្មាទិដ្ឋិ លោកពោលព្រោះជាបដិបក្ខជាមួយមិច្ឆាទិដ្ឋិនោះ ។*

ចប់អដ្ឋកថា ទិដ្ឋិសូត្រទី ២

# អដ្ឋកថា អកតញ្ញុតាសូត្រទី ៣

*“ភាពអកតញ្ញូ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អកតញ្ញុតាសូត្រទី ៣ ដូចតទៅនេះ ៖*

[៦៣] *បទថា **អកតញ្ញុតា អកតវេទិតា** (ភាពអកតញ្ញូអកតវេទី) បានដល់ ដោយការមិនដឹងគុណ និងដោយការមិនតបគុណ ។ សូម្បីទាំងពីរបទនោះ ដោយអត្ថ តែម្យ៉ាងដូចគ្នានោះឯង ។ សូម្បីក្នុងសុក្កបក្ខ (ធម៌ចំណែកល្អ) ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា អកតញ្ញុតាសូត្រទី ៣

# អដ្ឋកថា បាណាតិបាតសូត្រទី ៤

*"បុគ្គលអ្នកសម្លាប់សត្វ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បាណាតិបាតសូត្រទី ៤ ដូចតទៅនេះ ៖*

[៦៤] *បាណាតិបាតសូត្រ លោកពោលដោយកម្មកិលេស ៤ និងធម៌ជាបដិបក្ខដល់កម្មកិលេសនោះ ។*

ចប់អដ្ឋកថា បាណាតិបាតសូត្រទី ៤

# អដ្ឋកថា បឋមមគ្គសូត្រទី ៥

*“ពោលអំពីមគ្គ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមគ្គសូត្រទី ៥ ដូចតទៅនេះ ៖*

[៦៥] *បឋមមគ្គសូត្រ លោកពោលដោយមិច្ឆត្តៈ ៤ ខាងដើមនៃសិក្ខាបក្ខ (សម្មត្តៈ) ។*

ចប់អដ្ឋកថា មគ្គសូត្រទី៥

# អដ្ឋកថា ទុតិយមគ្គសូត្រទី ៦

*"ពោលអំពីមគ្គ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមគ្គសូត្រទី ៦ ដូចតទៅនេះ ៖*

[៦៦] *ទុតិយមគ្គសូត្រ លោកពោលដោយមិច្ឆត្តៈ ៤ ដ៏សេស ។*

ចប់អដ្ឋកថា ទុតិយមគ្គសូត្រទី ៦

# អដ្ឋកថា បឋមវោហារសូត្រទី ៧

*“ផ្លូវនៃវោហារ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវោហារសូត្រទី ៧ ដូចតទៅនេះ ៖*

[៦៧] *បឋមវោហារសូត្រ លោកពោលដោយអនរិយវោហារ និង អរិយវោហារ ។*

ចប់អដ្ឋកថា បឋមវោហារសូត្រទី ៧

## អដ្ឋកថា ទុតិយវោហារសូត្រទី ៨

*"ផ្លូវនៃវោហារ"*

## អដ្ឋកថា អហិរិកសូត្រទី ៩

*"បុគ្គលមិនមានហិរិ"*

## អដ្ឋកថា ទុប្បញ្ញសូត្រទី ១០

*"បុគ្គលមិនមានបញ្ញា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨-៩-១០ ដូចតទៅនេះ ៖*

*[៦៨-៦៩-៧០] លោកពោលដោយអសទ្ធម្ម ដែលជាបដិបក្ខដល់សុក្កធម៌នោះ ៗ ក៏ក្នុងសូត្រទាំងនោះ ធម៌ជាសុក្កបក្ខ លោកពោលលាយទាំងលោកិយៈ និងលោកុត្តរៈ ៗ ក្នុង ៩ សូត្រ លោកពោលដល់ មគ្គដូច្នេះក៏ពិត តែក៏រមែងបានមគ្គ ៣ ផល ៣ ប៉ុណ្ណោះ ៗ*

ចប់អដ្ឋកថា សូត្រទី ៨-៩-១០

### ចប់សោភនវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ទុច្ចរិតវគ្គវណ្ណនាទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុងទុច្ចរិតវគ្គ ៣ ដូចតទៅនេះ ៖*

*[៧១-៨១] ទុច្ចរិតវគ្គវណ្ណនាទី ៣ ក្នុងទុច្ចរិតសូត្រទី ១ ជាដើម មានសេចក្ដីងាយហើយ ។ ក្នុងកវីសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ បុគ្គលដែលគិតហើយ ទើបតែងបទកវី ឈ្មោះថា* ***ចិន្តាកវី*** *។ បុគ្គលដែលស្ដាប់ហើយ ទើបតែងបទកវី ឈ្មោះថា* ***សុតកវី*** *។ បុគ្គលដែលអាស្រ័យសេចក្ដីហើយ តែងបទកវី ឈ្មោះថា* ***អត្ថកវី*** *។ បុគ្គលដែលតែងដោយបដិភាណរបស់ខ្លួនក្នុងខណៈនោះឯង ដូចព្រះវង្គីសថេរៈ ឈ្មោះថា* ***បដិភាណកវី*** *។*

### ចប់ទុច្ចរិតវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១ សូត្រ

# កម្មវគ្គវណ្ណនាទី ៤

## អដ្ឋកថា សង្ខិត្តសូត្រទី ១

*"កម្មដោយសង្ខេប"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខិត្តសូត្រទី ១ ដូចតទៅនេះ ៖*

*[៨២] បទថា **កណ្ហំ** (ខ្មៅ) បានដល់ កម្មខ្មៅ គឺ អកុសលកម្មបថ ១០ ។ បទថា **កណ្ហវិបាកំ** (មានវិបាកខ្មៅ) បានដល់ មានវិបាកខ្មៅ ព្រោះឲ្យកើតក្នុងអបាយ ។ បទថា **សុក្កំ** (ស) បានដល់ កម្មស គឺ កុសលកម្មបថ ១០ ។ បទថា **សុក្កវិបាកំ** (មានវិបាកស) បានដល់ មានវិបាកស ព្រោះឲ្យកើតក្នុងសួគ៌ ។ បទថា **កណ្ហំ សុក្កំ** (ទាំងខ្មៅទាំងស) បានដល់ កម្មលាយគ្នា ។ បទថា **កណ្ហសុក្កវិបាកំ** (មានវិបាកទាំងខ្មៅទាំងស) បានដល់ មានវិបាកទាំងសុខ និងទុក្ខ ។ ពិតហើយ បុគ្គលធ្វើកម្មលាយគ្នាហើយ កើតក្នុងឋានៈជាមង្គលហត្ថីជាដើម ក្នុងកំណើតសត្វតិរច្ឆានដោយអកុសល សោយសុខក្នុងបច្ចុប្បន្នដោយកុសល ។ បុគ្គលកើតសូម្បីក្នុងរាជត្រកូលដោយកុសល រមែងសោយទុក្ខក្នុងបច្ចុប្បន្នដោយអកុសល ។ បទថា **អកណ្ហំ អសុក្កំ** (មិនខ្មៅមិនស) លោកប្រាថ្នាយកមគ្គញាណ ៤ ដែលធ្វើកម្មឲ្យអស់ទៅ ។ ពិតណាស់ កម្មនោះ មិនថាជាកម្មខ្មៅ ក៏គប្បី*

ឲ្យវិបាកខ្មៅ មិនថាជាកម្មស គប្បីឲ្យវិបាកស តែដែលមិនខ្មៅមិនស ព្រោះមិនឲ្យវិបាកទាំងពីរ ដូចពោលមកនេះ ជាអត្ថក្នុងសេចក្តីនេះ ។

ចប់អដ្ឋកថា សង្ខិត្តសូត្រទី ១

# អដ្ឋកថា ទិត្ថារសូត្រទី ២

## “កម្មដោយពិស្ដារ”

*គប្បីជ្រាបវិនិច្ឆ័យក្នុង សន្ទិត្ថសូត្រទី ២ ដូចតទៅនេះ ៖*

[៨៣] *បទថា* ***សព្យាបជ្ឈំ*** *(ដែលមានសេចក្ដីបៀតបៀន) គឺ មានទោស ។ បទថា* ***កាយសង្ខារំ*** *(កាយសង្ខារ) បានដល់ ចេតនាក្នុងកាយ-ទ្វារ ។ បទថា* ***អភិសង្ខរោតិ*** *(តាក់តែង) បានដល់ កពូន គឺ ប្រមូលមក ។ សូម្បីក្នុងពីរពួកដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***សព្យាបជ្ឈំ លោកំ*** *(លោកដែលមានការបៀតបៀន) បានដល់ លោកជាទុក្ខ ។ បទថា* ***សព្យា-បជ្ឈា ផស្សា*** *(ផស្សៈដែលមានការបៀតបៀន) បានដល់ ផស្សៈជាវិបាកជាទុក្ខ ។ បទថា* ***សព្យាបជ្ឈំ វេទនំ វេទិយតិ*** *(រមែងសោយវេទនាដែលមានសេចក្ដីបៀតបៀន) បានដល់ សោយវេទនាមានវិបាក ប្រព្រឹត្តទៅជាមួយសេចក្ដីបៀតបៀន ។ បទថា* ***ឯកន្តទុក្ខំ*** *(ជាទុក្ខតែម្យ៉ាង បានដល់ ជាទុក្ខដោយចំណែកមួយប៉ុណ្ណោះ គឺ មិនលាយឡំដោយសុខ ។*

*បទថា* ***សេយ្យថាបិ*** *ក្នុងបទនេះថា* ***សេយ្យថាបិ សត្តា នេរយិកា*** *(ដូចសត្វនរក) គប្បីឃើញថា ជានិបាតចុះក្នុងអត្ថឧបមា ។ បទនោះ ទ្រង់សម្ដែងដល់សត្វនរកតែម្យ៉ាង ក៏សត្វដទៃឈ្មោះថា នឹងឃើញស្រដៀងគ្នា*

នឹងសត្វនរកនោះមិនមាន ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយឧបាយនេះ ។

ក៏ក្នុងបទមានជាអាទិ៍ថា **សេយ្យថាបិ មនុស្សា** (ដូចមនុស្ស) និងពោល ដល់ពួកមនុស្ស វេលាខ្លះកើតសុខវេទនា វេលាខ្លះកើតទុក្ខវេទនា ។ ចំណែកក្នុងបទនេះថា **ឯកច្ចេ ច ទេវា** (ទេវតាពួកខ្លះ) គប្បីឃើញថា ជាទេវតាជាន់កាមាវចរ: ។ ពិតហើយ ទេវតា ឃើញទេវតាអ្នកមានសក្តិ៍ធំជាងកាមាវចរៈទេពនោះ វេលាខ្លះរមែងកើតទុក្ខដោយកិច្ចមានជាអាទិ៍ថា ត្រូវក្រោកពីទីអង្គុយ ត្រូវដោះសំពត់ដណ្តប់ធ្វើសំពត់ឆៀងស្មា ត្រូវផ្គងអញ្ជលី ។ កាលសោយទិព្វសម្បត្តិ រមែងដល់នូវសេចក្តីសុខតាមវេលា ។ ក្នុងបទថា **ឯកច្ចេ ច វិនិបាតិកា** (និងវិនិបាតិកសត្វពួកខ្លះ) គប្បីឃើញដូចវេមានិកប្រេតពួកខ្លះ ។ វេមានិកប្រេតទាំងនោះ សោយសុខក្នុងវេលាមួយ សោយទុក្ខក្នុងវេលាមួយជួរនិរន្តរ: ។ ក៏សត្វទាំងឡាយ មាននាគ គ្រុឌ ដំរី និងសេះជាដើម រមែងមានទាំងសុខ និងទុក្ខ ដូចមនុស្ស ។ ក្នុងបទថា **បហានាយ យា ចេតនា** (ចេតនាណា... ដើម្បីលះ) នេះ គប្បីជ្រាបមគ្គចេតនាដែលឲ្យដល់វដ្ដ: និងវិវដ្ដ: ។ ពិតណាស់ មគ្គចេតនានោះ រមែងប្រព្រឹត្តទៅដើម្បីការអស់កម្ម ។

ចប់អដ្ឋកថា វិត្ថារសូត្រទី ២

# អដ្ឋកថា សោណកាយនសូត្រទី ៣

## *“សោណកាយនមាណព”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោណកាយនសូត្រទី ៣ ដូចតទៅនេះ ៖*

[៨៤] *បទថា* ***សិខាមោគ្គល្លានោ*** *(សិខាមោគ្គល្លានៈ) បានដល់ព្រាហ្មណ៍មោគ្គល្លានគោត្រ មានជុកធំតាំងនៅកណ្តាលសីសៈ ។ បទថា* ***បុរិមានិ*** *(ច្រើនថ្ងៃមកហើយ) បានដល់ ថ្ងៃមុន តាំងពីថ្ងៃដែលកន្លងទៅហើយ ។ គប្បីជ្រាបថ្ងៃដែលច្រើនជាងថ្ងៃមុន ចាប់តាំងពីថ្ងៃទីពីរជាដើម ។ បទថា* ***សោណកាយនោ*** *(សោណកាយនៈ) បានដល់ អន្តេវាសិករបស់ព្រាហ្មណ៍នោះឯង ។ បទថា* ***កម្មសច្ចាយំ ភោ លោកោ*** *(លោកនេះមានកម្មជាសភាវៈ) ។ បទថា* ***កម្មសមារម្ភដ្ឋាយី*** *(តាំងនៅដោយការបង្កកម្ម) សេចក្តីថា លោកនេះ តាំងនៅដោយការកកើតនៃកម្ម គឺ កពូនទូវកម្ម មិនមែនមិនកពូន ។ លោកសម្តែងថា រមែងជាប់សូន្យ ។ បទដ៏សេស មានន័យដូចពោលហើយក្នុងខាងក្រោយនុ៎ះឯង ។*

ចប់អដ្ឋកថា សោណកាយនសូត្រទី ៣

# អដ្ឋកថា សិក្ខាបទសូត្រទី ៤

## *“ពោលអំពីសិក្ខាបទ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខាបទសូត្រទី ៤ ដូចតទៅនេះ ៖*

[៨៥] *សិក្ខាបទសូត្រទី ៤ ជាដើម មានសេចក្ដីងាយហើយ ។ ក៏អង្គមគ្គទាំងឡាយ លោកពោលថា ព្រោះព្រះយោគាវចរចូលទៅតាំងសតិទុក ហើយកំណត់ដោយបញ្ញា ដូច្នោះ ទាំងពីរនោះឯងជាកម្ម ដ៏សេសជាអង្គប៉ុណ្ណោះ មិនមែនកម្ម ។ សូម្បីពោជ្ឈង្គៈក៏ន័យនេះដូចគ្នា ។ ចំណែកក្នុងអភិធម្ម លោកពណ៌នាកម្មទាំងអស់នោះថា ជាកម្មដែលសម្បយុត្តដោយចេតនា ដោយមិនប្លែកគ្នា ។*

ចប់អដ្ឋកថា សិក្ខាបទសូត្រទី ៤

# អដ្ឋកថា សិក្ខាបទសូត្រទី ៥

*“ពោលអំពីសិក្ខាបទ”*

[៨៦] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា សិក្ខាបទសូត្រទី ៥

# អដ្ឋកថា អរិយមគ្គសូត្រទី ៦

*"ពោលអំពីអរិយមគ្គ"*

[*៨៧*] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា សិក្ខាបទសូត្រទី ៥

# អដ្ឋកថា ពោជ្ឈង្គសូត្រទី ៧

*“ពោលអំពីពោជ្ឈង្គៈ”*

[៨៨] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ពោជ្ឈង្គសូត្រទី ៧

# អដ្ឋកថា សាវជ្ជសូត្រទី ៨

*"កម្មដែលមានទោស និងមិនមានទោស"*

[៨៩] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា សាវជ្ជសូត្រទី ៨

# អដ្ឋកថា អព្យាបជ្ឈសូត្រទី ៩

*“កម្មដែលមិនមានការបៀតបៀន”*

[៩០] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា សិក្ខាបទសូត្រទី ៩

# អដ្ឋកថា សមណសូត្រទី ១០

## *"សមណា ៤ ប្រភេទ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមណសូត្រទី ១០ ដូចតទៅនេះ ៖*

*[៩១] បទថា **ឥធេវ** (ក្នុងធម្មវិន័យនេះប៉ុណ្ណោះ) គឺ ក្នុងសាសនានេះប៉ុណ្ណោះ ។ ក៏សេចក្តីមិនពិតនេះ គប្បីជ្រាបសូម្បីក្នុងបទដ៏សេស ។ ពិតហើយ សូម្បីសមណៈទី ២ ជាដើម ក៏មាននៅក្នុងសាសនានេះប៉ុណ្ណោះ មិនមានក្នុងសាសនាដទៃ ។ បទថា **សុញ្ញា** (ទទេ) បានដល់ សូន្យទទេ ។ បទថា **បរប្បវាទា** (លទ្ធិដទៃ) បានដល់ ទិដ្ឋិ ៦២ ដែលមកហើយក្នុងព្រហ្មជាលសូត្រ សូម្បីទាំងអស់នេះ គឺ សស្សតវាទៈ ៤ ឯកច្ចសស្សតិកៈ ៤ អន្តានត្តិកៈ ៤ អមរាវិក្ខេបិកៈ ៤ អធិច្ចសមុប្បន្និកៈ ២ សញ្ញីវាទ ១៦ អសញ្ញីវាទ ៨ នេវសញ្ញីនាសញ្ញីវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ វាទៈរបស់បុគ្គលដទៃក្រៅពីធម៌វិន័យនេះ ឈ្មោះ **បរប្បវាទៈ** ។ វាទៈសូម្បីទាំងអស់នោះ សូន្យចាកសមណៈដែលតាំងនៅក្នុងផល ៤ ទាំងនេះ ទាំងវាទៈទាំងនោះ ក៏មិនមាននៅក្នុងធម្មវិន័យនេះ ។ មួយទៀត វាទៈទាំងនោះ មិនមែនសូន្យចាកសមណៈទាំងនេះតែប៉ុណ្ណោះ ទាំងសូន្យចាកសមណៈសូម្បី ១២ គឺ សមណៈដែលតាំងនៅក្នុងមគ្គ ៤ ខ្ទះ សមណៈដែល*

ប្រារព្ធវិបស្សនាដើម្បីប្រយោជន៍ដល់មគ្គ ៤ ខ្ទះ ។ ព្រះមានព្រះភាគទ្រង់សំដៅសេចក្តីនេះ ទើបត្រាស់ទុកក្នុងមហាបរិនិព្វានសូត្រថា

ម្នាលសុភទ្ទៈ តថាគតមានវ័យ ២៩ ស្វែងរកថា
អ្វីជាកុសល ទើបចេញបួស តាំងពីតថាគតបួស
ហើយ រាប់បាន ៥១ ឆ្នាំ សូម្បីសមណៈប្រព្រឹត្ត
ក្នុងប្រទេសនៃធម៌ជាគ្រឿងត្រាស់ដឹង មិនមាន
ក្រៅអំពីក្នុងធម្មវិន័យនេះ ។

សូម្បីសមណៈទី ២ ក៏មិនមាន សូម្បីសមណៈទី ៣ ក៏មិនមាន សូម្បីសមណៈទី ៤ ក៏មិនមាន លទ្ធិដទៃសូន្យទទេចាកសមណបណ្ឌិត ។

ពិតហើយ អ្នកប្រារព្ធវិបស្សនា លោកបំណាងយកក្នុងបទថា ប្រព្រឹត្តក្នុងប្រទេសនេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើសមណៈសូម្បី ៣ ពួក គឺ សមណៈអ្នកប្រារព្ធវិបស្សនាដើម្បីសោតាបត្តិមគ្គ ១ សមណៈអ្នកតាំងនៅក្នុងមគ្គ ១ សមណៈអ្នកតាំងនៅក្នុងផល ១ រួមគ្នាទើបត្រាស់ថា សូម្បីសមណៈ ក៏មិនមាន ។ ទ្រង់ធ្វើសមណៈ ៣ ពួក គឺ សមណៈអ្នកប្រារព្ធវិបស្សនាដើម្បីសកទាគាមិមគ្គ ១ សមណៈអ្នកតាំងនៅក្នុងមគ្គ ១ សមណៈអ្នកតាំងនៅក្នុងផល ១ រួមគ្នា ទើបត្រាស់ថា សូម្បីសមណៈទី

*២ ក៏មិនមានដូច្នេះ ។ សូម្បីក្នុងសមណៈពីរពួកដ៏សេសក្រៅអំពីនេះ ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា សមណសូត្រទី ១០

# អដ្ឋកថា សប្បុរិសានិសង្សសូត្រទី ១១

*"អានិសង្សនៃការសេពគប់សប្បុរស"*

[៩២] *មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា សប្បុរិសានិសង្សសូត្រទី ១១

## ចប់កម្មវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អាបត្តិភយវគ្គវណ្ណនាទី ៥

## អដ្ឋកថា សង្ឃភេទកសូត្រទី ១

*"ពោលអំពីភិក្ខុបំបែកសង្ឃ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ឃភេទកសូត្រទី ១ ដូចតទៅនេះ ៖*

[៩៣] *បទថា* ***អបិ នុតំ អានន្ទ អធិករណំ*** *(អានន្ទ... អធិករណ៍នោះ) សេចក្តីថា បណ្តាអធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើម អធិករណ៍ណាមួយ កើតឡើងហើយដល់ភិក្ខុសង្ឃ ។ ព្រះសាស្តាកាលទឹងសួរដល់រឿងអធិករណ៍នោះថា ស្ងប់ហើយឬនៅ ទើបត្រាស់យ៉ាងនេះ ។ បទថា* ***កុតោ តំ ភន្តេ*** *(អធិករណ៍នោះ រម្ងាប់អំពីទីណា) ព្រះអានន្ទ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អធិករណ៍នោះនឹងរម្ងាប់អំពីណាបាន គឺ អធិករណ៍នោះ នឹងរម្ងាប់បានដោយហេតុណា ។ បទថា* ***កេវលកប្បំ*** *បានដល់ បន្ទាបង់តែម្យ៉ាង ។ បទថា* ***សង្ឃភេទាយ ឋិតោ*** *(តាំងនៅក្នុងការបំបែកសង្ឃ) បានដល់ ព្រះវាហិយៈតាំងជំហរពោលតទល់ជាមួយសង្ឃ ។ បទថា* ***តត្ថាយស្មា*** *(កាលព្រះវាហិយៈតាំងនៅយ៉ាងនោះហើយ) បានដល់ កាលព្រះវាហិយៈនោះ ស្ថិតនៅយ៉ាងនេះ ព្រះអនុរុទ្ធ ។ បទថា* ***ន ឯកវចិកំបិ ភណិតព្វំ មញ្ញតិ*** *(មិនឲ្យសេចក្តីសំខាន់ដែលគប្បីពោលសូម្បីត្រឹមតែពាក្យ*

មួយម៉ាត់) សេចក្តីថា ព្រះអនុរុទ្ធមិនដាក់ធុរៈដែលនឹងពោលថា ម្នាលអ្នកមានអាយុ លោកកុំនិយាយយ៉ាងនេះនឹងសង្ឃ ។ បទថា **វោយុញ្ជតិ** (នឹងចាត់ការជម្រះ) បានដល់ ខ្វល់ខ្វាយ គឺ តាំងសេចក្តីព្យាយាម ។ បទថា **អត្ថវសេ** (អំណាចប្រយោជន៍) ប្រែថា ព្រោះអំណាចនៃហេតុ ។ បទថា **នាសេស្សន្តិ** (នឹងនាសនៈ) បានដល់ ភិក្ខុទាំងឡាយ មិនឲ្យយើងចូលទៅនឹងគ្រាហ៍យើងចេញពីឧបោសថ និងបវារណា ។ បទដ៏សេស គប្បីជ្រាបតាមបាលីនុ៎ះឯង ។

ចប់អដ្ឋកថា សង្ឃភេទកសូត្រទី ១

# អដ្ឋកថា អាបត្តិសូត្រទី ២

## *"ការភ័យខ្លាចចំពោះអាបត្តិ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាបត្តិសូត្រទី ២ ដូចតទៅនេះ ៖*

*[៩៤] បទថា **ខុរមុណ្ឌំ ករិត្វា** (កោរសក់) បានដល់ កោរសក់ទុក ៥ កញ្ចុំ ។ បទថា **ខរស្សរេន** (មានសំឡេងខ្លាំង) គឺ សំឡេងក្រអៅ ។ បទថា **បណវេន** គឺ ស្គរប្រហារ ។ បទថា **ថលដ្ឋស្ស** (ឈរក្នុងទីមួយ) គឺ បុរសម្នាក់ឈរក្នុងទីមួយកន្លែង ។ បទថា **សីសច្ឆេជ្ជំ** (ត្រូវកាត់ក្បាល) គឺ គួរដល់ការកាត់ក្បាល ។ បទថា **យត្រ ហិ នាម** កែជា **យំ នាម** ។ បទថា **សោ វតស្សំ** បានដល់ យើងនេះឯង មិនគួរធ្វើបាបបែបនេះឡើយ ។ បទថា **យថាធម្មំ បដិករិស្សតិ** (នឹងសម្តែងតាមធម្មតា) គឺ នឹងប្រព្រឹត្តឲ្យសមគួរដល់ធម៌ ។ អធិប្បាយថា នឹងតាំងនៅក្នុងសាមណេរភូមិ ។ បទថា **កាឡកំ វត្ថំ បរិធាយ** (ស្លៀកដណ្តប់សំពត់ខ្មៅ) បានដល់ ស្លៀកដណ្តប់សំពត់ចាស់ពណ៌ខ្មៅ ។ បទថា **មោសល្លំ** (កាន់អង្រែ) គឺ គួរលីអង្រែ ។*

*បទថា **យថាធម្មំ** (តាមធម្មតា) សេចក្តីថា ចេញចាកអាបត្តិក្នុងធម្មវិន័យនេះ ហើយតាំងនៅក្នុងសេចក្តីបរិសុទ្ធ ឈ្មោះថា រមែងប្រព្រឹត្តតាមធម៌ ។ បទថា **អស្សបុដំ** បានដល់ កញ្ចប់ផេះ ។ បទថា **គារយ្ហំ អស្ស-***

**បជំ** (គួរតិះដៀល គួរឲ្យលើកញូប់ផេះ) បានដល់ គួរឲ្យលើកញូប់ផេះទៅ គួរតិះដៀល ។ បទថា **យថាធម្មំ** (តាមធម៌) បានដល់ សម្តែងអាបត្តិក្នុងធម្មវិន័យនេះ ឈ្មោះថា រមែងប្រព្រឹត្តតាមធម៌ ។ បទថា **ឧបវជ្ជំ** បានដល់ គួរតិះដៀល ។ បទថា **បាដិទេសនីយេសុ** គឺ គួរសម្តែង ។ អាបត្តិដ៏សេសសូម្បីទាំងអស់ លោកសង្គ្រោះដោយបទនេះ ។ បទថា **ឥមានិ ខោ ភិក្ខវេ ចត្តារិ អាបត្តិភយានិ** (ម្នាលភិក្ខុទាំងឡាយ សេចក្តីភ័យខ្លាចដល់អាបត្តិ ៤ ប្រការនេះឯង) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សេចក្តីភ័យខ្លាចអាបត្តិ ៤ ប្រការនេះ ឈ្មោះថា ភ័យអាស្រ័យអាបត្តិកើតឡើង ។

ចប់អដ្ឋកថា អាបត្តិសូត្រទី ២

# អដ្ឋកថា សិក្ខានិសំសសូត្រទី ៣

## "ព្រហ្មចរិយមានសិក្ខាជាអានិសង្ស"

គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខានិសង្សសូត្រទី ៣ ដូចតទៅនេះ ៖

[៩៥] ព្រហ្មចរិយៈ ឈ្មោះថា **សិក្ខានិសំសំ** (សិក្ខាជាអានិសង្ស) ព្រោះមានសិក្ខាជាអានិសង្ស ។ បទថា **បញ្ញុត្តរំ** (មានបញ្ញាជាកំពូល) ព្រោះមានបញ្ញាជាទីបំផុត ។ ឈ្មោះ **វិមុត្តិសារំ** ព្រោះមានវិមុត្តិជាខ្លឹម ។ ឈ្មោះ **សតាធិបតេយ្យំ** (មានសតិជាអធិបតី) ព្រោះមានសតិជាធំ ។ លោកអធិប្បាយទុកថា ប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីប្រយោជន៍ដល់អានិសង្សជាដើម ដែលបានដល់សិក្ខាជាដើមទាំងនោះ ។ បទថា **អភិសមាចារិកា** បានដល់ សិក្ខាជាប់ដោយអភិសមាចារដែលប្រសើរបំផុត ។ បទនេះ ជាឈ្មោះរបស់សីលដែលទ្រង់បញ្ញត្តិទុក ដើម្បីជាវត្តបដិបត្តិ ។ បទថា **តថា តថា សោ តស្សា សិក្ខាយ** (សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដោយប្រការផ្សេងៗ) បានដល់ ភិក្ខុនោះជាអ្នកប្រាថ្នាសិក្សាក្នុងសិក្ខាបទនោះយ៉ាងនោះ ។ បទថា **អាទិព្រហ្មចរិយកា** នេះ ជាឈ្មោះនៃមហាសីល ៤ ដែលជាខាងដើមនៃព្រហ្មចរិយៈ ។ បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង ។

បទថា **ធម្មា** (ធម៌ទាំងឡាយ) បានដល់ សច្ចធម៌ ៤ ។ បទថា **បញ្ញាយ សមវេក្ខិតា ហោន្តិ** (ដែលសាវកពិចារណាដោយបញ្ញា) សេចក្ដីថា ធម៌ទាំងឡាយដែលសាវកពិចារណាឃើញដោយល្អ ដោយមគ្គប្បញ្ញាជាមួយសមាធិ និងវិបស្សនា ។ បទថា **វិមុត្តិយា ផុសិតា ហោន្តិ** (ជាធម៌ពាល់ត្រូវហើយដោយវិមុត្តិ) បានដល់ ធម៌ទាំងឡាយដែលសាវកពាល់ត្រូវ (សម្រេច) ដោយវិមុត្តិ គឺ អរហត្តផល គឺ ដោយផស្សៈ គឺ ញាណ ។ បទថា **អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ** (សតិដែលភិក្ខុតាំងទុកល្អហើយខាងក្នុង) សេចក្ដីថា សតិដែលសាវកចូលទៅតាំងទុកដោយល្អក្នុងខាងក្នុងខ្លួននោះឯង ។ បទថា **បញ្ញាយ អនុគ្គហេស្សាមិ** (នឹងអនុគ្រោះ... ដោយបញ្ញា) សេចក្ដីថា យើងនឹងផ្គងដោយវិបស្សនាបញ្ញា ។ សូម្បីក្នុងបទថា **បញ្ញាយ សមវេក្ខិស្សាមិ** (នឹងពិចារណា... ដោយបញ្ញា) នេះ ក៏បំណាងយកសូម្បីវិបស្សនាបញ្ញា ។ តែក្នុងបទនេះថា **ផុសិតំ វា ធម្មំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** (នឹងអនុគ្រោះធម៌ ដែលយើងពាល់ត្រូវដោយបញ្ញាក្នុងឋានៈនោះ) លោកបំណាងយកមគ្គប្បញ្ញាតែម្យ៉ាង ។

ចប់អដ្ឋកថា សិក្ខានិសំសសូត្រទី ៣

# អដ្ឋកថា សេយ្យសូត្រទី ៤

## *"ការដេក ៤ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេយ្យសូត្រទី ៤ ដូចតទៅនេះ ៖*

*[៩៦] អ្នកស្ដាប់ហើយ លោកហៅថា បេតៈ ។ បទថា* ***ឧត្តានា សេន្តិ*** *(ដេកផ្ងារ) បានដល់ អ្នកស្ដាប់ទាំងនោះដោយច្រើនដេកផ្ងារ ។ ម្យ៉ាងទៀត សត្វដែលកើតក្នុងបិត្តិវិស័យ ឈ្មោះថា បេតៈ (ប្រេត) ។ ប្រេតទាំងនោះ ព្រោះមានសាច់ និងឈាមតិច មានឆ្អឹងឡើងរគាម មិនអាចនឹងដេកផ្អៀងបាន ទើបបានតែដេកផ្ងារតែម្យ៉ាង ។*

*បទថា* ***អនត្តមនោ ហោតិ*** *(រមែងមិនពេញចិត្ត) សេចក្ដីថា ក៏សីហមិគរាជ ព្រោះជាសត្វមានអំណាចច្រើន ដាក់ជើងទាំងពីរខាងមុខត្រង់ឯជើងខាងក្រោយមួយកន្លែង ស៊កកន្ទុយទុកក្នុងចន្លោះភ្លៅ កំណត់ឱកាសត្រង់ជើងមុខ ជើងក្រោយ និងកន្ទុយ ហើយដាក់ក្បាលលើជើងមុខទាំងពីរដេក កាលភ្ញាក់ពីដេកឡើងក៏មិនតក់ស្លុត ភ្ញាក់ផ្អើល តែងើបក្បាលឡើងសង្កេតមើលឱកាសត្រង់ជើងមុខជាដើម បើឃ្លៀងឃ្លាតខុសទីដើម ក៏មិនពេញចិត្តថា នេះមិនសមគួរដល់ជាតិត្រកូលរបស់យើង មិនសមគួរដល់អ្នកក្លាហាន ទើបដេកក្នុងទីនោះទៀត មិនចេញទៅស្វែងរកអាហារ ។ បទថា*

*រមែងមិនពេញចិត្ត លោកពោលសំដៅយកប្រការនេះ ។ តែកាលអ្វីៗ មិនយៀងឃ្លាតទេ សីហមិគរាជទើបត្រេកអរថា នេះសមគួរដល់ជាតិត្រកូលរបស់អ្នក និងសមគួរដល់សេចក្ដីជាអ្នកក្លាហានរបស់អ្នក ហើយក្រោកចាកទីនោះ ពត់កាយរលាស់រោមក បន្លឺសីហនាទ ៣ ដង ទើបចេញរកអាហារ ។ ព្រោះហេតុនោះ ទើបត្រាស់ថា* ***អត្តមនោ ហោតិ*** *(រមែងពេញចិត្ត) លោកពោលដោយប្រការនេះ ។*

ចប់អដ្ឋកថា សេយ្យសូត្រទី ៤

# អដ្ឋកថា ថូបារហសូត្រទី ៥

## *“ថូបារហបុគ្គល ៤”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ថូបារហសូត្រទី ៥ ដូចតទៅនេះ ៖*

*[៩៧] ក្នុងបទថា **រាជា ចក្កវត្តី** (ស្តេចចក្រពត្តិ) នេះ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់អនុញ្ញាតការកសាងស្តូប ចំពោះស្តេចចក្រពត្តិដែលសុគតហើយ ទ្រង់មិនអនុញ្ញាតឲ្យធ្វើដល់ភិក្ខុដែលជាបុថុជ្ជនអ្នកមានសីល ។ ឆ្លើយថា ព្រោះភិក្ខុជាបុថុជ្ជនមិនជាអច្ឆរិយៈ ។ ព្រោះកាលព្រះមានព្រះភាគទ្រង់អនុញ្ញាតស្តូបទាំងឡាយ ដល់ភិក្ខុដែលជាបុថុជ្ជន ក៏នឹងមិនមានកន្លែងដាក់ ស្តូបក្នុងស្រុក និងកំពង់ចម្លង ក្នុងតម្ពបណ្ណិទ្វីបឡើយ ក្នុងទីដទៃក៏យ៉ាងនោះ ព្រោះដូច្នោះ ទើបទ្រង់មិនអនុញ្ញាត ព្រោះទ្រង់ឃើញថា ភិក្ខុទាំងនោះនឹងមិនជាអច្ឆរិយៈ ។ ស្តេចចក្រពត្តិទ្រង់ឧប្បត្តិតែមួយព្រះអង្គប៉ុណ្ណោះ ព្រោះហេតុនោះ ស្តូបរបស់ស្តេចចក្រពត្តិទើបជាអច្ឆរិយៈ ។ តែគួរធ្វើសក្ការៈធំដល់ភិក្ខុបុថុជ្ជនអ្នកមានសីល ដូចភិក្ខុដែលបរិនិព្វានហើយដូច្នោះ ដោយពិត ។*

ចប់អដ្ឋកថា ថូបារហសូត្រទី ៥

# អដ្ឋកថា បញ្ញាវុឌ្ឍិសូត្រទី ៦

## *“សេចក្តីចម្រើននៃបញ្ញា”*

[៩៨] *អដ្ឋកថាបញ្ញាវុឌ្ឍិសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា បញ្ញាវុឌ្ឍិសូត្រទី ៦

# អដ្ឋកថា ពហុការសូត្រទី ៧

*"ធម៌មានឧបការៈច្រើនដល់មនុស្ស"*

[៩៩] *អដ្ឋកថាពហុការសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ពហុការសូត្រទី ៧

# អដ្ឋកថា បឋមវោហារសូត្រទី ៨

## *"វោហារ ៤"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវោហារសូត្រទី ៨ ដូចតទៅនេះ ៖*

[១០០] *បទថា* ***អនរិយវោហារា*** *បានដល់ ការនិយាយរបស់បុគ្គលមិនមែនជាអរិយៈ ។ ក្នុងបទដ៏សេសងាយហើយ ។*

ចប់អដ្ឋកថា បឋមវោហារសូត្រទី ៨

# អដ្ឋកថា ទុតិយវោហារសូត្រទី ៩

*"វោហារ ៤"*

[១០១] *អដ្ឋកថាទុតិយវោហារសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ទុតិយវោហារសូត្រទី៩

# អដ្ឋកថា តតិយវោហារសូត្រទី ១០

*“វោហារ ៤”*

[១០២] *អដ្ឋកថាតតិយវោហារសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា តតិយវោហារសូត្រទី ១០

# អដ្ឋកថា ចតុត្ថវោហារសូត្រទី ១១

*"វោហារ ៤"*

[១០៣] *អដ្ឋកថាតតិយវោហារសូត្រ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ចតុត្ថវោហារសូត្រទី ១១

## ចប់អាបត្តិភយវគ្គវណ្ណនាទី ៩

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៦ សូត្រ

# អភិញ្ញាវគ្គវណ្ណនាទី ៦

## អដ្ឋកថា អភិញ្ញាសូត្រទី ១

*"ធម៌ដែលដឹងដ៏ក្រៃលែង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អភិញ្ញាសូត្រទី ១ ដូចតទៅនេះ ៖*

[១០៤] *បទថា* ***អភិញ្ញា*** *(ដឹងដ៏ក្រៃលែងហើយ) បានដល់ ដឹងដ៏ក្រៃលែងដោយបញ្ញា ។ បទថា* ***សមថោ ច វិបស្សនា ច*** *(សមថៈ និងវិបស្សនា) បានដល់ ភាពជាអ្នកមានចិត្តមានអារម្មណ៍តែមួយ និងវិបស្សនាញាណជាគ្រឿងកំណត់ដឹងសង្ខារ ។ បទថា* ***វិជ្ជា ច វិមុត្តិ ច*** *(វិជ្ជា និងវិមុត្តិ) បានដល់ វិជ្ជាដែលជាមគ្គញាណ និងសម្បយុត្តធម៌ដ៏សេស ។*

ចប់អដ្ឋកថា អភិញ្ញាសូត្រទី ១

# អដ្ឋកថា បរិយេសនាសូត្រទី ២

*"ការស្វែងរក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិយេសនាសូត្រទី ២ ដូចតទៅនេះ ៖*

*[១០៥] បទថា **អនរិយបរិយេសនា** បានដល់ ការស្វែងរក គឺ ការស្វែងរករបស់បុគ្គលមិនមែនជាអរិយៈ ។ បទថា **ជរាធម្មំ** (វត្ថុដែលមានជរាជាធម្មតា) បានដល់ វត្ថុដែលមានសេចក្តីចាស់ជាសភាវៈ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា បរិយេសនាសូត្រទី ២

# អដ្ឋកថា សង្គហសូត្រទី ៣

*"ធម៌ជាគ្រឿងសង្គ្រោះគ្នា"*

[១០៦] *អដ្ឋកថាសង្គហសូត្រ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សង្គហសូត្រទី ៣

# អដ្ឋកថា មាលុង្ក្យបុត្តសូត្រទី ៤

## “មាលុង្ក្យបុត្តទូលសូមឱវាទ”

[១០៧] បទថា មាលុង្ក្យបុត្តោ បានដល់ បុត្ររបស់មាលុង្ក្យព្រាហ្មណ៍ ។ បទថា ឯត្ថ (ក្នុងសេចក្តីនេះ) បានដល់ ក្នុងការអង្វរសូមឱវាទរបស់មាលុង្ក្យបុត្ត ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់ហាមខ្លះ ទ្រង់សរសើរខ្លះ ដល់ព្រះថេរៈ ។ សួរថា ដូចម្តេច ។ ឆ្លើយថា បានឮថា កាលព្រះមាលុង្ក្យបុត្តនៅកំលោះ ក៏ជាប់ជំពាក់ក្នុងបច្ច័យលាភ តមកដល់ខ្លួនចាស់បំណាងនឹងនៅព្រៃ ទើបអង្វរសូមកម្មដ្ឋាន ។ គប្បីប្រកបសេចក្តីថា លំដាប់នោះ ព្រះមានព្រះភាគកាលត្រាស់ដោយព្រះបំណងថា ទីនេះ តថាគតនឹងពោលជាមួយភិក្ខុកំលោះៗ ដូចម្តេច សូម្បីពួកអ្នក ក៏ដូចមាលុង្ក្យបុត្តក្នុងវេលានៅកំលោះរវល់តែជាប់ជំពាក់ក្នុងបច្ច័យ តែដល់ខ្លួនចាស់ក៏ចូលព្រៃបំពេញសមណធម៌ ដូច្នេះ ឈ្មោះថា ទ្រង់ហាមព្រះថេរៈ ។ ក៏ព្រោះហេតុដែលព្រះថេរៈ ក្នុងវេលាចាស់ ខ្លួនចូលព្រៃបំណងនឹងធ្វើសមណធម៌ ដូច្នោះ ព្រះមានព្រះភាគត្រាស់ដោយព្រះបំណងថា ទីនេះ តថាគតនឹងពោលជាមួយភិក្ខុកម្លោះៗ យ៉ាងណាហ្ន៎ មាលុង្ក្យបុត្តរបស់ពួកអ្នកនេះ សូម្បីវេលាខ្លួនចាស់ក៏បំណងចូលព្រៃ ប្រាថ្នានឹងបំពេញសមណធម៌ ទើប

*អង្គវសេមកម្មដ្ឋាន ពួកអ្នកសម្បីវេលានៅជាកំលោះ ក៏មិនបានធ្វើសេចក្តីព្យាយាមជាមុន ដូច្នេះ ឈ្មោះថា ទ្រង់សរសើរព្រះថេរៈ ដូច្នេះ ។*

ចប់អដ្ឋកថា មាលុង្ក្យបុត្តសូត្រទី ៤

# អដ្ឋកថា កុលសូត្រទី ៥

*“ហេតុឲ្យត្រកូលតាំងនៅមិនយូរ”*

[១០៨] *បទថា* ***អាធិបច្ចេ ឋបេន្តិ*** *(តាំង... ស្ត្រី ឬបុរសឲ្យជាធំ) បានដល់ តាំងទុកក្នុងតំណែងអ្នករក្សាឃ្លាំង ។*

ចប់អដ្ឋកថា កុលសូត្រទី ៥

# អដ្ឋកថា បឋមអាជានេយ្យសូត្រទី ៦

## *"អង្គរបស់សេះអាជានេយ្យ"*

[១០៩] *បទថា **វណ្ណសម្បន្នោ** (សម្បូរដោយពណ៌) បានដល់ ដល់ព្រមដោយសម្បុរកាយ ។ បទថា **ពលសម្បន្នោ** (សម្បូរដោយកម្លាំង) បានដល់ ដល់ព្រមដោយកម្លាំងកាយ ។ បទថា **ភិក្ខុ វណ្ណសម្បន្នោ** (ភិក្ខុសម្បូរដោយពណ៌) បានដល់ ដល់ព្រម ដោយវណ្ណៈ គឺ គុណ ។ បទថា **ពលសម្បន្នោ** (សម្បូរដោយកម្លាំង) បានដល់ ដល់ព្រមដោយកម្លាំង គឺ សេចក្ដីព្យាយាម ។ បទថា **ជវសម្បន្នោ** (សម្បូរដោយសន្ទុះ) បានដល់ ដល់ព្រមដោយសន្ទុះជើង គឺ ញាណ ។*

ចប់អដ្ឋកថា បឋមអាជានេយ្យសូត្រទី ៦

# អដ្ឋកថា ទុតិយអាជានេយ្យសូត្រទី ៧

*"អង្គរបស់សេះអាជានេយ្យ"*

[១១០] *មានសេចក្តីដូចសូត្រទី ៦ ដែរ ។*

ចប់អដ្ឋកថា ទុតិយអាជានេយ្យសូត្រទី ៧

# អដ្ឋកថា ពលសូត្រទី ៨

## *“កម្លាំង ៤ ប្រការ”*

[១១១] *មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា ពលសូត្រទី ៨

# អដ្ឋកថា អារញ្ញសូត្រទី ៩

*"ធម៌របស់បុគ្គលគួរនៅព្រៃ និងមិនគួរនៅព្រៃ"*

[១១២] *មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា អារញ្ញសូត្រទី៩

# អដ្ឋកថា កម្មសូត្រទី ១០

## *“កម្ម និងទិដ្ឋិ”*

[១១៣] *មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា អារញ្ញសូត្រទី ៩

## ចប់អភិញ្ញាវគ្គវណ្ណនាទី ៦

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# កម្មបថវគ្គវណ្ណនាទី ៧

## អដ្ឋកថា កម្មបថសុត្រ

*“ពោលដោយពួកកម្មបថ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កម្មបថសូត្រ ដូចតទៅនេះ ៖*

*[១១៤-១២៣] ក្នុងកម្មបថទាំង ១០ លោកពោលលាយគ្នា ទាំងលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា កម្មបថសុត្រ

**ចប់កម្មបថវគ្គវណ្ណនាទី ៧**

ក្នុងវគ្គនេះ ព្រះអដ្ឋកថាកែអត្ថរូមគ្នា

# រាគបេយ្យាលវណ្ណនា

## អដ្ឋកថា រាគបេយ្យាល

*“ធម៌គួរចម្រើនដើម្បីដឹងច្បាស់នូវរាគៈជាដើម”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រាគបេយ្យាល ដូចតទៅនេះ ៖*

[១២៨] *រាគបេយ្យាល ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងឲ្យដល់ព្រះអរហត្ត ។ បទដ៏សេសក្នុងទីទាំងពួង ងាយហើយ ។*

ចប់អដ្ឋកថា រាគបេយ្យាលវណ្ណនា

## ចប់អដ្ឋកថាចតុក្កនិបាត អង្គុត្តរនិកាយ

## ឈ្មោះ

## មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សាវឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសកសោម រតនៈព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |